ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- កម្មវត្ថុនៃអំពើមនុស្សធម៌ក្លែងក្លាយ
- បណ្ណាល័យសម្តេចម៉ែ
- សូមប្រកាសរកយាយដែលបាត់ខ្លួន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៧១ ខែកក្កដា ឆ្នាំ២០២២

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៧១ ខែកក្កដា ឆ្នាំ២០២២

## មាតិកា

### សំបុត្រ

◆ កម្មវត្ថុនៃអំពើមនុស្សធម៌ក្លែងក្លាយ.........១
◆ បណ្ណាល័យសម្តេចម៉ែ ........................ ៤

### ផ្នែកឯកសារ

◆ ហ៊ីង គ្រុយ លេខាស្រុកកណ្តាលស្ទឹង........ ៦

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ កូប ហ៊ាទីម៉ះ ៖ របបខ្មែរក្រហមធ្វើឲ្យខ្ញុំ.... ១០
◆ ដួង ធីង ៖ ឈ្លបភូមិសម័យខ្មែរក្រហម ... ១២
◆ ម៉ៅ វណ្ណា ៖ ខ្ញុំនៅចាំពាក្យសម្តីរបស់..... ១៤
◆ យាន់ យួន ៖ កងសែងយុទ្ធជន............១៧
◆ ជា ខេងថៃ ៖ ប្រធានមន្ទីរពាណិជ្ជកម្ម...... ១៩
◆ ប៉ុល ខន ៖ ជាងសាងសង់ផ្ទះ............. ២២
◆ អ៊ុក ម៉ុក ៖ ប្រធានក្រុមនៅកងចល័ត .... ២៤
◆ ខ្ញុំនៅតែសោកស្តាយប្អូនប្រុសរបស់ខ្ញុំ ... ២៦
◆ អតីតប្រធានកងរថក្រោះ .................. ២៦
◆ គង់ ស៊ុម ៖ កងផលិត..................... ២៨
◆ ខ្ញុំគឺជាពេទ្យស្ម័គ្រចិត្តបដិវត្តន៍.............. ៣០
◆ ញ៉ឹម សំកើ៖ គ្រួសារខ្ញុំត្រូវជម្លៀស........៣៣
◆ គី ហៀង៖ ខ្ញុំចូលធ្វើទ័ពខ្មែរក្រហម........៣៥

### វេទិកាពិភាក្សាសាធារណៈ

◆ យុវជនមកពីស្រុកកំចាយមារ ស្វែងយល់អំពី. ប្រវត្តិសាស្ត្រខ្មែរក្រហម......................៣៨
◆ សិស្សានុសិស្សវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍........ ៤០
◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកា ថ្នាក់រៀនចុងសប្តាហ៍........................៤៤
◆ វេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពីសារសំខាន់ នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជា ......... ៤៩



កងទ័ពបដិវត្តន៍ខ្មែរក្រហមកំពុងរោយស្រូវដែលទើបនឹងបោកបែនរួចៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

◆ វេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ.......................៥៤
◆ និស្សិតមកពីវិទ្យាស្ថានពហុបច្ចេកទេស ខេត្តកំពង់ចាម ចូលរួមវេទិកាអន្តរជំនាន់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ...... ៥៧

### ស្រាវជ្រាវរកគ្រួសារ

◆ ស្វែងរកបងដែលបាត់ខ្លួន .................. ៦១
◆ សូមប្រកាសរកយាយដែលបាត់ខ្លួន....... ៦១
◆ «ទួលពិឃាដ»..............................៦២

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, មីន សាណាស់, គាត ស្រីឡែន, ស៊ាង ចិន្តា, ភា រស្មី, ថុន ស្រីពេជ្រ, សៀង កញ្ញា, សូ ហាន់, អ៊ុន សុដាវី, ដេង ពង្សរ៉ាស៊ី, ទូច វណ្ណេត, សួត វិចិត្រ, ឈុំ រ៉ា, អេង វណ្ណីកា និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាក ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# កម្មវត្ថុនៃអំពើមនុស្សធម៌ក្លែងក្លាយ

ឆាំង យុ



លោក ដី ទេរិទ្ធ ប្រធានគម្រោងការចូលរួមរបស់ជនរងគ្រោះ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជួយជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជាបំពេញបែបបទបណ្តឹងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដើម្បីរាយការណ៍អំពីអំពើឃោរឃៅដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម។ តាមរយៈការជួយបំពេញទម្រង់បែបបទចូលរួមរបស់ជនរងគ្រោះនេះ ជនរងគ្រោះក្នុងរបបខ្មែរក្រហមអាចស្នើសុំចូលរួមយ៉ាងសកម្មក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក តាមវិធីបីយ៉ាង៖ ដោយការស្ម័គ្រចិត្តធ្វើជាសាក្សី តាមរយៈការដាក់ពាក្យបណ្តឹងនិង ដោយការដាក់ពាក្យសុំចូលរួមជា "ជនរងគ្រោះ" នៅក្នុងបណ្តឹងរដ្ឋប្បវេណី។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីថ្ងៃទី១៦ ខែមិថុនា លោកស្រី មេហ្គេន ហើស បានស្នើសុំដកខ្លួនចេញពីតំណែងជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈលិខិតរិះគន់ ដែលបានអំពាវនាវឲ្យមានការយកចិត្តទុកដាក់ចំពោះកង្វះខាតផ្នែកធនធានយ៉ាងខ្លាំង និងការយកចិត្តទុកដាក់ជារួម ដើម្បីជាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ លោកស្រីបានគូសបញ្ជាក់ពីការបរាជ័យជារួមក្នុងការមិនអនុវត្តតាមការសន្យារបស់យើងចំពោះជនរងគ្រោះនៅក្នុងដំណើរការស្វែងរកយុត្តិធម៌សម្រាប់ខ្មែរក្រហម។

បើធៀបទៅនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិពីមុនៗមក សមិទ្ធផលដ៏អស្ចារ្យមួយរបស់ អ.វ.ត.ក គឺការទទួលស្គាល់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី។ ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីដែលបង្ហាញថា ខ្លួនបានទទួលរងរបួសផ្លូវកាយ ផ្លូវចិត្ត ឬជាសម្ភារដែលកើតឡើងដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែលត្រូវបានកាត់ទោសនៅចំពោះមុខ អ.វ.ត.ក។

តុលាការបានទទួលស្គាល់ពួកគាត់ថា ជាជនរងគ្រោះ ហើយពួកគាត់ត្រូវបានគេសន្មតថាមានសិទ្ធិជាទូទៅស្រដៀងគ្នានឹងការកាត់ទោស និងមេធាវីការពារក្តី។

ការបង្កើតឲ្យមានដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិចូលរួមរបស់ពួកគាត់ គឺតំណាងឲ្យការសន្យាក្នុងការផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះ។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ជនម្នាក់ត្រូវមានឱកាសទោះបីជាមានការកម្រិតកំណត់ និងតាមរយៈអ្នកតំណាងស្របច្បាប់ដែលត្រូវបានតែងតាំងរបស់ខ្លួនក៏ដោយ គួរមានសិទ្ធិចូលរួម និងទទួលបានការជូនដំណឹងអំពីដំណើរការយុត្តិធម៌នេះ។

ការផ្តល់សិទ្ធិអំណាចនេះត្រូវបានទទួលស្គាល់ថាជាគោលការណ៍ដ៏សំខាន់មួយនៅក្នុង អ.វ.ត.ក ដោយហេតុថាគេជឿថាការណ៍នេះ នឹងជួយដល់ការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងការផ្សះផ្សាជាតិ។

ការចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក មានន័យថា ការរងការឈឺចាប់ និងសំឡេងរបស់ពួកគាត់ត្រូវបានទទួលស្គាល់ជារួមក្នុងកម្រិតនៅក្នុងតុលាការ។ ចំណុចសំខាន់ដូចគ្នានេះដែរគឺ សិទ្ធិទទួលបានព័ត៌មានអំពីដំណើរការយុត្តិធម៌មានន័យថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ម្នាក់ៗក្នុងនាមជាជនរងគ្រោះ ហើយពួកគាត់អាចប្រើប្រាស់ដំណើរការរបស់ អ.វ.ត.ក ជាឱកាសមួយដើម្បីបង្ហាញពីបទពិសោធន៍របស់ខ្លួនក៏ដូចជាការស្វែងរកការពិតសម្រាប់ជម្រះវិបត្តិផ្លូវចិត្តរបស់ពួកគាត់។

ជនរងគ្រោះភាគច្រើនជាប្រជាជនក្រីក្រ ជនចាស់ជរា និងបានទទួលរងនូវផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តមួយចំនួននៅក្នុងរបបខ្មែរក្រហម។ (ឧទាហរណ៍ ជំងឺផ្លូវចិត្ត ឬជំងឺតានតឹងអារម្មណ៍) ដូច្នេះ សិទ្ធិក្នុងការចូលរួម និងទទួលបានព័ត៌មានអំពីដំណើរការយុត្តិធម៌គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ជាការពិត ការបរាជ័យរបស់យើងក្នុងការលើកតម្កើងនូវសិទ្ធិទាំងនេះសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ គឺជាកង្វះខាត ឬការត្រួតពិនិត្យមិនបានដិតដល់គួរឲ្យកត់សម្គាល់។

សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងអស់ យុត្តិធម៌គឺមានអត្ថន័យលើសពីការបង្កើតអង្គហេតុដែលបញ្ជាក់អំពីពិរុទ្ធភាព ឬភាពគ្មានទោសកំហុសរបស់ជនល្មើសដែលត្រូវបានចោទប្រកាន់ទៅទៀត ពោលគឺដើម្បីបង្កើតឡើងវិញនូវអធិបតេយ្យភាពសង្គមស៊ីវិលដែលបានយកឈ្នះទៅលើរបបដ៏ព្រៃផ្សៃ និងឧត្តមភាពរបស់មនុស្សជាតិទៅលើភាពអមនុស្សធម៌។ នៅពេលដែលយើងមិនបានបំពេញតាមការសន្យារបស់យើងចំពោះជនរងគ្រោះ យើងមិនត្រឹមតែធ្វើឲ្យថយចុះភាពអាចជឿទុកចិត្តរបស់ស្ថាប័នដែលទទួលបន្ទុកលើកិច្ចការទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែយើងក៏បានធ្វើឲ្យប៉ះពាល់ដល់ភាពអាចជឿទុកចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងរបស់យើងទាំងមូល។

អ.វ.ត.ក គឺជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិដំបូងគេដែលកំពុងព្យាយាមធ្វើការកាត់ទោសឧក្រិដ្ឋកម្មដ៏ឃោរឃៅ ដែលផ្តល់ឱកាសឲ្យជនរងគ្រោះចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនីតិវិធីកាត់ក្តីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ ប្រសិនបើយើងមិនគោរពតាមការសន្យារបស់យើងចំពោះជនរងគ្រោះទេនោះ យើងច្បាស់ជាគ្មានអ្វីផ្តល់ជូនជនរងគ្រោះ ក្រៅពីកម្មវត្ថុនៃអំពើមនុស្សធម៌ក្លែងក្លាយនោះទេ។

លោក ឆាំង យុ គឺជានាយកប្រតិបត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងជាអ្នករស់រានមានជីវិតពី "វាលពិឃាត" របស់ខ្មែរក្រហម។ ក្នុងចំណោមការរួមចំណែកជា

ច្រើនរបស់លោកចំពោះការពិត និងយុត្តិធម៌ លោកបានផ្តល់សក្ខីកម្មនៅចំពោះមុខសាលាក្តីខ្មែរក្រហម បានបង្កើតកម្មវិធីអប់រំអំពីអំពើរបបប្រល័យពូជសាសន៍ទូទាំងប្រទេស និងបានបង្កើតមជ្ឈមណ្ឌលថ្នាក់ភូមិភាគចំនួនប្រាំនៅទូទាំងប្រទេសកម្ពុជា រួមទាំងបណ្ណាល័យ សម្តេចម៉ែ ដើម្បីជួយសម្រួលដល់ការអប់រំ ការស្រាវជ្រាវ និងការផ្សះផ្សាៗ



លោក ដឺ ទេរិទ្ធ ប្រធានគម្រោងការចូលរួមរបស់ជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជួយជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅទូទាំងប្រទេសកម្ពុជាបំពេញបែបបទបណ្តឹងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដើម្បីរាយការណ៍អំពីអំពើឃោរឃៅដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហមៗ តាមរយៈការជួយបំពេញទម្រង់បែបបទ ចូលរួមរបស់ជនរងគ្រោះនេះ ជនរងគ្រោះក្នុងរបបខ្មែរក្រហមអាចស្នើសុំចូលរួមយ៉ាងសកម្មក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក តាមវិធីបីយ៉ាង៖ ដោយការស្ម័គ្រចិត្តធ្វើជាសាក្សី តាមរយៈការដាក់ពាក្យបណ្តឹងនិង ដោយការដាក់ពាក្យសុំចូលរួមជា "ជនរងគ្រោះ" នៅក្នុងបណ្តឹងរដ្ឋប្បវេណីៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# បណ្ណាល័យសម្តេចម៉ែ

សោម ប៊ុនថន




*ក្រុមយុវជនទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បណ្ណាល័យសម្តេចម៉ែ គឺជាស្ថាប័នមួយដែលបម្រើដល់ការសិក្សាស្រាវជ្រាវ បង្ហាញអំពីវប្បធម៌ និងសិល្បៈ ដោយទទួលបានការជំរុញចិត្តពីព្រះរាជដំណើរជីវិតរបស់សម្តេចព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈ។ ដោយមានសម្តេចម៉ែ ជាព្រះរាជកត្តាជំរុញចិត្ត បណ្ណាល័យសម្តេចម៉ែ សូមឧទ្ទិសកិច្ចខិតខំប្រឹងប្រែងឈានទៅសម្រេចបានឯករាជ្យភាពរបស់ប្រជាជនកម្ពុជា តាមរយៈការអប់រំ។ ការអប់រំ គឺពិតជាចាំបាច់ណាស់សម្រាប់យុវជន-យុវនារីកម្ពុជា ដែលតំណាងឲ្យអនាគតប្រទេសកម្ពុជា។ ការអប់រំបើកទូលាយនូវការយល់ឃើញរបស់យុវវ័យ ឲ្យចាកឆ្ងាយពីគំនាបនៃភាពមិនអើពើ រីឯវប្បធម៌និងសិល្បៈផ្តល់ឱកាសឲ្យយុវជន-យុវនារី ទទួលបានគំនិត ការយល់ឃើញ និងចក្ខុវិស័យថ្មីៗសម្រាប់អនាគត។ យើងបានទទួលស្វាគមន៍យុវជន-យុវនារីជាច្រើនរូប ដែលមកសិក្សាស្វែងយល់ ហើយយើងមានបំណងទទួលស្វាគមន៍យុវជន-យុវនារីគ្រប់រូប។ យើងស្វាគមន៍យុវជន-យុវនារីកម្ពុជា ទាំងអស់អញ្ជើញទស្សនកិច្ចនិងសិក្សាស្វែងយល់ ព្រមទាំងទទួលបានបទពិសោធន៍ក៏ដូចជាទទួលបានចំណេះដឹងពីបណ្ណាល័យសម្តេចម៉ែ។ បណ្ណាល័យសម្តេចម៉ែ មិនត្រឹមតែជាទីតាំងសម្រាប់ការសិក្សាយល់ដឹងអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាទីតាំងដែលបណ្តុះស្មារតីសិក្សារៀនសូត្រ, កត្តាជំរុញចិត្ត និងនាំនូវវត្តភាព។ បណ្ណាល័យសម្តេចម៉ែ មានវត្តមានឡើង តំណាងឲ្យការប្តេជ្ញាចំពោះប្រទេសជាតិកម្ពុជា ប្រជាជនកម្ពុជា និងអ្នករាល់គ្នា។




ក្រុមយុវជនទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)











# ហ៊ីង គ្រុយ លេខាស្រុកកណ្តាលស្ទឹង តំបន់២៥

**ជាវ៉ាវ៉ុដ្ឋ មេត្តា**



កម្មាភិបាល និងយោធាខ្មែរក្រហមចុះទៅតាមសហករណ៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហ៊ីង គ្រុយ ភេទប្រុស អាយុ៤០ឆ្នាំ នៅក្នុងឆ្នាំ១៩៦៧។ ខ្ញុំមានតួនាទីជាលេខាស្រុកកណ្តាលស្ទឹង តំបន់២៥។ ខ្ញុំមានស្រុកកំណើតនៅភូមិកោះតូច ឃុំតាលុន ស្រុកស្អាង តំបន់២៥។ ពេលខ្ញុំមានអាយុប្រហែល៧ឆ្នាំ ឪពុកម្តាយខ្ញុំនាំខ្ញុំទៅនៅវត្តតាលុនដើម្បីឲ្យខ្ញុំបានរៀនសូត្រ។ នៅពេលខ្ញុំអាយុ១៣ឆ្នាំ ខ្ញុំបួសជាព្រះសង្ឃ។ ខ្ញុំបួសបានរយៈពេល១ឆ្នាំ ក៏ទៅរៀនបន្តនៅសាលាបាលីរងនៅវត្តទឹកវិល ស្ថិតនៅឃុំកោះខែល ស្រុកស្អាង។ ខ្ញុំរៀនរយៈពេល១ឆ្នាំដោយមិនទាន់បានប្រឡងផង ក៏ត្រឡប់មកនៅវត្តតាលុនវិញ។ នៅពេលខ្ញុំអាយុ១៧ឆ្នាំ ទើបខ្ញុំសឹក។ បន្ទាប់មក ខ្ញុំមករស់នៅជាមួយឪពុកម្តាយ និងជួយធ្វើការងារធ្វើស្រែចម្ការ។ នៅឆ្នាំ១៩៥៧ ខ្ញុំចេញទៅបាត់ដំបងប្រកបរបររធាក់រ៉ឺម៉ក លក់នំប៉័ង និងការ៉េមកី បានរយៈពេល១ខែកន្លះ ក៏ត្រឡប់មករស់នៅជាមួយឪពុកម្តាយឯស្រុកកំណើតវិញ។

តាំងពីខ្ញុំដឹងក្តីមកខ្ញុំស្គាល់ តាបាវ ត្រូវជាបងជីដូនមួយ ចំណែក ឆឹង តូ គឺជាជីទួតមួយ។ ក្រោយមក ឈុន គ្រី បានរៀបចំគ្រួសារជាមួយកូនតាបាវ ដូច្នេះខ្ញុំបានស្គាល់ ឈុន គ្រី ទៀតដែលមាននាទីថែរក្សាដំណាំមន្ទីររដ្ឋតំបន់២៥តាំងពីពេលនោះមក។ នៅចន្លោះឆ្នាំ១៩៦១ ដល់ឆ្នាំ១៩៦២ តាបាវ, ឈុន

គ្រី, ឆឹង គូ បានណែនាំខ្ញុំឲ្យចូលធ្វើបដិវត្តន៍ និងមានការកិច្ចឃោសនាប្រមូលយុវជនឲ្យចូលធ្វើបដិវត្តន៍។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បក្ខពួកខ្ញុំបានបើកអង្គប្រជុំដោយមានអ្នកចូលរួមឈ្មោះ តាបាវ ក្រោយមកស្លាប់នៅក្នុងឆ្នាំ១៩៧៣, ឈុន គ្រី, ឆៃ ហម នៅកសិកម្មតំបន់២៥, ហួត សេ, ខ្ញុំ និងជនជាតិវៀតណាមឈ្មោះ ហាយ ថាយ ដើម្បីរៀបចំផែនការកម្ទេចឈ្មោះ សុវណ្ណ។ យើងគិតថា ប្រសិនបើ សុវណ្ណ ធ្វើជាលេខាបក្ខ ពួកខ្ញុំធ្វើអ្វីក៏មិនបាន និងមិនអាចមានបក្ខពួកធ្វើនៅក្នុងតំបន់នេះទៀតទេ។ នៅខែតុលា ឆ្នាំ១៩៧០ ខ្ញុំស្គាល់ គ្រូសុខ, តាចំរើន និងបក្ខពួករបស់គាត់។ នៅដើមខែវិច្ឆិកា ឆ្នាំ១៩៧០ បក្ខពួកក្បត់របស់ខ្ញុំធ្វើសកម្មភាពកម្ទេច សុវណ្ណ នៅតាមផ្លូវ។ នៅពេលនោះ សុវណ្ណ បានរត់រួចប៉ុន្តែត្រូវស្លាប់ឈ្មោះ កែវ សាភិន និង នីរសាររបស់គាត់ម្នាក់។

នៅខែមករា ឆ្នាំ១៩៧១ គ្រូសុង ត្រូវអង្គការហៅទៅរៀនសូត្រនៅភូមិភាគបូព៌ា ហើយនៅពេលនោះភូមិភាគបូព៌ា បានបញ្ជូនកម្មាភិបាលដែលលាក់ខ្លួនទៅវៀតណាមខាងជើងមកតំបន់២៥មួយចំនួន ក្នុងនោះមានពីរនាក់គឺជាសមាសភាពគណៈតំបន់ គឺ សូ ពុំ គឺជាលេខាតំបន់២៥ និង សៀន សាន គឺជាសមាជិកគណៈតំបន់២៥។

នៅក្នុងឆ្នាំ១៩៧២ ខ្ញុំប្រគល់ភារកិច្ចឲ្យបក្ខពួកខ្ញុំនៅស្រុកស្អាងមានតាផ្លុង គឺជាលេខាស្រុកស្អាង, យ៉ែម សឿង គឺជាអនុប្រធានស្រុក, ឆោ ស៊ីវ, ប៊ុន លី, សូ ភ្លី, សែត ហៅ សូត្រ, ឆឹង គូ និង ប៊ុល ស៊ីង គឺជាប្រធានពេទ្យស្រុកឲ្យធ្វើសកម្មភាព។ ក្រោយពីទាក់ទង តាជ័យ ផ្ទាល់ដើម្បីរាយការណ៍និងស្នើយោបល់ពីការងាររួចហើយ នៅពាក់កណ្តាលខែធ្នូ តាជ័យ ប្រាប់ខ្ញុំថាភូមិភាគរៀបចំកងឈ្លបស្រុកស្អាង ឲ្យទៅជាកងវរសេនាតូចរបស់តំបន់ មានការធ្វើបញ្ជីយុទ្ធជនឲ្យបានត្រឹមត្រូវ ហើយខ្ញុំត្រូវចាត់តាំងទៅខាងទ័ព។ ចាប់តាំងពីពេលនោះមកខ្ញុំចាប់ផ្តើមរៀបចំបញ្ជីយោធា។

នៅខែមករា ឆ្នាំ១៩៧៣ តាជ័យ និងគ្រូសុខ នាំបក្ខពួកខ្ញុំមកនៅកងទ័ពជាមួយខ្ញុំដើម្បីប្រកាសតួនាទីបណ្តោះអាសន្ន។ គ្រូសុខ ប្រាប់ថានៅក្នុងខែមករានេះ អាចនឹងកើតមានបាតុកម្មគឺត្រូវប្រយ័ត្ន។ យើងត្រូវបង្ក្រាបដោយអាវុធ ប៉ុន្តែមិនបាញ់ឲ្យចំទេ រួចចាប់បញ្ជូនទៅមន្ទីរអប់រំ។ តាជ័យ ប្រាប់ថា នៅថ្ងៃទី១៨ ខែមករា ខាងមុនរៀបចំកម្លាំងទាំងអស់ឲ្យដល់សាលាស្រុកកោះធំ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៣ ខ្ញុំបានចាត់កម្លាំងតាមការរៀបចំ។ លេខាភូមិភាគប្រកាសចាត់តាំងគណៈបញ្ជាការកងវរសេនាតូចមាន៥នាក់ គឺ ខ្ញុំគឺជាស្នងការ, ប៊ុល ស៊ីង អនុបញ្ជាការ, សារ៉េត បញ្ជាការ, គាម អនុបញ្ជាទី១, សុត អនុបញ្ជាការទី២ ហើយការបង្កើតកងនេះមានឈ្មោះវរសេនាតូចលេខ ១២៤ គឺជាកងរបស់តំបន់ប្រចាំតំបន់២៥។ លុះពេលចប់ពិធី ខ្ញុំនាំកងត្រឡប់មកសមរភូមិវិញ។ ព្រមជាមួយថ្ងៃបុណ្យប្រកាសចាត់តាំងកងទ័ព ក៏មានក្បួនធ្វើបាតុកម្មកើតឡើងនៅក្នុងឃុំព្រែកអំបិល ដោយមានការរុះរើផ្ទះគណៈឃុំ ចាប់គណៈភូមិចង។

នៅទីថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៣ ក្បួនបាតុកម្មនេះដង្ហែសំដៅទៅមន្ទីរស្រុកបន្តទៅតំបន់ដោយមានគ្រូទុំ គឺជាអ្នកដឹកនាំបាតុកម្ម។ ខ្ញុំនាំកងមកដល់ក្តាប់បានសភាពការណ៍ ក៏ដាក់កងទ័ព ហើយរៀបចំធ្វើការដូចការណែនាំរបស់ តាជ័យ ខ្ញុំឲ្យកងទ័ពស្ទាក់ក្បួនបាតុករទាំងអស់ចូលវត្តព្រែកអំបិល លុះចូលវត្តទាំងអស់ហើយស្រាប់តែតាចំរើនតាផ្លុងមកដល់ខ្ញុំក៏ប្រគល់ឲ្យពួកគាត់ទាំងពីរនាក់ទៅដោះស្រាយឲ្យត្រឡប់ទៅផ្ទះវិញ។ ចាំពេលល្ងាច ខ្ញុំនាំកម្លាំងចាប់ខ្លះធ្វើឲ្យប្រជាជនភ័យខ្លាច។ លុះពេលយប់ខ្ញុំនាំកងដើរចាប់តាមផ្ទះបានចំនួន២០នាក់បញ្ជូនទៅមន្ទីរ១៣ ហើយមានអ្នកដែលខ្ញុំមិនទាន់ចាប់បាននាំគ្នារត់ចូលព្រៃ។ នៅយប់ថ្ងៃទី១៩ មានបាតុកម្មកើតឡើងនៅឃុំត្រើយស្លា តំបន់២៥ មានលក្ខណៈដូចនៅឃុំព្រែកអំបិលដែរ ហើយបាតុកម្មនេះដឹកនាំដោយ តាបាន គឺជាអ្នករៀបចំហើយមាន តា ឡុក និង តាឌួក គឺជាអ្នកដឹកនាំដង្ហែដោយផ្ទាល់។ បាតុករទាំងពីរកន្លែងនេះ បានសំណូមពរដូចគ្នាថា

១) សុំឲ្យអង្គការចេញលិខិតឲ្យដើររកទិញអង្ករ, ២) សុំឲ្យអង្គការកុំទុកស្រូវ ត្រូវចែកគ្នាហូប, ៣) សុំឲ្យអង្គការបើកច្បាប់ឲ្យដូចដើមវិញ, ៤) សុំអង្គការបើកឲ្យធ្វើបុណ្យដូចដើមវិញ, ៥) សុំប្រគល់ដីឲ្យមកអ្នកដែលមានដីតិចវិញ។

ក្រុមកងដែលបញ្ជូនឲ្យបង្ក្រាបបាតុករ គឺកងវរសេនាតូចលេខ១២១ ដែលមានឈ្មោះ សៅ ស៊ិន គឺជាស្នងការ, ខាត់ គឺជាបញ្ជាការកងពល ១២ វរសេនាតូច ២៦៥, ប៊ុន លាត គឺជាអនុបញ្ជាការកងពល ១២, ប៊ុន ស៊ិញ ហៅ សំ ស្នងការអនុសេនាធំ និង សឿន ស្នងការអនុសេនាធំ កងពល១១ វរសេនាតូច១២១។ ការបង្ក្រាបនេះមានសភាពខ្លាំងជាងនៅព្រែកអំបិល ព្រោះមានគ្រូ សុង ចូលរួមដែរ។ កងនេះបានកាប់ប្រជាជននៅកន្លែងកើតហេតុចំនួន ២០នាក់ ដោយមានបំណង គឺចង់កាប់ទាំងអស់ ប៉ុន្តែមានលិខិតពីតាជ័យ នឹងមានការស្តីបន្ទោសពីភូមិភាគមិនឲ្យសម្លាប់ប្រជាជន ទើបបានបញ្ជាឲ្យមន្ទីរ១៥ដោះស្រាយ។ នៅពេលស្ងាត់បាតុកម្ម បក្ខពួកខ្ញុំនាំកងទ័ពចូលខ្សែត្រៀមតាមមុខសញ្ញាចាស់។

បក្ខពួកខ្ញុំនៅកងពល ១២៤ គឺរាយការណ៍ឲ្យខ្ញុំទាំងអស់គ្នា ហើយខ្ញុំគឺជាអ្នកចាត់ចែងសម្រេចការងារនៅក្នុងកង។ ចំណែកការងារទាក់ទងវរមួយ ទៅកងវរមួយទៀតក្នុងតំបន់ គឺមានតែខ្ញុំនិង សារ៉េត ទេទើបចេញទាក់ទងកងដទៃបាន ហើយបានទាក់ទងធ្វើការកិច្ចប្តូរយោបល់គ្នា និងសម្រេចការងារនៅក្នុងសមរភូមិ។ ចុងឆ្នាំ១៩៧៣ អង្គការរៀបចំកង ២វរសេនាតូចទៀត គឺកងវរសេនាតូច១២៧ និងកងវរសេនាតូច ១៣១ ។

នៅខែមេសា ឆ្នាំ១៩៧៤ ភូមិភាគដកកងយោធាទាំងអស់របស់តំបន់ រៀបចំជារបស់ភូមិភាគ។ ខ្ញុំនិង សៅ ស៊ិន ត្រូវមកខាងក្រោយដើម្បីកសាងយោធាក្នុងតំបន់ឡើងវិញ។ ចាប់តាំងពីខែមេសា ឆ្នាំ១៩៧៤ មក ខ្ញុំមានតួនាទីជាសមាជិកគណៈស្រុកកៀនស្វាយ ទទួលខាងយោធា, សៅ ស៊ិន មាននាទីជាសមាជិក គណៈស្រុកកោះធំទទួលខាងយោធា។ នៅខែមិថុនា ឆ្នាំ១៩៧៤ តាជ័យ បើកការប្រជុំមួយនៅកន្លែង តាផ្លុង គឺមន្ទីរស្រុកស្អាង ហើយបក្ខពួករបស់ខ្ញុំចូលរួមមានឈ្មោះ តាចំរើន, ហួតសេង, ខ្ញុំ, តាផ្លុង, សៅ ស៊ិត, រៀល លិញ, សុផៃ គឺជាប្រធានយោធា, ទ្រង់ និងផន។ តាជ័យ លើកឡើងអំពីផែនការ និងការទាក់ទងបក្ខពួក។ ផែនការយើងធ្វើឲ្យប្រជាជនដាច់បាយ អត់អំបិល, បំផុសឲ្យប្រជាជនក្តៅក្រហាយជាមួយបដិវត្តន៍, បំផ្លាញផលដំណាំប្រជាជនស្របតាមច្បាប់, ខិតខំកសាងកម្លាំងក្បត់បង្កប់ក្នុងបដិវត្តន៍។ នៅខែតុលា ឆ្នាំ១៩៧៣ តំបន់និងភូមិភាគ ដកតាផ្លុង ពីស្រុកស្អាងឲ្យទទួលពាណិជ្ជ-កម្មតំបន់ឲ្យទទួលថែរក្សាដំណាំរដ្ឋក្នុងតំបន់, ដក សុផៃ ពីស្រុកលើកដែកមកសិប្បកម្មតំបន់និងដកខាងស្រុកកៀនស្វាយ ហើយដាក់ខ្ញុំជាលេខាស្រុកកៀនស្វាយ ចាប់ពីពេលនោះមក។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៤ តាជ័យ ទៅជួបខ្ញុំនិងណែនាំខ្ញុំបន្ថែមលើផែនការទៅថ្ងៃមុខ ហើយឧទ្ទេសនាម ខ្ញុំឲ្យគ្រប់គ្រងកម្លាំង ហួតសេ (អង្គការចាប់) ឲ្យជាប់រួមជាមួយមនុស្សចំនួន៥នាក់ទៀត គឺ សុខ ស្រ៊ុន គឺជាប្រធានឃុំប្រាសាក់, ខាត់ណា ហៅ ខាត់ គឺជាប្រធានកសិដ្ឋានស្រុក, ម៉ែង គឺជាប្រធានភូមិតាយោ នៅកសិដ្ឋានស្រុកកៀនស្វាយ, ចៃ គឺជាសមាជិកភូមិតាយោ កសិដ្ឋានស្រុកកៀនស្វាយ, ជួរ គឺជាគណៈជម្រៀសប្រជាជន។

នៅខែមករា ឆ្នាំ១៩៧៥ តាជ័យ ហៅបក្ខពួកខ្ញុំទៅប្រជុំនៅមន្ទីរ១៥ ដើម្បីរៀបចំផែនការសម្រាប់ឆ្នាំ១៩៧៥។ បក្ខពួកខ្ញុំចូលរួមប្រជុំរួមមាន ខ្ញុំ, រៀល លិញ, សៅ ស៊ិត, ហេង, តេង, តាសេ និង គ្រូសុខ។ តាជ័យ ណែនាំយើងអំពីផែនការឆ្នាំ១៩៧៥ មុនពេលរំដោះ។ តាជ័យ បានបញ្ជាក់ថាអង្គការដកគាត់មកក្រុង ដូច្នេះត្រូវបង ជា ទទួលនាទីជាលេខាតំបន់ ២៥ ។ ប្រហែលជាខែសីហា តាជ័យ មកជួបខ្ញុំប្រាប់ថា គាត់ត្រូវទៅខាងកសិកម្មរដ្ឋហើយគាត់សុំដីខ្ញុំចំនួន ១០០ហិកតា។ ខ្ញុំឲ្យតាជ័យ ស្នើពីបងជា ហើយចាប់តាំងពីពេលនោះមក ខ្ញុំទាក់ទងជួប តាជ័យ ញឹកញាប់។ សកម្មភាពរបស់យើងក្រោយរំដោះឆ្នាំ១៩៧៥ គឺខ្ញុំធ្វើសកម្មភាពវាយប្រហារឥទ្ធិពលបដិវត្តន៍ ដោយ

ពេលនោះខ្ញុំណែនាំឲ្យឈ្លបស្រុកមាន សារឿន គឺជាអ្នកដឹកនាំឲ្យប្រជាជនជម្លៀសចុះទៅក្រោម សម្លុតប្រជាជនណាដែលមិនព្រមចុះទៅក្រោម ដកយកអាវុធភ្លង់ពីក្រោយៗ នៅពាក់កណ្តាលខែធ្នូ ឆ្នាំ១៩៧៥ បងជាឲ្យខ្ញុំមកជួបគាត់នៅមន្ទីរតំបន់ហើយប្រាប់ខ្ញុំថា អង្គការភូមិភាគសម្រេចដកខ្ញុំមកស្រុកកណ្តាលស្ទឹង ជំនួសបង អាន ព្រោះបង អាន ត្រូវផ្លាស់ទៅកំពត។ នៅថ្ងៃបន្ទាប់ គាត់ឲ្យខ្ញុំទៅដល់កន្លែងតា អាន ដើម្បីក្តាប់ការងារមួយរយៈទើបឲ្យតា អាន ចេញទៅ។ ស្អែកឡើងខ្ញុំជួបតាជ័យ នៅអង្គរជ័យជម្រាបគាត់អំពីរឿងខ្ញុំត្រូវមកស្រុកកណ្តាលស្ទឹង។ ខ្ញុំនៅជាមួយតាអានរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ តំបន់បានប្រកាសចាត់តាំងខ្ញុំហើយ តាអាន ក៏ទៅកំពត។

នៅឆ្នាំ១៩៧៦ ពេលប្រជុំសភាតំណាងប្រជាជន ខ្ញុំបានជួប តាជ័យ ព្រោះ តាជ័យប្រជុំក្នុងនេះដែរ។ ប៉ុន្តែមិននិយាយអ៊ីទេព្រោះមានមនុស្សច្រើនពេលអង្គុយចាំឡានទៅ ហូបបាយនៅបុរីកីឡា។ ពេលនោះ តាជ័យមកអង្គុយជិតខ្ញុំហើយសួរអំពីរឿងស្រូវអង្គរ។ រយៈពេល៥ថ្ងៃក្រោយមក តាជ័យ ឲ្យឈ្មោះ ឆាយ គឺជានីសាររបស់គាត់មកទាក់ទងខ្ញុំ ខ្ញុំក៏បានរាយការណ៍ឲ្យ តាជ័យ តាមរយៈនីសាររបស់គាត់ ហើយបានផ្តល់ស្ករចំនួនជាង១០ពាងឲ្យទៅ ឆាយ ដឹកមកកន្លែង តាជ័យ នៅភ្នំពេញ។ នៅខែមិថុនា ឆ្នាំ១៩៧៦ តាជ័យ មកជួបនៅកន្លែងរបស់ខ្ញុំ ហើយគាត់បានឲ្យខ្ញុំខិតខំកសាងកម្លាំងដដែល ហើយតាជ័យ បានចាត់ឲ្យក្រុមគាត់យកម៉ាស៊ីនបូមទឹកឲ្យប្រជាជន។ ចាប់តាំងពីពេលនោះមកខ្ញុំដាច់ការទាក់ទងជាមួយតាជ័យ។ ក្រោយមកខ្ញុំស្តាប់វិទ្យុថា តាជ័យទៅទស្សនកិច្ចនៅបរទេស ក៏បាត់គាត់រហូតដល់ឥឡូវទើបខ្ញុំដឹងថា អង្គការចាប់ខ្លួនគាត់។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៦ ជីវភាពប្រជាជនកំពុងខ្វះខាតស្រូវ។ នៅពេលនោះ មានស្រូវទុំដែរប៉ុន្តែតាអោក និងសនមិនឲ្យប្រជាជនប្រូតហូប ដោយលើកឡើងថាស្រូវនៅខ្ចី។

នៅខែមីនាឆ្នាំ១៩៧៧ រៀល លិញ, និងសៅ ស៊ិត ទៅជួបខ្ញុំហើយដឹកត្រីនិងបន្លែឲ្យខ្ញុំ ហើយអ្នកទាំងនោះក៏បានសួរយោបល់ខ្ញុំដែរ។ ខ្ញុំប្រាប់ថា តាមការណែនាំពីតាជ័យ បើដាច់ទាក់ទងគ្នារយៈពេល១ ឬឆ្នាំ២ឆ្នាំ ក៏ដោយឲ្យតែនៅមានសកម្មភាពត្រូវធ្វើសកម្មភាពជាក់ស្តែងទៅមុខទៀត ដូច្នេះខ្ញុំនៅតែបន្តផែនការនេះ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៦មុនពេលចាប់ខ្លួន ខ្ញុំ និងបក្ខពួក បានបំផ្លាញផែនការស្រូវប្រាំងរហូតមិនបានផល ម្យ៉ាងទៀតមិនរៀបចំរាយកណ្តុរ មិនដោះស្រាយបញ្ហាអត់ទឹកឲ្យស្រូវស្កកនិងកណ្តុរស៊ីស្រូវអស់ចំនួន៥០ហិកតា រហូតដល់អង្គការចាប់ខ្លួនខ្ញុំ។

*កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ00២៥២។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ហ៊ីង គ្រុយ ពិតប្រាកដយ៉ាងណានោះទេ?*



កងចល័តកំពុងលើកភ្លឺស្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កូប ហ្វាទីម៉ះ ៖ របបខ្មែរក្រហមធ្វើឱ្យខ្ញុំក្លាយជាកូនកំព្រា និងជាស្ត្រីមេម៉ាយ

***មីន សាណាស់***




*កូប ហ្វាទីម៉ះ នៅផ្ទះរបស់គាត់ស្ថិតនៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម កាលពីខែកក្កដា ឆ្នាំ២០២២។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

«ខ្ញុំមិនបោលកីតម្បាញសូត្រទេ ព្រោះនេះជាការងារដែលខ្ញុំស្រឡាញ់ ចូលចិត្តតាំងពីអាយុ ១៣ឆ្នាំ ហើយវាជាផ្នែកមួយដែលខ្ញុំអាចរកប្រាក់ឲ្យកូនខ្ញុំរៀនសូត្រក្លាយជាគ្រូពេទ្យមួយរូបនៅក្នុងភូមិ» នេះគឺជាការលើកឡើងរបស់ស្ត្រីជនជាតិចាមម្នាក់។ គាត់រៀបរាប់បន្តថា «ខ្ញុំឈ្មោះ កូប ហ្វាទីម៉ះ ភេទស្រី អាយុ ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ហើយបច្ចុប្បន្នរស់នៅក្នុងឃុំដដែល។ សព្វថ្ងៃខ្ញុំប្រកបមុខរបរត្បាញសំពត់សូត្រដូចម្តាយរបស់ខ្ញុំដែរ។ ឪពុកខ្ញុំឈ្មោះ កូប គឺជាអ្នកនេសាទត្រី។ ឪពុកម្តាយរបស់ខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហម ដោយសារការអត់ឃ្លាន។

ខ្ញុំរៀបការជាមួយប្តីឈ្មោះ អះម៉ាត់ ប្រហែលជាឆ្នាំ១៩៧៣ ហើយកាលនោះខ្ញុំគឺជាកូនក្រមុំស្លៀកសំពត់សូត្រគោមផ្កាកន្ទេល ពណ៌បៃតងយ៉ាងស្រស់ស្អាត។ នៅឆ្នាំ១៩៧៤ ខ្ញុំសម្រាលបានកូនប្រុសម្នាក់។ នៅឆ្នាំ១៩៧៥ កូនរបស់ខ្ញុំទើបតែចេះវារ ខ្មែរក្រហមក៏ជម្លៀសគ្រួសារខ្ញុំ និងអ្នកភូមិឯទៀត តាមរថភ្លើង

ទៅកាន់ខេត្តបាត់ដំបង។ គ្រួសារខ្ញុំចុះនៅចំណុចភូមិក្បាលថ្នល់ ស្រុកសង្កែ ខេត្តបាត់ដំបង។ មូលហេតុដែលនាំឲ្យមានការជម្លៀស គឺយោធាខ្មែរក្រហមប្រាប់ថា នាំអ្នកភូមិឲ្យទៅរស់នៅប្រទេសម៉ាឡេស៊ី ទើបអ្នកទាំងអស់គ្នាចាកចេញពីភូមិ។ រថភ្លើងបរមកដល់ខេត្តបាត់ដំបងភ្លាម កម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យប្រជាជនចុះធ្វើស្រែ និងដកស្ទូង។ ចំណែកប្តីខ្ញុំត្រូវចុះទៅភ្ជួរស្រែ។ ក្រោយមកមិនទាន់បានមួយឆ្នាំ ស្រាប់តែឪពុកម្តាយខ្ញុំធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារការអត់ឃ្លាន។ មួយខែក្រោយមកទៀត ប្តីខ្ញុំដួលសន្លប់បាត់ស្មារតីបន្ទាប់ពីត្រឡប់មកពីភ្ជួរស្រែ រួចបញ្ជូនទៅពេទ្យស្រុក។ ពេទ្យបានចាក់ថ្នាំមួយម្ជុលឲ្យគាត់ ហើយគាត់ក៏ស្លាប់ទៅ។ ខ្ញុំគិតថាពេទ្យមានចេតនាចាក់ថ្នាំសម្លាប់ប្តីខ្ញុំ ឬម៉្យាងទៀត មកពីពេទ្យទាំងនោះមិនមានចំណេះដឹងច្បាស់លាស់។ ការបាត់បង់ឪពុកម្តាយ និងប្តីរបស់ខ្ញុំមិនធ្វើឲ្យខ្ញុំខូចចិត្តឬយំសោកតទៀតឡើយ ព្រោះខ្ញុំគិតថា ពួកគាត់បានសុខហើយ ពួកគាត់លែងវេទនា និងរស់នៅក្នុងរបបដល់ខ្មៅងងឹតទាំងអត់ឃ្លានដូចខ្ញុំឡើយ។ ខ្ញុំត្រូវប្រឹងរស់ ដើម្បីមើលថែកូនប្រុស និងប្អូនៗ។ ពេលថ្ងៃខ្ញុំប្រឹងធ្វើការ ពេលយប់ខ្ញុំចេញទៅលួចស្រូវ និងពោតមកស្ងោរឲ្យកូននិងប្អូនៗហូប។ ពេលខ្លះខ្ញុំលួចបាន ពេលខ្លះក៏លួចមិនបាន។ របបខ្មែរក្រហមធ្វើឲ្យខ្ញុំក្លាយជាកូនកំព្រា និងជាស្ត្រីមេម៉ាយមកដល់សព្វថ្ងៃ។

នៅដើមឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលមក និងបានឮសំឡេងបំផ្ទុះគ្រាប់បែក។ ពេលនោះខ្ញុំនិងប្រជាជនឯទៀតកំពុងទូលកណ្តាប់ស្រូវយកទៅដាក់នៅទីលានបោកបែនធម្មតា ប៉ុន្តែកងកម្លាំងវៀតណាមដេញឲ្យអ្នកភូមិនិងខ្ញុំនាំគ្នារត់ចូលទៅក្នុងទីរួមខេត្តបាត់ដំបងវិញ។ ការធ្វើដំណើរទៅទីក្រុងបាត់ដំបង គ្រួសារខ្ញុំលំបាកជាងអ្នកផ្សេងទៀត ដោយសារប្អូនប្រុសខ្ញុំម្នាក់ស្វិតជើង ហេតុនេះ ពិបាកក្នុងការធ្វើដំណើរ។ ដើម្បីឲ្យទាន់គ្រួសារឯទៀត ខ្ញុំមានតែឲ្យប្អូនចុះទៅក្នុងប្រឡាយស្របជាមួយផ្លូវ រួចហែលរហូតទាល់តែមានរទេះគោណាដែលខ្ញុំអាចសុំឲ្យប្អូនខ្ញុំជិះជាមួយបាន។ ខ្ញុំអាណិតប្អូនខ្ញុំណាស់ ប៉ុន្តែមិនអាចជួយគាត់បាន ព្រោះខ្ញុំគ្មានកម្លាំងសែង។ មកដល់ទីរួមក្រុងបាត់ដំបង ខ្ញុំរៀបចំកន្លែងស្នាក់នៅ ហើយបានជួបបងប្អូន និងពូមីងមួយចំនួន។ នៅពេលរស់នៅជុំគ្នាក្នុងក្រុងបាត់ដំបង យើងទទួលដំណឹងថា ជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ អាចបញ្ជូនជនភៀសខ្លួនខ្មែរឲ្យទៅកាន់ប្រទេសអាមេរិក ម៉ាឡេស៊ី និងអូស្ត្រាលី។ គ្រួសារខ្ញុំនិងអ្នកភូមិផ្សេងទៀតបានធ្វើដំណើរបន្តទៅកាន់ជំរំដែលមានឈ្មោះថា ណងចាន់។ នៅជំរំណងចាន់ ខ្ញុំបានទទួលរបបអាហារបរិភោគគ្រប់គ្រាន់ ហើយរស់នៅក្នុងជំរំបានរយៈពេលកន្លះខែ។ ប៉ុន្តែក្រោយមក ខាងប្រទេសថៃដឹកយើងមកបោលនៅលើភ្នំដងរែក។ បន្ទាប់ពីរួចជីវិតពីភ្នំដងរែក គ្រួសារខ្ញុំធ្វើដំណើរដោយថ្មើរជើងរយៈពេលជាងមួយខែទម្រាំបានមកដល់ស្រុកកំណើត។ ពេលមកដល់ស្រុកកំណើតខ្ញុំចាប់ផ្តើមយកចំណេះដឹងពីម្តាយរបស់ខ្ញុំមកប្រើប្រាស់ ដោយដំបូងខ្ញុំដើរទៅសុំចិននៅផ្សារដើម្បីស៊ីឈ្នួលចាក់មងទាំងថ្ងៃទាំងយប់ ព្រោះខ្ញុំចង់សន្សំលុយទុកសង់ផ្ទះ និងទិញសម្ភារផ្សេងៗ។

ប្រហែលឆ្នាំ១៩៨៦ បងប្អូនខ្មែរនៅខាងក្រៅជួលខ្ញុំឲ្យត្បាញសំពត់សូត្រ ព្រមទាំងផ្តល់ជាគ្រឿងតម្បាញទាំងស្រុង។ ខ្ញុំសម្រេចចិត្តត្បាញឡើងវិញ ព្រោះវាជាការងារដែលខ្ញុំស្រឡាញ់តាំងពីអាយុ១៣ឆ្នាំ។ ខ្ញុំចាប់ផ្តើមចងគោមដែលខ្ញុំស្រឡាញ់ពីមុន ដូចជា គោកផ្កាកន្ទេល គោមជណ្តើរបារាំង គោមក្បោកសម័យ គោមដបតែ គោមសំពោង និងគោមខុងមិញជាដើម។ សម្រាប់ការជ្រលក់ពណ៌ គឺមានតែ ពណ៌លឿង ខ្មៅ ក្រហម បៃតង និង ខៀវ។ ពណ៌បៃតង និង ខៀវ គឺពេញនិយមណាស់ចំពោះកូនក្រមុំថ្ងៃរៀបការ។ ខ្ញុំត្បាញសព្វថ្ងៃនេះ គឺដើម្បីជាការថែរក្សាប្រពៃណី ចំណេះជំនាញដែលដូនតាបន្សល់ទុក។ ខ្ញុំត្បាញក៏ចាត់ទុកជាចលនាហាត់ប្រាណមួយដែរ។ ខ្ញុំសង្ឃឹមថា ទីផ្សារសូត្រ និងងើបឡើងវិញ បន្ទាប់ពីជំងឺកូវីដ១៩បាត់ផុតរលត់ទៅ។

# ដួង ធីង ៖ ឈ្លបភូមិសម័យខ្មែរក្រហម

**គាត ស្រីឡែន**



រូបខាងស្តាំ ៖ ដួង ធីង អាយុ៨០ឆ្នាំ រស់នៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ សុខ វណ្ណៈ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ដួង ធីង អាយុ៨០ឆ្នាំ មានស្រុកកំណើតនៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ ខ្ញុំមានឪពុកឈ្មោះ ដួង ថង និង ម្តាយឈ្មោះ តួង ញឹក។ ខ្ញុំមានបងប្អូនចំនួន ៥ នាក់ គឺស្រីចំនួន២នាក់ និងប្រុសចំនួន៣នាក់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ មួត អឿន និងមានកូនចំនួន៥នាក់។ ខ្ញុំរស់នៅភូមិរំចេកតាំងតែពីដឹងក្តីមក។

កាលពីសម័យខ្មែរឥស្សរៈ ភូមិរំចេកមិនសូវមានមនុស្សរស់នៅច្រើនទេ។ ប្រជាជននៅក្នុងភូមិនេះមានប្រហែលជាង១០០នាក់ និងមានផ្ទះចំនួន ២០ ទៅ៣០ខ្នងប៉ុណ្ណោះ។ ភូមិនេះមានសុទ្ធតែព្រៃ និងដើមរំចេកដុះ ទ្រុបទ្រុលទើបចាស់ៗហៅថា ភូមិរំចេក និងជាប់ឈ្មោះនេះរហូតមកដល់សព្វថ្ងៃ។ នៅក្នុងសម័យនោះ ប្រសិនបើប្រជាជនត្រូវការទិញរបស់របរប្រើប្រាស់ត្រូវទៅទិញនៅស្រុកឆ្លូង ខេត្តក្រចេះ។ ពីសម័យឥស្សរៈ ឪពុកខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងដាំបន្លែ។ ប្រជាជនក្នុងភូមិស្រឡាញ់គ្នាណាស់ ហើយពេលដាំដុះបានផលដំណាំ ឬមានម្ហូបចំណី តែងតែយកមកចែកគ្នាហូប។

ពេលខ្ញុំនៅកុមារ ខ្ញុំបានរៀននៅសាលាវត្តរំចេកជាមួយព្រះសង្ឃ។ ក្រោយមកខ្ញុំឈប់រៀនដោយសារសង្គ្រាម និងមានបាតុកម្មប្រឆាំងនឹង លន់ នល់ ដែល

ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ខ្ញុំនិងអ្នកភូមិរំចេកមិនបានចូលរួមបាតុកម្មនេះទេ។

នៅចុងឆ្នាំ១៩៧០ ខ្ញុំបានរៀបការប្រពន្ធ។ កាលនោះមានយន្តហោះទម្លាក់គ្រាប់បែក ហោះកាត់ភូមិខ្ញុំជារឿយ ដូច្នេះខ្ញុំរៀបការផង ភ័យខ្លាចយន្តហោះទម្លាក់គ្រាប់ចំរោងការផង។ ក្រោយមក អ្នកដឹកនាំនៅក្នុងភូមិបានជ្រើសរើសយុវជនឲ្យចូលធ្វើកងទ័ព។ ដោយសារខ្ញុំមានប្រពន្ធ ដូច្នេះខ្ញុំក៏រួចខ្លួន ប៉ុន្តែប្អូនខ្ញុំ២នាក់ត្រូវបានជ្រើសឲ្យចូលកងទ័ព។

នៅឆ្នាំ១៩៧១ មានការទម្លាក់គ្រាប់បែកឆេះផ្ទះប្រជាជននៅក្នុងភូមិរំចេកអស់២ខ្នង ដោយសារ មានកងទ័ពវៀតកុង ឬ វៀតណាមខាងជើងចូលមកក្នុងភូមិ។ ពេលនោះខ្ញុំមិនហ៊ានរត់ចូលព្រៃទេ ព្រោះខ្លាចទាហានអាមេរិកច្រឡំជាកងទ័ពវៀតកុង (វៀតណាមខាងជើង) ដូច្នេះខ្ញុំបានរត់ចូលរណ្តៅត្រង់សេឬលេណដ្ឋានដើម្បីលាក់ខ្លួន។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកក្នុងភូមិរួចហើយប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជនដាក់រួមឲ្យធ្វើស្រែប្រវាស់ដៃ និងបង្កើតសហករណ៍។ មួយរយៈក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជន១៧ មេសា មករស់នៅតាមផ្ទះអ្នកភូមិមូលដ្ឋានចាស់ ហើយប្រជាជន១៧ មេសាខ្លះទៀតស្នាក់នៅវត្ត។ ពេលនោះ ខ្មែរក្រហមចាត់តាំងខ្ញុំធ្វើឈ្លបភូមិ និងដឹកនាំប្រជាជន១៧មេសា ឬប្រជាជនថ្មី សង់ផ្ទះថ្មី និងដឹកនាំប្រជាជនថ្មីទាំងនោះឲ្យធ្វើចម្ការ និងដឹករបស់របរតាមរទេះគោយកទៅចែកឲ្យតាមក្រុម និងតាមកង។ តំបន់ដែលខ្ញុំធ្វើការគឺតំបន់២១ ដែលមានប្រធានភូមិភាគបូព៌ាឈ្មោះ សោ ភឹម។

ក្រោយមកមានកម្មាភិបាល និងកងទ័ពមកពីភូមិភាគនិរតីបានចូលមកប្រាប់ថា ខាងបូព៌ាក្បត់ក្បាលយួនខ្លួនខ្មែរ។ កម្មាភិបាលនិងកងទ័ពមកពីនិរតី បានចាប់ប្រធានកង និងឈ្លប៣នាក់ រួមទាំងខ្ញុំចងរួបបណ្តើរទៅដាក់នៅក្នុងរោងបាយ។ ពេលនោះអតីតប្រធានឈ្លបឈ្មោះ មេន បានលួចស្រាយចំណងនិងដោះខ្នោះខ្លួនឯងបានរួចហើយមកជួយស្រាយចំណងឲ្យខ្ញុំ និងឈ្លបដែលជាប់ចំណងម្នាក់ទៀត។ យើងនាំគ្នារត់នៅពេលអ្នកយាមដេកលក់។ មេន, ខ្ញុំ និងឈ្លបម្នាក់ទៀត បែកទិសដៅគ្នារត់ជាបីមុខព្រួញ។ បន្ទាប់មក ខ្ញុំបានរត់ទៅនៅស្រុកកំណើតខាងប្រពន្ធរបស់ខ្ញុំ ចំណែក មេន និងឈ្លបម្នាក់នោះ បានស្លាប់ នៅក្នុង១៩៧៨។ ក្រោយពេលទៅដល់ស្រុកកំណើតរបស់ប្រពន្ធខ្ញុំបានមួយរយៈ កងទ័ពខ្មែរក្រហមបានមកតាមរកខ្ញុំ ប៉ុន្តែក្រុមគ្រួសារខាងប្រពន្ធខ្ញុំបានជួយលាក់បាំងអត្តសញ្ញាណឲ្យខ្ញុំ។ ក្រោយមក ខ្ញុំបានគេចខ្លួនទៅរស់នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ បន្ទាប់ពីកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជានៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងប្រពន្ធកូនបានត្រឡប់មករស់នៅភូមិរំចេក និងប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



ផ្លូវលំនៅខាងមុខផ្ទះរបស់ ដួង ធីង ស្ថិតនៅក្នុងភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ៅ វណ្ណា ៖ ខ្ញុំនៅចាំពាក្យសម្តីរបស់មិត្ត ជាច និយាយមុនពេលខ្មែរក្រហមនាំគាត់ទៅសម្លាប់ថា «ខ្មែរក្រហមមិនដែលសាហាវជាងហ៊ីត្លែរនោះទេ»

*ស៊ាង ចិន្តា*



ម៉ៅ វណ្ណា អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ម៉ៅ វណ្ណា ភេទស្រី អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ សុខ ង៉ុយ និងមានកូនប្រុសស្រីចំនួន៣នាក់។ ខ្ញុំគឺជាអតីតនាយកសាលាបឋមសិក្សាទីប្រជុំ ដែលស្ថិតនៅភូមិទី៨នេះ។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ លាងគ្រី ដែលជាគ្រូបង្រៀននៅវិទ្យាល័យជម្ពូវ័ន និងម្តាយឈ្មោះ ម៉ៅ សុផល គឺជាមេផ្ទះ។ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ គឺនៅសល់តែរូបខ្ញុំនិងប្អូនម្នាក់ប៉ុណ្ណោះដែលរួចរស់ជីវិត។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាចុងកោះរហូតដល់ថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំស្នាក់នៅជាមួយយាយនៅក្នុងភូមិកំណើតចំណែកឯឪពុកម្តាយ និងបងប្អូនផ្សេងទៀតរបស់ខ្ញុំរស់នៅ ទីក្រុងភ្នំពេញ។ ប៉ុន្មានខែបន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មានអ្នកភូមិបានទៅចូលរួមដង្ហែរបាតុកម្មប្រឆាំងនឹងរដ្ឋប្រហារនេះនៅទីរួមខេត្តកំពង់ចាម។ ខ្ញុំមិនបានទៅចូលរួមទេគឺខ្ញុំស្នាក់នៅផ្ទះជាមួយយាយរបស់ខ្ញុំ។ ក្រោយមកទៀត កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ និងបានស្នាក់

នៅក្រោមផ្ទះរបស់អ្នកភូមិទី៨។ នៅចុងឆ្នាំ១៩៧០ និងដើមឆ្នាំ១៩៧១ សង្គ្រាមរវាង ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅស្រុកកោះសូទិន។ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ទាហាន លន់ នល់ បានបើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហម ដែលឈរជើងនៅក្នុងស្រុកកោះសូទិនកាន់តែខ្លាំងឡើងៗ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំ ឪពុកម្តាយរបស់ខ្ញុំបានមកយកខ្ញុំទៅរស់នៅជាមួយពួកគាត់នៅជាយក្រុងក្រុងភ្នំពេញវិញ។ ខ្ញុំបានចូលរៀនបន្តនៅសាលាបឋមសិក្សាជម្ពូវ័ន រហូតដល់ថ្នាក់ទី៨ នៅវិទ្យាល័យជម្ពូវ័នដដែល។

នៅដើមឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានទទួលដំណឹងថាកងទ័ពខ្មែរក្រហមបានចូលមកកៀកទីក្រុងភ្នំពេញហើយ។ នៅពេលនោះ ឪពុករបស់ខ្ញុំបានប្រាប់ម្តាយខ្ញុំឲ្យនាំកូនៗចូលក្នុងក្រុងភ្នំពេញ និងទៅស្នាក់នៅផ្ទះម្តុំទួលស្វាយព្រៃបណ្តោះអាសន្ន។ ចំណែកឯឪពុករបស់ខ្ញុំជិះកង់មកតាមក្រោយ។ បន្ទាប់ពីស្នាក់នៅមិនបានប៉ុន្មានផង ទីក្រុងភ្នំពេញត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយបែក និងគ្រប់គ្រង។ គ្រួសាររបស់ខ្ញុំ គឺស្ថិតនៅក្នុងចំណោមគ្រួសាររាប់ពាន់ផ្សេងទៀត ដែលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ឪពុកម្តាយរបស់ខ្ញុំសម្រេចចិត្តនាំកូនៗត្រឡប់មកភូមិកំណើតនៅកោះសូទិន ដើម្បីរស់នៅជាមួយយាយរបស់ខ្ញុំវិញ។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរជាច្រើនថ្ងៃទើបមកដល់ភូមិ។

បន្ទាប់ពីមកដល់ភូមិវិញ គ្រួសាររបស់ខ្ញុំត្រូវបានប្រជាជនមូលដ្ឋានហៅថាប្រជាជន១៧មេសា ព្រោះមានប្រវត្តិរូបធ្លាប់ធ្វើជាគ្រូបង្រៀននៅក្នុងរបបចាស់។ បន្ទាប់មក ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានភូមិតាណុង គឺជាកន្លែងប្រមូលផ្តុំប្រជាជនដែលជាប់និន្នាការជាមួយរបបលន់នល់ ដើម្បីលត់ដំខ្លួន។ នៅពេលនោះ ខ្ញុំមិនបានទៅនៅជាមួយឪពុកម្តាយ និងបងប្អូនទេ ពីព្រោះយាយរបស់ខ្ញុំបានប្រាប់មេភូមិថា ខ្ញុំគឺជាអ្នកមូលដ្ឋានចាស់។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅក្នុងកងចល័តនារី គឺធ្វើស្រែ ជីកដី និងលើកទំនប់។ នៅឆ្នាំ១៩៧៧ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ទីកន្លែងធ្វើការទៅការដ្ឋានឆ្នូត្រវិញ ដែលនៅទីកន្លែងនោះខ្ញុំស្ទើរតែត្រូវបានចាប់យកទៅសម្លាប់ និងជាកន្លែងដែលខ្ញុំឃើញផ្ទាល់ភ្នែកពីទុក្ខវេទនារបស់គ្រួសារខ្ញុំ។ ខ្ញុំតែងតែលួចទៅជួបឪពុកម្តាយរបស់ខ្ញុំក្នុងស្ថានភាពស្គមស្គាំង និងភិតភ័យ។ ខ្ញុំបានត្រឹមតែសួរសុខទុក្ខ និងមិនអាចធ្វើអ្វីបានលើសពីនេះទេ។ ចំណែកឯកងចល័តនារីរបស់ខ្ញុំវិញ ត្រូវទៅជីកដី លើកដី និងធ្វើស្រែគ្មានពេលសម្រាក និងគ្មានអាហារហូបគ្រប់គ្រាន់។ កងចល័តនារីកន្លែងខ្ញុំធ្វើការ មានសមាជិកមិត្តនារីទាំងអស់៩៧នាក់។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកដល់ និងចាប់ផ្តើមចាប់កម្មាភិបាលមូលដ្ឋាន និងប្រធានកងយកទៅសម្លាប់ចោល។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីក៏ចាប់ផ្តើមស្រាវជ្រាវប្រវត្តិប្រជាជន១៧មេសា។ នៅពេលនោះ កងចល័តនារីនៅសេសសល់ប្រហែល ៦០នាក់ប៉ុណ្ណោះ។

នៅយប់មួយ ប្រធានកងចល័តនារីឈ្មោះ ស្រ៊ាង បានដើរស្រង់ឈ្មោះអ្នកដែលមានប្រវត្តិជាប្រជាជន ១៧ មេសា។ ខ្ញុំដឹងថា ប្រជាជន១៧មេសា នៅពេលនោះគឺត្រូវបានស្រង់ឈ្មោះបានចំនួន ១៣នាក់ រួមទាំងឈ្មោះរបស់ខ្ញុំផងដែរ។ ប៉ុន្តែមិត្តនារី ស្រ៊ាង ដែលជាអតីតមិត្តរៀនថ្នាក់ទី១១ នៅសាលាបឋមសិក្សាចុងកោះជាមួយគ្នា ស្គាល់ខ្ញុំ និងមិនបានហៅខ្ញុំដើម្បីរៀបចំបាយពោតដើម្បីយកទៅសម្លាប់ចោលនោះទេ។ ចំណែកឯអ្នក១២នាក់ផ្សេងទៀតត្រូវបានមិត្តនារី ស្រ៊ាង ប្រាប់ឲ្យរៀបចំបាយពោត និងហៅទៅតាមគាត់។ នៅយប់ដដែល ប្រជាជន ១៧ មេសា បានងើបអង្គុយ និងពិភាក្សាគ្នាអំពីការរៀបចំបាយ និងការផ្លាស់ទៅកន្លែងផ្សេងទៀត។ នៅពេលនោះ មិត្តថាច ដែលរៀនបានខ្ពង់ខ្ពស់ និងចប់ថ្នាក់មហាវិទ្យាល័យ និយាយទៅកាន់អ្នកទាំងអស់គ្នាថា «កុំទៅបារម្ភពេក ខ្មែរក្រហមមិនដែលសាហាវដាង ហ៊ីតែ្លរ

នោះទេ»។ ការលើកឡើងរបស់មិត្ត ផាច នៅពេលនោះ គឺគាត់មិនជឿថា ខ្មែរក្រហម សម្លាប់ខ្មែរនោះទេ។ ប៉ុន្តែអ្វីដែលមិត្ត ផាច និយាយនោះគ្រាន់តែជាការយល់ខុស។ ខ្មែរក្រហមបានបណ្តើរអ្នកទាំង ១២នាក់ ដែលត្រូវបានស្រង់ឈ្មោះ និងប្រាប់ឲ្យរៀបចំបាយ យកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃក្បែរការដ្ឋានដែលខ្ញុំ និងអ្នកផ្សេងទៀតកំពុងធ្វើការ។

នៅឆ្នាំ១៩៧៨ ខ្ញុំទទួលបានដំណឹងថា ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ និងទម្លាក់ចោលក្នុងទន្លេ ពីព្រោះតែជាប់ប្រវត្តិជាប្រជាជន១៧ មេសា។ បន្ទាប់ពីកងទ័ពវៀតណាមចូលមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំមិនបានរត់ទៅជាមួយខ្មែរក្រហមមកពីភូមិភាគនិរតីទេ។ ខ្ញុំបានវិលត្រឡប់មកភូមិទី៨វិញ ដើម្បីរស់នៅជាមួយយាយរបស់ខ្ញុំ និងប្អូនម្នាក់ដែលរួចផុតពីការសម្លាប់នៅពេលនោះ។ នៅឆ្នាំ១៩៨០ ខ្ញុំបានបង្រៀនកូនអ្នកភូមិនៅសាលាបឋមសិក្សាទីប្រជុំ និងក្រោយមកទៀតទទួលតួនាទីជានាយកសាលា។ បន្ទាប់ពីខ្ញុំចូលនិវត្តន៍ ខ្ញុំលក់នំនិងអាហារនៅក្នុងសាលា និងបន្តបង្រៀនកូនអ្នកភូមិក្នុងតួនាទីជាគ្រូកិច្ចសន្យា។




សិស្សសាលានៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ជិះទូកដទៅសាលារៀន។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សសាលានៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម ជិះកង់ត្រឡប់ទៅផ្ទះ។
(ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# យ៉ាន់ យួន ៖ កងសែងយុទ្ធជនខ្មែរក្រហមដែលរងរបួស

ភា រស្មី



យាន់ យួន អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យាន់ យួន ភេទស្រី អាយុ៦៧ឆ្នាំ បានរៀបរាប់ថា ខ្ញុំកើតនៅភូមិស្វាយយា ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ខ្ញុំមានឪពុកឈ្មោះ សៅ យាន់ និងម្តាយឈ្មោះ ងួន ដាង ព្រមទាំងមានបងប្អូន៩នាក់ ក្នុងនោះប្រុស២នាក់។ នៅអាយុ១៣ឆ្នាំ ខ្ញុំបានចូលរៀនថ្នាក់អក្ខរកម្មនៅវត្តស្វាយយា ជាមួយព្រះសង្ឃ។ បន្ទាប់ពីឈប់រៀន ខ្ញុំបានជួយឃ្វាលគោក្របី និងធ្វើស្រែចម្ការឪពុកម្តាយរបស់ខ្ញុំ។ នៅឆ្នាំ១៩៧១ ពេលខ្ញុំអាយុ១៧ឆ្នាំ ខ្ញុំបានរៀបការជាមួយប្តីឈ្មោះ មាស ហាត់ និងបានផ្លាស់ទៅរស់នៅជាមួយប្តីនៅភូមិអង្គ្រង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែងវិញ។ ប្តីរបស់ខ្ញុំកាលនោះធ្វើជាសេនាជននៅក្នុងភូមិអង្គ្រង ហើយពេលទំនេរគាត់ធ្វើស្រែចម្ការដើម្បីចិញ្ចឹមគ្រួសារ។

នៅចុងឆ្នាំ១៩៧២ ខ្ញុំបានសម្រាលកូនទីមួយរបស់ខ្ញុំនៅផ្ទះ។ បន្ទាប់ពីឆ្លងទន្លេបានប្រមាណ ២ខែ ប្រធានភូមិបានស្នើសុំឲ្យក្រុមមីងៗទៅជួយសែងកងទ័ពរំដោះខ្មែរក្រហមរងរបួសនៅពេលឡើងទៅវាយជាមួយកងទ័ពរដ្ឋការ លន់ នល់ នៅសមរភូមិព្រៃទប់ និងស្ពានត្រាំក្នុងខេត្តស្វាយរៀងយកទៅព្យាបាលនៅមន្ទីរពេទ្យដែលមានទីតាំងស្ថិតនៅក្នុងវត្តបន្ទាយ។ ចន្លោះឆ្នាំ១៩៧២ដល់ឆ្នាំ១៩៧៣ មានការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកងទ័ពរដ្ឋការ ជាមួយកងទ័ពរំដោះខ្មែរក្រហម។ កាលនោះ ក្រុមសែងកងទ័ពរងរបួស

របស់ខ្ញុំមានគ្នា១០នាក់ ស្រីចំនួន៥នាក់ និងប្រុសចំនួន៥នាក់។ ក្រុមរបស់ខ្ញុំ បានទៅទទួលកងទ័ពរងរបួសពីភូមិសូ យកមកឲ្យប្រជាជននៅក្នុងភូមិក្ដីស្វា ដើម្បីសែងបន្តទៀត។ ការសែងអ្នករបួសនេះបញ្ចប់ទៅនៅត្រឹមឆ្នាំ១៩៧៤ ព្រោះកងទ័ព លន់ នល់ បានចាញ់សង្គ្រាមនៅខេត្តស្វាយរៀង។ ចាប់ពីឆ្នាំ១៩៧៤ នៅក្នុងភូមិអង្គ្រងចាប់ផ្ដើមធ្វើស្រែប្រវាស់ដៃ និងចាប់ផ្ដើមប្រមូលរបស់របរប្រជាជនដាក់ជារបស់រួម។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅក្នុងភ្នំពេញជាច្រើននាក់ត្រូវបានខ្មែរក្រហមជម្លៀសមករស់នៅក្នុងភូមិអង្គ្រង។ ប្រជាជន ១៧ មេសា មួយចំនួនដែលមានចំណេះដឹងត្រូវបានអង្គការយកទៅរៀនសូត្រ ហើយអ្នកដែលនៅសេសសល់មួយចំនួនត្រូវបានអង្គការតាមដានបន្តទៀត។ ខ្ញុំចាំបានថា ដំបូងអង្គការបានជ្រើសរើសប្រជាជនដែលទើបជម្លៀសមកពីទីក្រុងភ្នំពេញឲ្យបង្រៀនអក្សរដល់ប្រជាជននៅក្នុងភូមិ ទាំងចាស់ ទាំងក្មេង ហើយខ្ញុំក៏បានចូលរៀនដែរ។ សាលារៀននៅពេលនោះមាន៣កម្រិតគឺ ថ្នាក់រៀនសម្រាប់កុមារ គឺគ្រូបង្រៀននៅពេលព្រឹក, ថ្នាក់រៀនសម្រាប់យុវជន-យុវនារី គឺគ្រូបង្រៀននៅពេលថ្ងៃ និងថ្នាក់រៀនសម្រាប់មីងៗនិងពូៗ គឺគ្រូបង្រៀននៅពេលថ្ងៃដូចគ្នា។ ខ្ញុំរៀនបានប្រមាណ៣ទៅ៨ខែ អង្គការក៏បញ្ជូនលោកគ្រូអ្នកគ្រូទាំងអស់នោះទៅរៀនសូត្រអស់។ ខ្ញុំរៀនបណ្ដើរ និងធ្វើការងារបុកស្រូវបណ្ដើរដើម្បីយកអង្ករដាក់ក្នុងរោងបាយ ព្រោះនៅក្នុងភូមិអង្គ្រងប្រជាជនចាប់ផ្ដើមហូបបាយរួម។ ខ្ញុំត្រូវបុកស្រូវក្នុងមួយថ្ងៃឲ្យបាន ៥តៅ ដើម្បីយកអង្ករដាក់ក្នុងរោងបាយរួម។ អ្នកបុកស្រូវក្នុងរោងបាយរួមមួយមានសមាជិកចំនួន៣នាក់។ ខ្ញុំបានធ្វើការនេះរហូតដល់ខ្ញុំឆ្លងទន្លេកូនទី២របស់ខ្ញុំ នៅឆ្នាំ១៩៧៦។

បន្ទាប់ពីឆ្លងទន្លេរួច អង្គការបានអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកចំនួន១ខែ ដើម្បីឲ្យខ្ញុំមានសុខភាពរឹងមាំ មុនពេលចុះទៅច្រូតស្រូវបន្តនៅក្បែរៗភូមិ។ នៅពេលច្រូតស្រូវ ខ្ញុំអាចឡើងមកបំបៅដោះកូនរបស់ខ្ញុំបាននៅពេលដែលកូនរបស់ខ្ញុំឃ្លានខ្លាំង។ នៅពេលដែលផុតរដូវច្រូតកាត់ អង្គការបានឲ្យក្រុមមីងៗនិងខ្ញុំ ទៅដងទឹកយកមកស្រោចដំណាំរបស់ប្រជាជនដែលដាំនៅតាមផ្ទះ។

នៅចុងឆ្នាំ១៩៧៨ អង្គការបានកត់ឈ្មោះគ្រួសាររបស់ខ្ញុំដើម្បីជម្លៀសទៅខេត្តពោធិ៍សាត់ ប៉ុន្តែដោយសារតែខ្ញុំឈឺពោះឆ្លងទន្លេកូនទី៣ របស់ខ្ញុំ ទើបខ្ញុំសុំពន្យារពេលមួយរយៈ និងចាំទៅលើកក្រោយ។ ខ្ញុំឆ្លងទន្លេបានរយៈពេល២ខែ ស្រាប់តែអង្គការឲ្យប្រជាជនទាំងអស់ជម្លៀសទៅខេត្តភាគខាងលិច ហើយខ្ញុំនិងគ្រួសារបានធ្វើដំណើរទៅដល់ភ្នំឈើកាច់។

នៅដើមខែមករា ឆ្នាំ១៩៧៩ គ្រួសាររបស់ខ្ញុំបានត្រឡប់មកភូមិស្រុកវិញ និងបានប្រកបរបរធ្វើស្រែចម្ការបន្តទៀតដើម្បីចិញ្ចឹមជីវិត។ ក្រោយមកនៅឆ្នាំ២០១១ ប្ដីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺបេះដូង។ ខ្ញុំរស់នៅជាមួយកូនៗចំនួន៧ នាក់ ក្នុងនោះមានកូនស្រី១នាក់។ សព្វថ្ងៃ ខ្ញុំរស់នៅជាមួយកូនប្រុសពៅរបស់ខ្ញុំ ចំណែកកូនផ្សេងទៀតបានរៀបការ និងមានគ្រួសារបែកផ្ទះរៀងៗខ្លួនអស់ហើយ។



ផ្លូវលំក្នុងស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជា ខេងថៃ ៖ ប្រធានមន្ទីរពាណិជ្ជកម្ម តំបន់ ៤១ ក្នុងរបបខ្មែរក្រហម

ស៊ាង ចិន្តា

ខ្ញុំឈ្មោះ ជា ខេងថៃ អាយុ៧០ឆ្នាំ ជាកសិករ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំគឺជាគ្រូបង្រៀនចូលនិវត្តន៍កាលពីឆ្នាំ២០១១។ ខ្ញុំរៀបការប្រពន្ធឈ្មោះ យា ឆេងស៊ិន ដោយមានកូនចំនួន៤នាក់ (ស្រី៣ និងប្រុស១)។ ខ្ញុំកើតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ ខ្ញុំមានឪពុកឈ្មោះ ជា ម៉េត និងម្ដាយឈ្មោះ គា ណៃគីម។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន ៣នាក់ ។ នៅវ័យកុមារ ខ្ញុំទៅរៀននៅសាលាបឋមសិក្សាកំពង់ក្របី រហូតដល់ចប់ថ្នាក់ទី៧ និងបានប្រឡងជាប់ដើម្បីបន្តការរៀនសូត្រនៅវិទ្យាល័យព្រះសីហនុ។ ប្រហែលជា ៣ខែ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅដើមឆ្នាំ១៩៧០ ខ្ញុំឃើញមានបាតុកម្មដង្ហែរចូលមកទីរួមខេត្តកំពង់ចាមរយៈពេល៣ថ្ងៃ ។ នៅពេលនោះ ខ្ញុំរៀនថ្នាក់ទី៦។ បើទោះបីជាមានការធ្វើបាតុកម្មយ៉ាងណាក្តី ខ្ញុំនៅតែបន្តការសិក្សា និងស្នាក់អាស្រ័យជាមួយឪពុកមានៅ ទីរួមខេត្តកំពង់ចាម។ បន្ទាប់ពីបាតុកម្មបានបញ្ចប់ ការផ្ទុះអាវុធរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានកើតឡើង។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ភូមិកំណើតរបស់ខ្ញុំដើម្បីត្រៀមវាយបន្ទាយ លន់ នល់ នៅម្តុំកោះរកា។ ខ្ញុំតែងតែមកលេងផ្ទះដោយដើរតាមផ្លូវវាង។ មូលហេតុដែលខ្ញុំមិនអាចមកតាមផ្លូវពីព្រែកដើមចាន់ មកភូមិចំការសាមសិប គឺមានទាហាន លន់ នល់ ត្រូវបានដាក់ឈរជើងដើម្បីទប់ទល់ និងវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមនៅភូមិជិតនោះ។ ខ្ញុំបានបន្តរៀននៅវិទ្យាល័យព្រះសីហនុរហូតដល់ឆ្នាំ១៩៧៣ ត្រឹមថ្នាក់ទី៣។ ខ្ញុំបានឈប់រៀន បន្ទាប់ពីមកលេងផ្ទះនាពេលចុងសប្តាហ៍។ នៅពេលនោះ លោកតា របស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថាកុំវិលទៅរៀននៅ ទីរួមខេត្តកំពង់ចាម ព្រោះតែស្ថានការណ៍ច្របូកច្របល់។



ជា ខេងថៃ អាយុ៧០ឆ្នាំ ជាកសិករ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់តាំងពីឆ្នាំ១៩៧៣ មក ខ្ញុំបានចូលបម្រើបដិវត្តន៍ និងត្រូវបានមិត្ត ជឿន ដែលជាមេភូមិក្នុងតំបន់រំដោះនាពេលនោះ ដាក់ចូលធ្វើការងារនៅ



កំពង់ចម្លងនៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។
(ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កងពាណិជ្ជកម្មស្រុកកំពង់សៀម។ នៅក្នុងកងពាណិជ្ជកម្មស្រុក មានសមមិត្តប្រហែលជា១០នាក់ ដែលមានតួនាទីដឹកជញ្ជូនសម្ភារប្រើប្រាស់ផ្សេងៗ។ នៅឆ្នាំ១៩៧៣ ដដែល ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៤១ ដែលមានមិត្ត ផួន គឺជាប្រធាន។ នៅពេលនោះ ខ្ញុំទទួលបានមុខងារជាអ្នកកត់ត្រា និងធ្វើបញ្ជីទំនិញសម្ភារប្រើប្រាស់។ នៅមន្ទីរពាណិជ្ជកម្មតំបន់៤១នេះ មានសមមិត្តទាំងអស់ចំនួន ១០នាក់ ដែលត្រូវបានចាត់តាំងធ្វើការងារផ្សេងៗគ្នា។ សមរភូមិរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះកាន់តែខ្លាំងឡើង។ កងពាណិជ្ជកម្មតំបន់ ៤១ បានជិះកង់ទៅដឹកអីវ៉ាន់សម្ភារប្រើប្រាស់ពីព្រំប្រទល់វៀតណាម ដើម្បីយកមកចែកចាយនៅតាមស្រុកនានាក្នុងតំបន់។

បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានរំដោះនៅឆ្នាំ ១៩៧៥ ខ្ញុំនៅបន្តធ្វើជាអ្នកកត់បញ្ជីទំនិញនៅមន្ទីរពាណិជកម្មតំបន់៤១ ដដែល ដែលស្ថិតនៅទីប្រជុំជនថ្នល់ទទឹង ស្រុកព្រៃឈរ។ ខ្ញុំមិនដែលបានមកលេងផ្ទះនោះឡើយ។ តាមអ្វីដែលខ្ញុំដឹងនោះគឺតំបន់ ៤១ ស្ថិតនៅភូមិភាគកណ្ដាលដែលមានកែ ពក គឺជាលេខាភូមិភាគ មានស្រុកចំណុះចំនួន៥ រួមមាន៖ ស្រុកកំពង់សៀម (ហៅថាស្រុក៨៨), ស្រុកព្រៃឈរ (ហៅថាស្រុក៧៧), ស្រុកកងមាស (ហៅថាស្រុក ១០១), ស្រុកជើងព្រៃ (ហៅថាស្រុក៤៤) និងស្រុកបាធាយ (ហៅស្រុក៧៣)។ នៅឆ្នាំ១៩៧៦ តំបន់ ៤១ មានប្រធានឈ្មោះមិត្ត តាំង។ ប្រធានមន្ទីរពាណិជកម្មតំបន់គឺមិត្ត សាន ដែលបានចាត់តាំងឲ្យខ្ញុំកត់ត្រាបញ្ជីសម្ភារប្រើប្រាស់ក្នុងឃ្លាំង។ នៅឆ្នាំ ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកដល់ និងចាប់ផ្ដើមចាប់ខ្លួនកម្មាភិបាលមូលដ្ឋាន។ នៅពេលនោះ មិត្ត តាំង ប្រធានតំបន់ និងមិត្ត សាន ត្រូវបានចាប់ខ្លួន និងសម្លាប់។ មិត្ត ស៊ុប ប្រធានមន្ទីរ

សន្តិសុខតំបន់ គឺជាអ្នកដើរចាប់ៗ ប៉ុន្តែក្រោយមក មិត្ត ស៊ុប ត្រូវបានសម្លាប់ដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីវិញ។ នៅក្នុងឆ្នាំដដែល សមមិត្ត អោ អាន ត្រូវបានផ្លាស់មកគ្រប់គ្រងតំបន់ ៤១។ បន្ទាប់ពីការមកដល់របស់ សមមិត្ត អោ អាន មានការចាប់ប្រធានកង និងកម្មាភិបាលមូលដ្ឋាននៅតាមស្រុកកាន់តែច្រើនឡើងៗ ខ្ញុំត្រូវបានចាត់តាំងធ្វើជាប្រធានមន្ទីរពាណិជ្ជកម្ម។ ថ្នាក់លើប្រាប់ថា ខ្ញុំមិនទាន់ត្រូវបានចាប់យកទៅសម្លាប់នៅពេលនេះ ពីព្រោះតែមិនទាន់មានអ្នកជំនួសចេះធ្វើបញ្ជីនៅឃ្លាំងៗ ចាប់តាំងពីពេលនោះមក ខ្ញុំបានកិនគ្រាប់ស្វែង និងដាក់តាមខ្លួនរហូត។ នៅពេលដែលខ្ញុំត្រូវបានចាប់ខ្លួនធ្វើទារុណកម្ម ខ្ញុំនឹងសម្លាប់ខ្លួនដោយការលេបគ្រាប់ស្វែងដែលកិនរួចជាស្រេចនោះ។ ខ្ញុំខ្លាចការធ្វើទារុណកម្ម។ រាល់ពេលខ្ញុំទៅមន្ទីរតំបន់ ៤១ ខ្ញុំតែងតែឮសូរការសួរចម្លើយ និងសម្រែកឈឺចុកចាប់ចេញពីកន្លែងធ្វើទារុណកម្ម។ ខ្ញុំមិនចង់ជួបភាពឈឺចុកចាប់បែបនេះទេ។ មិនយូរមិនឆាប់ ខ្ញុំនឹងត្រូវបានចាប់ខ្លួន ដូច្នេះខ្ញុំបានត្រៀមគ្រាប់ស្វែងកិនដាក់តាមខ្លួន។ ក្នុងអំឡុងពេលធ្វើជាប្រធានមន្ទីរពាណិជ្ជកម្ម ខ្ញុំតែងតែដឹកនាំកងដឹកជញ្ជូនពាណិជ្ជកម្មទៅយកអំបិល សម្ភារប្រើប្រាស់ និងក្រណាត់ខ្មៅនៅមន្ទីរភូមិភាគកណ្តាលនៅម្តុំចំការលើ។ បន្ទាប់ពីដឹកអំបិល សម្ភារប្រើប្រាស់ និងក្រណាត់ចូលឃ្លាំងវិញមក មិត្ត អោ អាន លេខាតំបន់ ៤១ មិនអនុញ្ញាតឲ្យដឹកយកទៅចែកនៅតាមបណ្តាស្រុកក្នុងតំបន់នោះឡើយ រហូតដល់របស់ទាំងអស់នេះនៅសល់ពេញឃ្លាំងៗ ខ្ញុំដឹងថា មិត្ត កែ ពក លេខាភូមិភាគ បានបញ្ជាឲ្យលេខាតំបន់ ៤១ គឺមិត្ត អោ អាន ធ្វើការចែកចាយសម្ភារប្រើប្រាស់ ជាពិសេសក្រណាត់ខ្មៅ ទៅកាន់ស្រុកផ្សេងៗ ប៉ុន្តែមិត្ត អាន មិនស្តាប់និងអនុវត្តតាមនោះឡើយ។ នៅថ្ងៃមួយចុងឆ្នាំ១៩៧៧ ខ្ញុំបានឡើងទៅដឹកសម្ភារប្រើប្រាស់បន្ថែមនៅមន្ទីរភូមិភាគ និងសរសេរសំបុត្រអនាមិកមួយរាយការណ៍ដល់លេខាភូមិភាគអំពីការមិនចែកចាយសម្ភារប្រើប្រាស់ ជាពិសេសក្រណាត់ខ្មៅនៅតំបន់៤១។ រយៈពេល ២ទៅ៣ថ្ងៃបន្ទាប់មក នីរសារភូមិភាគចំនួន២នាក់ត្រូវបានបញ្ជូនមក ដើម្បីពិនិត្យមើលឃ្លាំងនៅមន្ទីរពាណិជ្ជកម្មតំបន់ ៤១។ ប៉ុន្មានថ្ងៃក្រោយមក មិត្ត អាន បានឡើងទៅប្រជុំនៅមន្ទីរភូមិភាគ។ បន្ទាប់ពីការប្រជុំនៅមន្ទីរភូមិភាគ មិត្ត អាន បានបញ្ជាឲ្យកងពាណិជ្ជកម្មតំបន់ចាប់ផ្តើមចែកចាយសម្ភារ និងក្រណាត់ខ្មៅនៅតាមស្រុក និងសហករណ៍នៅក្នុងតំបន់៤១។ ខ្ញុំមានការព្រួយបារម្ភជាខ្លាំងពីការដែលអង្គការដឹងថា ខ្ញុំគឺជាអ្នកសរសេរសំបុត្រអនាមិកជូនលេខាភូមិភាគ។ នៅឆ្នាំ១៩៧៨ ខ្ញុំបន្តធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់៤១ដដែល។ នៅពេលដែលកងទ័ពវៀតណាមវាយចូលមកដល់នៅដើមឆ្នាំ១៩៧៩ ខ្ញុំត្រូវបានជម្លៀសជាមួយអ្នកផ្សេងទៀតទៅទិសខាងលិចប្រទេស។ ដោយសារតែភ័យខ្លាចការនាំទៅសម្លាប់ ខ្ញុំ និងមិត្ត៣នាក់ទៀតបានលួចឡានដឹករត់ទៅខាងចំការលើ និងបានទុកឡានចោលក្នុងចម្ការចេកៗ ខ្ញុំបានបន្តដើរមកកាន់ភូមិកំណើតវិញ និងរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម។ នៅឆ្នាំ១៩៨១ ខ្ញុំចូលបង្រៀនសិស្សនៅសាលាបឋមសិក្សាកំពង់ក្របី និងចូលនិវត្តន៍អស់រយៈពេលជិត១០ឆ្នាំហើយ។



ផ្លូវក្រាលបេតុងនៅទីប្រជុំជនស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៉ុល ខន ៖ ជាងសាងសង់ផ្ទះ

ថុន ស្រីពេជ្រ



ប៉ុល ខន អាយុ៧៩ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិអង្រ្គង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុល ខន អាយុ៧៩ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិអង្រ្គង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ដោយសារតែរបបខ្មែរក្រហមកើតឡើងរយៈពេលជាង៤០ឆ្នាំកន្លងមកហើយ ហើយដោយសារគាត់មានវ័យកាន់តែជរា ដូច្នេះគាត់បានភ្លេចនូវរឿងរ៉ាវរបស់គាត់មួយចំនួននៅក្នុងរបបនោះ។ ខន បានរំលឹកអំពីប្រវត្តិរឿងរ៉ាវរបស់គាត់ប្រាប់បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដូចខាងក្រោម៖

ខ្ញុំឈ្មោះ ប៉ុល ខន កើតនៅភូមិអង្រ្គង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ប៉ុល ខាន់ និងម្ដាយឈ្មោះ ប៉ែន នីម។ ខ្ញុំគឺជាកូនទោលនៅក្នុងគ្រួសារ។ ឪពុកម្ដាយរបស់ខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅសិក្សារៀនសូត្រនៅសាលាបឋមសិក្សាបូសព្រីង។ នៅអាយុ១៥ឆ្នាំ ខ្ញុំរៀនត្រឹមថ្នាក់ទី ១០ ពីសង្គមចាស់។ ពេលនោះខ្ញុំក៏សម្រេចចិត្តឈប់រៀន ហើយមកបួសរៀននៅវត្តប្រាសាទ ស្ថិតនៅឃុំស្វាយយា ស្រុកស្វាយជ្រំ។ បួសបាន៣វស្សា ខ្ញុំបានសឹក ហើយត្រឡប់មកធ្វើស្រែចម្ការវិញ។ នៅអាយុ១៩ឆ្នាំ ខ្ញុំបានរៀបការជាមួយនឹងប្រពន្ធរបស់ខ្ញុំ។ បន្ទាប់ពីរៀបការហើយ ខ្ញុំមានកូនស្រីម្នាក់ ខណៈនោះមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ពីប្រមុខរដ្ឋ។ ដោយសារតែបានឮការអំពាវនាវរបស់សម្ដេចពីទីក្រុងប៉េកាំងមកឲ្យកូនចៅដែលមានភក្ដីភាពជាមួយព្រះអង្គរត់ចូលព្រៃម៉ាគី ដើម្បីតស៊ូប្រយុទ្ធ និងទាមទារយកអំណាចមកថ្វាយព្រះអង្គវិញ ដូច្នេះខ្ញុំពុំរួញរាឡើយ គឺខ្ញុំសម្រេចចិត្តចូលទៅក្នុងព្រៃម៉ាគី ដើម្បីតស៊ូជាមួយប្រជាជន។ គ្រួសាររបស់ខ្ញុំក៏សប្បាយចិត្ត និងជំរុញឲ្យខ្ញុំទៅតស៊ូដែរ។ ខ្ញុំធ្វើដំណើរអស់រយៈពេល ២ថ្ងៃ ទើបទៅដល់ឃុំកំពង់ត្រាច (ព្រៃម៉ាគី) ស្រុករមាសហែក និងបានស្នាក់នៅទឹកវិល។ កន្លះខែក្រោយមក ខ្ញុំបានត្រឡប់មកផ្ទះវិញដោយសារជួបការលំបាក និងពុំទាន់បានហ្វឹកហាត់យោធា។

ក្រោយថ្ងៃកងទ័ពខ្មែរក្រហម ទទួលជ័យជម្នះលើរបប លន់ នល់ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការដាក់បញ្ចូលទៅក្នុងក្រុមជាងសង់ផ្ទះដែលមានសមាជិកចំនួន១២នាក់។ ជារៀយៗសមាជិក

ក្រុមរបស់ខ្ញុំ បានសង់ផ្ទះ សង់ខ្ទមឲ្យប្រជាជននៅក្នុងភូមិ។ ក្រៅពីសង់ផ្ទះ និងខ្ទម ខ្ញុំបានសង់មន្ទីរពេទ្យចំនួន ១០ខ្នង និងរោងបាយចំនួន៣នៅក្នុងភូមិរបស់ខ្ញុំ និងអារឈើសម្រាប់សង់សំណង់ផ្សេងៗទៀត។ បើនិយាយអំពីអាហារហូបចុក ពេលនោះខ្ញុំមានបាយហូបគ្រប់គ្រាន់ដោយសារតែខ្ញុំមានមិត្តភក្តិ និងបងធម៌ដែលកាន់តួនាទីធំៗ ដូចជាឈ្មោះ ស័ក គឺជាគណៈឃុំ និង អ៊ុន គឺជាសន្តិសុខស្រុកទួលដើងចាប។ ស័ក និង អ៊ុន ត្រូវបានអង្គការចាប់ខ្លួន និងយកទៅសម្លាប់ នៅឆ្នាំ១៩៧៨ ក្រោយ សោ ភឹម ត្រូវបានចោទប្រកាន់ថា ប្រឆាំងនឹងបដិវត្តន៍។ ខ្ញុំពុំបានដឹងថា ឈ្លបខ្មែរក្រហមយកមិត្តភក្តិ និងបងធម៌របស់ខ្ញុំទៅសម្លាប់ឯណាឡើយ ប៉ុន្តែខ្ញុំដឹងថា ទីតាំងសម្លាប់ដែលខ្ញុំស្គាល់មានចំនួន ៣ កន្លែងគឺ វាលតាប្រុញ, វត្តបឹងវ៉ែ និងទួលដើងចាប។ ពេលដឹងថាមិត្តភក្តិ និងបងធម៌ត្រូវបានឈ្លបចាប់ខ្លួនយកទៅសម្លាប់បែបនេះ ខ្ញុំភិតភ័យខ្លាំងណាស់ ព្រោះខ្លាចឈ្លបខ្មែរក្រហមចោទប្រកាន់ខ្ញុំ និងយកខ្ញុំទៅសម្លាប់បន្តទៀត។

នៅដើមខែមករា ឆ្នាំ១៩៧៩ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំ បាននាំគ្នារត់ចាកចេញពីផ្ទះស្ទើរតែអស់រលីង ព្រោះបានឮដំណឹងតៗគ្នាថា កងកម្លាំងវៀតណាម នឹងចូលមកក្នុងភូមិ ហើយសម្លាប់ប្រជាជនចោលនាពេលបន្តិចទៀត។ ខ្ញុំរត់ភៀសខ្លួនបានបន្តិចក៏បានជួបជាមួយកងទ័ពវៀតណាម ហើយកងទ័ពវៀតណាមប្រាប់ខ្ញុំឲ្យត្រឡប់មកក្រោយវិញ។

ក្រោយរបបខ្មែរក្រហមដួលរលំ មិនបានប៉ុន្មានខែផង ស្រាប់តែមានក្រុមជាតិនិយមមួយក្រុមទៀតដែលខ្ញុំមិនចាំឈ្មោះ បានចាប់ខ្ញុំយកទៅឃុំឃាំង និងសួរចម្លើយ។ ក្រុមជាតិនិយមនោះបានចោទប្រកាន់ខ្ញុំថា គឺជាក្រុមដីវីសភ្លុកខៀវ ដែលបានចូលដៃចូលជើងជាមួយវៀតណាមខាងត្បូង។ ខ្ញុំទទួលរងការឈឺចាប់ និងរងទារុណកម្មរាល់ការសួរចម្លើយអស់រយៈពេល ២ខែ នៅក្នុងគុកមួយក្នុងខេត្តស្វាយរៀង។ ក្រោយពីការសួរចម្លើយ និងស្រាវជ្រាវដឹងថា ខ្ញុំមិនជាប់ពាក់ព័ន្ធជាមួយកងទ័ពវៀតណាមខាងត្បូង ក្រុមជាតិនិយមនោះក៏បានដោះលែងឲ្យ ខ្ញុំមានសេរីភាព និងបានវិលត្រឡប់មកស្រុកកំណើតវិញ។ ក្រោយមកខ្ញុំក៏បានចូលបម្រើកងទ័ពនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជារហូតដល់ចូលនិវត្តន៍។



ផ្ទះរបស់អ្នកភូមិស្ថិតនៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុក ម៉ុក ៖ ប្រធានក្រុមនៅកងចល័ត

គាត ស្រីឡែន



អ៊ុក ម៉ុក រស់នៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុក ម៉ុក ភេទប្រុស កើតនៅឆ្នាំ១៩៦២។ ខ្ញុំមានស្រុកកំណើតនៅភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ហើយសព្វថ្ងៃខ្ញុំរស់នៅភូមិឃុំដដែល។ ឪពុករបស់ខ្ញុំឈ្មោះ យ៉ាង អ៊ុក និងម្តាយឈ្មោះ ថោង ខុន ព្រមទាំងមានបងប្អូនបង្កើតចំនួន៨ នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ ស៊ាន និងមានកូនចំនួន៤ នាក់។

កាលពីសម័យមុននៅក្នុងភូមិរបស់ខ្ញុំមានប្រជាជនរស់នៅប្រហែលជា៧០គ្រួសារប៉ុណ្ណោះ ហើយនៅក្នុងភូមិមានដើមឈើដុះស៊ុបទ្រុប។ នៅពេលខ្ញុំមានអាយុ១០ឆ្នាំ នៅក្នុងភូមិរបស់ខ្ញុំកើតមានសង្គ្រាមរវាងទាហានអាមេរិក និងកងទ័ពវៀតកុង ឬវៀតណាមខាងជើង។ ប្រជាជននាំគ្នារត់ចូលត្រង់សេឬលេណដ្ឋានដើម្បីគេចពីគ្រាប់ផ្លោង។ ក្រោយសង្គ្រាមស្ងប់ស្ងាត់ ទើបយើងនាំគ្នាចូលមករស់នៅក្នុងផ្ទះ និងប្រកបរបរធ្វើស្រែចម្ការវិញ។ រយៈពេលមួយឆ្នាំក្រោយមកសង្គ្រាមក៏កើតឡើងម្តងទៀត។

នៅក្នុងឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានចូលមកគ្រប់គ្រងនៅក្នុងភូមិរបស់ខ្ញុំ និងបានប្រមូលទ្រព្យសម្បត្តិ, គោ, ក្របី, មាន់, ទា, ចាន, ឆ្នាំង ដាក់ជារបស់រួម។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងកងកុមារ។ កងកុមារចាប់ផ្តើមធ្វើការនៅម៉ោង៦ព្រឹកដូចកងមនុស្សចាស់ៗដែរ។ ក្រោយមក ខ្ញុំផ្លាស់ចូលធ្វើការនៅក្នុងកងចល័ត ហើយត្រូវបានខ្មែរក្រហមចាត់តាំងឲ្យប្រចូតស្រូវ និងឃ្វាលគោក្របី។ ពេលយប់ខ្មែរក្រហមឲ្យខ្ញុំរៀនអក្សរបន្ថែម។ គ្រូបង្រៀនគឺជាកម្មា-ភិបាលខ្មែរក្រហម ហើយខ្ញុំរៀនដល់ថ្នាក់ទី៣។

នៅពេលយប់កងយុវជន និងយុវនារីត្រូវដេកនៅកន្លែងផ្សេងគ្នា។ នៅពេលនោះប្រធានកងយុវជនឈ្មោះ សំ អេន និងប្រធានកងយុវនារី ឈ្មោះ ឈុំ។ ខ្ញុំត្រូវចាត់តាំងជាប្រធានក្រុម ដោយមានភារកិច្ចហៅសមាជិកក្រុមមកប្រជុំ និងណែនាំក្រុមឲ្យធ្វើការងារបន្ត។ ក្រុមនីមួយៗត្រូវចូលរួមប្រជុំរៀងរាល់ល្ងាច។ ខ្ញុំធ្វើការនៅកងចល័តរហូតដល់ឆ្នាំ១៩៧៧។

ក្រោយមក កម្មាភិបាល និងកងទ័ពមកពីភូមិភាគនិរតីបានចូលមកគ្រប់គ្រងភូមិ ហើយបានចាប់គ្រូ

បង្រៀន និងប្រធានកងរបស់ខ្ញុំយកទៅបាត់។ កម្មាភិបាល និងកងទ័ពមកពីភូមិភាគនិរតីបានចាប់មនុស្សកាន់តែច្រើនយកទៅចងទុកនៅសាលារំចេក។ ចំណែកខ្ញុំត្រូវខ្មែរក្រហមមកពីនិរតីជម្លៀសទៅដល់ព្រៃឆ្លូង ប៉ុន្តែដោយសារនៅទីនោះមិនមានអាហារហូបចុកគ្រប់គ្រាន់ ខ្ញុំក៏រត់ភៀសខ្លួនចេញពីភូមិទាំងភ័យខ្លាច។

នៅឆ្នាំ១៩៧៨ កម្មាភិបាល និងយោធាខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកកាន់តែច្រើន និងបានស្នាក់នៅសាលារំចេក។ នៅពេលនោះ ប្រជាជនលែងហ៊ានរស់នៅក្នុងភូមិទៀតហើយ គឺបាននាំគ្នាទៅរស់នៅក្នុងព្រៃ។ ខ្ញុំបានរត់ភៀសខ្លួនទៅខ្នងក្រពើ ហើយបន្ទាប់មកទៅប្រទេសវៀតណាម ព្រោះមានរថយន្តវៀតណាមរង់ចាំទទួលនៅមេមត់។ វៀតណាមបានសង់ផ្ទះថ្មី និងបើករបបអង្ករឲ្យខ្ញុំហូបរៀងរាល់ខែ។ ខ្ញុំរស់នៅវៀតណាមបានរយៈពេល៥ខែ។ បន្ទាប់ពីខ្ញុំបានឮសេចក្តីប្រកាសថា កងទ័ពវៀតណាមវាយចូលប្រទេសកម្ពុជា ដើម្បីរំដោះប្រជាជនកម្ពុជាចេញពីរបបខ្មែរក្រហម ទើបខ្ញុំត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំបានមករស់នៅជុំឪពុកម្តាយនៅក្នុងភូមិ។ បន្ទាប់មកខ្ញុំរៀបការជាមួយប្រពន្ធរបស់ខ្ញុំដែលជាអ្នកស្រុកជាមួយគ្នា និងប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



ព្រះវិហារ វត្តគិរីវនារាម ស្ថិតនៅក្នុងភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្លូវលំនៅក្នុងភូមិរំចេក ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំនៅតែសោកស្តាយប្អូនប្រុសរបស់ខ្ញុំ តូ នឹម អតីតប្រធានកងរថក្រោះ

សៀង កញ្ញា



តូ ណែម អាយុ៨២ឆ្នាំ រស់នៅភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ សៀង កញ្ញា អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ តូ ណែម អាយុ៨២ឆ្នាំ។ សព្វថ្ងៃខ្ញុំរស់នៅជាមួយកូនប្រុស និងចៅៗបួននាក់ ក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់ ក្នុងនោះមានស្រី៣នាក់ និងប្រុស២នាក់។ កាលពីអាយុ១០ឆ្នាំ ខ្ញុំរៀននៅក្នុងវត្តត្រពាំងធំជាមួយព្រះសង្ឃ។ ថ្ងៃមួយក្រុមខ្មែរឥស្សរៈត្រពាំងស្គោ បានមកលួងខ្ញុំឲ្យទៅជាមួយនៅជើងភ្នំជីរីរមៀលរយៈពេល៣ថ្ងៃ។ ក្រុមខ្មែរឥស្សរៈ បានបង្រៀនខ្ញុំឲ្យរៀនកាន់កាំភ្លើង រៀនកេះកៃកាំភ្លើង និងប្រាប់ពីរបៀបបាញ់។ នៅពេលបាត់ខ្លួនខ្ញុំ ឪពុកម្តាយរបស់ខ្ញុំបានដើររក ហើយបានឃើញខ្ញុំនៅជាមួយក្រុមខ្មែរឥស្សរៈ។ ឪពុកម្តាយរបស់ខ្ញុំបានស្នើសុំខ្ញុំពីក្រុមខ្មែរឥស្សរៈត្រឡប់មកវិញ ដើម្បីបានចូលរៀនដូចដើម។ ប៉ុន្តែពេលនោះខ្ញុំមិនបានរៀនស្ទិតស្ទេរទេ ព្រោះឪពុកម្តាយក្រីក្រ។ ខ្ញុំឈប់រៀននៅពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ នៅឆ្នាំ១៩៧១ ខ្ញុំរៀបការប្រពន្ធ និងប្រកបរបរជាអ្នកអារឈើរហូតដល់របបខ្មែរក្រហម។ ទោះបីយ៉ាងណា ខ្ញុំនៅតែចងចាំអំពីការបាត់បង់ប្អូនប្រុសរបស់ខ្ញុំម្នាក់ឈ្មោះ តូ នឹម គឺជាអតីតប្រធានកងរថក្រោះក្នុងរបបខ្មែរក្រហម ៖

តូ នឹម ស្លាប់ប្រហែលពាក់កណ្តាលឆ្នាំ១៩៧៨ នៅភ្នំពេញ។ ប្រសិនបើប្អូនប្រុសរបស់ខ្ញុំនៅរស់ នោះស្ថានភាពគ្រួសាររបស់វាគឺប្រាកដជាធូរធារ និងមានអ្នកស្គាល់។ មិត្តភក្តិរបស់ប្អូនប្រុសខ្ញុំម្នាក់ឈ្មោះ វឿន បានប្រាប់ខ្ញុំថា «ប្អូនប្រុសរបស់ខ្ញុំត្រូវ តាម៉ុក រុញទម្លាក់ពីលើផ្ទះ សាឡុត ស នៅក្នុងទីក្រុងភ្នំពេញជាន់ទីមួយ ដោយសារ តាម៉ុក សង្ស័យថា ប្អូនប្រុសរបស់ខ្ញុំបានក្បត់គាត់ និងក្បត់អង្គការ។ នៅក្នុងឆ្នាំ១៩៧៨ ប្អូនប្រុសរបស់ខ្ញុំបានមកលេងផ្ទះនៅស្រុកកំណើត នៅពេលដែលខ្ញុំកំពុងបំពេញការងារនៅក្នុងកងសេដ្ឋកិច្ច។ ខ្ញុំមិនបានជួបប្អូនទេ នៅពេលដែលអង្គការមកហៅវាឲ្យត្រឡប់ទៅភ្នំពេញវិញ តាមបញ្ជារបស់ តាម៉ុក ដោយប្រាប់មូលហេតុថាឲ្យប្អូនខ្ញុំទៅចូលរួមប្រជុំសម្ងាត់»។

ប្អូនរបស់ខ្ញុំមានតួនាទីជាប្រធានកងពលធំរថក្រោះ ប្រចាំការនៅទីក្រុងភ្នំពេញ។ ប្អូនខ្ញុំខស្វាហ៍មកលេងផ្ទះណាស់ ព្រោះវាមានសិទ្ធិអាចដើរហើរបាន។ ក្រោយមកខ្ញុំឮថា តាម៉ុក លែងទុកចិត្តវា ហើយព្យាយាមសម្លាប់វាចោល ប៉ុន្តែសម្លាប់មិនបាន ព្រោះប្អូនរបស់ខ្ញុំមានមន្តអាគមដែលអាចការពារខ្លួនពីការលួចបាញ់សម្លាប់។ ដូច្នេះ តាម៉ុកបានរកវិធីសម្លាប់ប្អូនខ្ញុំដោយប្រានវាទម្លាក់ពីលើផ្ទះ។ ប្អូនរបស់ខ្ញុំគឺជាមនុស្សហ៊ានសាហាវ និងមិនខ្លាចស្លាប់ឡើយ។ ប្អូនរបស់ខ្ញុំបានចូលរួមក្នុងចលនាបដិវត្តន៍របស់ខ្មែរក្រហម បន្ទាប់ពីលន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ភ្លាមៗ។

មិត្តភក្តិរបស់ប្អូនប្រុសខ្ញុំ៤នាក់ទៀតគឺ យែម, អុន, ដាង, និង ឌិន គឺសុទ្ធតែអ្នកមុះមុតប្រចាំភូមិ ក៏បានចូលធ្វើបដិវត្តន៍ជាមួយវាដែរ គឺចូលនៅត្រពាំងក្ដុម្ពឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ នៅពេលដែលកើតមានព្រឹត្តិការណ៍វាយប្រយុទ្ធគ្នារវាងវៀតណាមខាងជើង និងទាហានលន់ នល់ នៅតាមបង្កេះភ្នំជីវីរមៀល។ ប៉ុន្តែខ្ញុំបានដឹងថា ប្អូនរបស់ខ្ញុំមានតួនាទីធំក្នុងជួរកងទ័ពបដិវត្តន៍ខ្មែរក្រហម។ ក្រោយថ្ងៃយោធាខ្មែរក្រហមទទួលជ័យជម្នះ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្អូនរបស់ខ្ញុំមានតួនាទីជាប្រធានកងពលរថក្រោះ ហើយក្រោយមកវាត្រូវតាម៉ុក ផ្លាស់ប្តូរឲ្យទៅប្រចាំការនៅទីក្រុងភ្នំពេញរហូតដល់ថ្ងៃប្អូនរបស់ខ្ញុំស្លាប់។ ខ្ញុំស្តាយប្អូនរបស់ខ្ញុំខ្លាំងណាស់ មិនគួរជួបរឿងអកុសលដូច្នេះទេ។

ចំណែកខ្ញុំ បន្ទាប់ពីធ្វើការងារនៅកងសេដ្ឋកិច្ចខ្មែរក្រហមបានផ្លាស់ខ្ញុំឲ្យទៅធ្វើស្រែប្រាំងនៅត្នោតចាង ក្នុងស្រុកអង្គរបុរី ខេត្តតាកែវ។ ខ្មែរក្រហមបានប្រគល់ក្របីឲ្យខ្ញុំមួយនឹមយកទៅភ្ជួរស្រែ។ ក្របីនោះធំៗណាស់ ដូច្នេះខ្ញុំមិនសូវហ៊ានវាយវាទេ ព្រោះខ្ញុំខ្លាចវាវីធខ្ញុំវិញ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់កងទ័ពវៀតណាមវាយចូលមកនៅដើមខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំត្រឡប់មករស់នៅស្រុកកំណើតវិញ។



ភ្នំជីវីរមៀល ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គង់ ស៊ីម ៖ កងផលិត

## សូ ហាន់



រូបខាងឆ្វេង ៖ គង់ ស៊ីម ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ដល់ សូ ហាន់ បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គង់ ស៊ីម អាយុ ៧២ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង បានរៀបរាប់ថា ខ្ញុំមានបងប្អូនចំនួន៤នាក់ ក្នុងនោះស្រី២នាក់ ហើយខ្ញុំគឺជាកូនទី១។ នៅឆ្នាំ១៩៦៤ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាស្រះតាអឹម ដល់ថ្នាក់ទី៨ នៅក្នុងសម័យសង្គមរាស្ត្រនិយម។ ខ្ញុំរៀនជាមួយលោកគ្រូឈ្មោះ ប្រាក់ ម៉ុន, អាំ, តី ម៉ាឡែន និងគ្រូ ឡុង។

នៅឆ្នាំ១៩៦៩ ខ្ញុំបានបួសរៀននៅវត្តព្រៃរំដេង បានចំនួន២វស្សា ហើយសឹកវិញ។ នៅដើមឆ្នាំ១៩៧០ ខ្ញុំបានទៅចូលរួមទទួលដំណើរយាងរបស់សម្តេចព្រះ នរោត្តម សីហនុ មកសម្ពោធមន្ទីរពេទ្យ និងសាលារៀន នៅក្នុងឃុំអង្គរស។ ក្រោយមក ក៏កើតមានព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោក លន់ នល់។ ក្រោយពីរដ្ឋប្រហារ ខ្ញុំឃើញវត្តមានរបស់កងទ័ពធីវគី ចូលមកធ្វើបាប

ប្រជាជន និងលួចប្លន់ទ្រព្យសម្បត្តិប្រជាជនជាដើម។

នៅឆ្នាំ១៩៧១ ខ្ញុំបានចូលធ្វើឈ្លបឃុំអង្គរស រយៈពេល២ឆ្នាំ បន្ទាប់មកខ្ញុំផ្លាស់ទៅចូលកងពិសេស និងឈរជើងនៅស្រុកមេសាងវិញ។ ក្រោយមក ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅធ្វើការងារខាងបែងចែកផលត្រី។ នៅពេលនោះ មានការទម្លាក់គ្រាប់បែកកើតមានជាហូរហែ រហូតមកដល់ចុងឆ្នាំ១៩៧៣។ ការរស់នៅរបស់ខ្ញុំលំបាកណាស់ ព្រោះខ្ញុំត្រូវរត់ចូលក្នុងលេណដ្ឋានជាញឹកញាប់ដើម្បីគេចពីការទម្លាក់គ្រាប់បែក។ នៅឆ្នាំ១៩៧៤ ការទម្លាក់គ្រាប់បែកបានស្ងប់ស្ងាត់ទៅវិញ។ ចាប់តាំងពេលនោះមក ខ្មែរក្រហមបង្កើតឲ្យមានសហករណ៍ ហើយឲ្យប្រជាជនហូបបាយរួមជាបណ្តើរៗ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះ នៅទីក្រុងភ្នំពេញ ខ្ញុំបានវិលត្រឡប់មករស់នៅក្នុងភូមិស្រះតាអឹមវិញ។ នៅពេលនោះ ប្រជាជនចាប់ផ្តើមយករបស់របរប្រើប្រាស់ដាក់ចូលទៅក្នុងសហករណ៍ ធ្វើជារបស់ប្រើប្រាស់រួម។ នៅឆ្នាំ១៩៧៦ អង្គការបានរៀបការឲ្យខ្ញុំ។ បន្ទាប់ពីរៀបការរួច ខ្មែរក្រហមបានចាត់ខ្ញុំឲ្យធ្វើការនៅកងផលិត និងទៅកាប់ព្រៃនាម។ ក្រោយមក ខ្មែរក្រហមក៏បញ្ជូនខ្ញុំទៅធ្វើការនៅក្រុងព្រៃវែង។ នៅពេលនោះដោយសភាពការច្របូកច្របល់ និងមានការបាញ់ប្រោះ ខ្ញុំបានផ្លាស់ទៅនៅស្រុកពញាក្រែកវិញ។ នៅទីនោះបានមួយរយៈ កងទ័ពវៀតណាមបានចាប់ផ្តើមវាយប្រយុទ្ធតទល់ជាមួយយោធាខ្មែរក្រហមនៅតាមព្រំដែនក្នុងខេត្តក្រចេះ ធ្វើឲ្យខ្ញុំមានការភ័យខ្លាចហើយរត់ត្រឡប់មករស់នៅក្នុងភូមិស្រះតាអឹមវិញ។ ពេលខ្ញុំមកដល់ភូមិស្រះតាអឹម ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីភូមិឲ្យធ្វើដំណើរទៅអ្នកលឿង។ នៅពេលទៅដល់អ្នកលឿង ក៏មានការផ្ទុះអាវុធទៀត ហើយកងទ័ពសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ប្រកាសឲ្យប្រជាជនវិលត្រឡប់ទៅស្រុកកំណើតវិញ ព្រោះប្រទេសរបស់យើងត្រូវបានរំដោះហើយ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានវិលមករស់នៅក្នុងភូមិស្រះតាអឹម និងបានជួបជុំគ្រួសារវិញ។ ខ្ញុំនិងគ្រួសារនៅជួបការលំបាកនៅឡើយ ព្រោះមិនទាន់មានស្រូវអង្ករហូបចុកគ្រប់គ្រាន់។ ខ្ញុំនិងគ្រួសារបានដើររើសគួរស្រូវដើម្បីបុកហូប ហើយក្រោយមកទើបជីវភាពរបស់ខ្ញុំបានប្រសើរឡើង។

នៅឆ្នាំ១៩៨១ ខ្ញុំបានចូលបម្រើការងារជាមេភូមិស្រះតាអឹម ដើម្បីជួយដល់ប្រជាជន។ រហូតមកដល់ឆ្នាំ១៩៩៣ ខ្ញុំបានផ្លាស់ទៅធ្វើជានគរបាល ស្រុកមេសាង បានរយៈពេលមួយឆ្នាំក៏ឈប់ ហើយត្រឡប់មករស់នៅ និងធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ។



គង់ ស៊ីម អាយុ៧២ឆ្នាំ រស់នៅភូមិស្រះតាអឹម ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំគឺជាពេទ្យស្ម័គ្រចិត្តបដិវត្តន៍

***អ៊ុន សុជាទី***



ព្រំ ណៃ រស់នៅក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ព្រំ ណៃ កើតនៅក្នុងឆ្នាំ ១៩៦០ នៅក្នុងភូមិប្រាំង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង។ ក្រុមគ្រួសាររបស់ខ្ញុំមានសមាជិកចំនួន១០នាក់។ ម្ដាយរបស់ខ្ញុំឈ្មោះ ព្រំ ឈោក ស្លាប់ក្នុងឆ្នាំ១៩៩៦ ចំណែកឯឪពុករបស់ខ្ញុំឈ្មោះ វីរ សៀង ស្លាប់នៅក្នុងឆ្នាំ១៩៧៧ ហើយខ្ញុំមានបងប្អូនចំនួន ៨ នាក់រួមទាំងខ្ញុំដែលជាកូនច្បងនៅក្នុងគ្រួសារ។

ក្រុមគ្រួសាររបស់ខ្ញុំគឺជាអ្នកស្រែចម្ការ។ ឪពុកម្ដាយរបស់ខ្ញុំប្រកបមុខរបរធ្វើស្រែដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ដោយសារតែបញ្ហាជីវភាពគ្រួសារប្រឈមនឹងការលំបាកខ្លាំង ខ្ញុំមិនបានរៀនសូត្រឡើយ។ ខ្ញុំមិនអាចសរសេរអក្សរបានទេ ប៉ុន្តែខ្ញុំចេះអានអក្សរបានបន្តិចបន្តួច ដែរ។

ដំណើរជីវិតរបស់ខ្ញុំតស៊ូជាមួយនឹងខ្មែរក្រហមបានចាប់ផ្ដើមតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ នៅពេលដែលខ្ញុំបានសម្រេចចិត្តចូលធ្វើពេទ្យបដិវត្តន៍។ រយៈពេល៣ឆ្នាំបន្ទាប់ពីសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែងខ្ញុំបានស្ម័គ្រចិត្តចេញធ្វើបដិវត្តន៍នៅក្នុងស្រុករបស់ខ្ញុំ។ ពេលនោះ ខ្ញុំទើបតែមានអាយុប្រហែល ១៣ឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែដោយសារតែជីវភាពខ្វះខាត ខ្ញុំបានចូលធ្វើជាពេទ្យនៅឃុំដងពែងក្នុងស្រុកកំណើតរបស់ខ្ញុំ។

រហូតមកដល់ឆ្នាំ១៩៧៤ ខ្ញុំបានផ្លាស់មកធ្វើពេទ្យនៅឯពេទ្យស្រុកស្រែអំបិលវិញ។ ខ្ញុំចាំបានថា មានក្មេងស្រីៗដែលមានអាយុស្របក់ស្របាលនឹងខ្ញុំហើយក៏មានក្មេងស្រីដែលមានវ័យក្មេងជាងខ្ញុំជាច្រើននាក់បានស្ម័គ្រចិត្តធ្វើពេទ្យបម្រើឲ្យបដិវត្តន៍ដូចខ្ញុំដែរ។

មុនពេលចូលធ្វើជាពេទ្យ ខ្ញុំមិនធ្លាប់បានរៀនអំពីវិជ្ជាពេទ្យអ្វីនោះទេ។ វាគឺថ្មីសន្លាងសម្រាប់ខ្ញុំ។ នៅពេលដែលខ្ញុំចាប់ផ្ដើមរៀនដំបូង គឺខ្ញុំគ្រាន់តែមើលពេទ្យបងៗព្យាបាលរបួសឲ្យអ្នកជំងឺ ហើយបន្ទាប់មកខ្ញុំសាកល្បងព្យាបាលទៅតាមអ្វីដែលខ្ញុំបានឃើញនិងចងចាំ។ គ្រូពេទ្យបដិវត្តន៍ជាច្រើនទៀតរៀនសូត្រអំពីការព្យាបាលជំងឺ តាមវិធីសាស្ត្រដូចដែលខ្ញុំបានរៀនដែរ។ក្នុងវ័យ១៣ឆ្នាំ ក្រៅពីចេះព្យាបាលជំងឺ និងរបួស ខ្ញុំថែមទាំងចេះវិជ្ជាឆ្មបទៀត។ មិនយូរប៉ុន្មានខ្ញុំចាប់ផ្ដើមព្យាបាលជំងឺ និងរបួសឲ្យប្រជាជននិង

កងទ័ព។

នៅក្នុងឆ្នាំ១៩៧៨ដដែល ប្រជាជនភាគច្រើនកើតជំងឺគ្រុនចាញ់ ហើយកងទ័ពក៏មានរបួសច្រើនពីការប្រយុទ្ធគ្នាដែរ។ ខ្ញុំត្រូវនៅព្យាបាលអ្នកជំងឺទាំងយប់ទាំងថ្ងៃមិនសូវមានពេលសម្រាកឡើយ ប៉ុន្តែខ្ញុំមានសំណាងល្អដែលមានអាហារហូបគ្រប់គ្រាន់។

រហូតដល់ពេលខ្មែរក្រហមឡើងកាន់កាប់អំណាចជាផ្លូវការនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជ្រើសរើសខ្ញុំឲ្យមកធ្វើពេទ្យនៅតាមភូមិវិញ។ ខ្ញុំបានដើរព្យាបាលជំងឺរបស់ប្រជាជននៅតាមភូមិ និងតាមមន្ទីរតំបន់ ពីតំបន់មួយទៅតំបន់មួយ។

មានរឿងរ៉ាវជាច្រើនបានកើតឡើងនៅមន្ទីរពេទ្យ និងមានការធ្វើទុក្ខបុកម្នេញចំពោះជីវិតប្រចាំថ្ងៃរបស់ប្រជាជន។ ចាប់ពីឆ្នាំ១៩៧៦ នៅភូមិភាគបស្ចិម មានការធ្វើបាបប្រជាជនយ៉ាងខ្លាំងព្រោះតែ តាទីន ដែលជាប្រធានគណៈតំបន់បានក្បត់នឹងអង្គការ។ ការកាប់សម្លាប់ដោយសារតែការសង្ស័យថាក្បត់ ការបង្អត់អាហារ ការធ្វើការលើសកម្លាំង និងជំងឺ បានធ្វើឲ្យប្រជាជនស្លាប់ស្ទើរតែរៀងរាល់ថ្ងៃ។

ប្រជាជន១៧មេសា ទាំងស្រីទាំងប្រុស ត្រូវបានអង្គការបញ្ជូនឲ្យទៅរស់នៅក្នុងកងចល័ត ដោយបានបង្ខំឲ្យលើកទំនប់នៅបឹងព្រាវបណ្តាលឲ្យស្លាប់អស់ជាច្រើននាក់។ ចំណែកឯគ្រូពេទ្យដូចខ្ញុំក៏មិនត្រូវបានលើកលែងពីការសម្លាប់ដែរ។ យើងបានប្រឈមមុខនឹងការសម្លាប់ពីខ្មែរក្រហមដូចប្រជាជនឯទៀត ប្រសិនបើ ខ្មែរក្រហមមានការសង្ស័យថា យើងធ្វើខុសអ្វីមួយនោះ។

រឿងរ៉ាវរបស់ពេទ្យស្រីម្នាក់ឈ្មោះ រ៉ាន បានធ្វើឲ្យខ្ញុំនឹកឃើញដល់ជីវិតបងប្អូន និងឪពុកម្តាយរបស់ខ្ញុំនៅពេលនោះ។ ពេទ្យ រ៉ាន ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា បានប្រព្រឹត្តខុសសីលធម៌ជាមួយនឹងកងទ័ពម្នាក់រហូតដល់មានផ្ទៃពោះ។ ខ្មែរក្រហម បានយកកងទ័ពនោះទៅវាយសម្លាប់ និងបណ្តែតតាមទឹក ចំណែកឯពេទ្យ រ៉ាន វិញត្រូវខ្មែរក្រហមវះពោះយកកូនចេញយ៉ាងសាហាវឃោរឃៅនៅក្នុងទឹកប្រឡាយដែលខ្ញុំមិនធ្លាប់ឃើញដូច្នេះពីមុនមក។

បន្ទាប់ពីឃើញរូបភាពនៃការសម្លាប់នេះដោយផ្ទាល់នឹងភ្នែក ខ្ញុំតែងតែស្រមៃដល់ការស្លាប់របស់ឪពុកខ្ញុំ ដែលប្រហែលជាខ្មែរក្រហមយកគាត់ទៅសម្លាប់ដូចពេទ្យរ៉ាន និងគូស្នេហ៍របស់គាត់។ នៅក្នុងរបបខ្មែរក្រហម ឪពុករបស់ខ្ញុំធ្វើជាមេភូមិ។ គាត់ត្រូវរងការចោទប្រកាន់យ៉ាងអយុត្តិធម៌ថា គាត់បានប្រព្រឹត្តខុសសីលធម៌ទើបបណ្តាលឲ្យខ្មែរក្រហមយកគាត់ទៅសម្លាប់នៅក្នុងឆ្នាំ១៩៧៧។ ពេលនោះខ្ញុំមិនបាននៅក្បែរឪពុករបស់ខ្ញុំទេ ព្រោះខ្ញុំបានចាកចេញទៅធ្វើការនៅភូមិឆ្ងាយពីគាត់។

ក្រៅពីឪពុករបស់ខ្ញុំ ជីតា ជីដូន និងប្អូនប្រុសរបស់ខ្ញុំក៏ត្រូវបានខ្មែរក្រហមសម្លាប់។ ជីតារបស់ខ្ញុំត្រូវខ្មែរក្រហមចោទប្រកាន់ថា លួចគោរបស់អង្គការចំនួន ២ក្បាល បន្ទាប់ពីគាត់ធ្វើឲ្យបាត់គោនៅក្នុងព្រៃ ពេលដែលគាត់ទៅឃ្វាលគោ។ កាលនោះក្នុងខេត្តកោះកុងសម្បូរទៅដោយព្រៃទ្រុបទ្រុល និងសត្វព្រៃជាច្រើន ទើបបណ្តាលឲ្យជីតារបស់ខ្ញុំពិបាកក្នុងការគ្រប់គ្រងគោទាំងអស់នោះ។ បងប្អូនជីដូនមួយរបស់ខ្ញុំបានប្រាប់ខ្ញុំថា គាត់បានលួចមើលឃើញកងឈ្លបភូមិបង្ខំឲ្យជីតារបស់ខ្ញុំចូលទៅក្នុងចម្ការអំពៅមួយកន្លែង រួចបង្ខំឲ្យគាត់ហូបស្លឹកអំពៅ។ បន្ទាប់មក កងឈ្លបក៏បានវាយសម្លាប់ជីតារបស់ខ្ញុំចោលនៅក្នុងចម្ការអំពៅនោះ។ ចំណែកឯ ជីដូន របស់ខ្ញុំបានឈឺស្លាប់ដោយសារមិនអាចអត់ទ្រាំនឹងការអត់អាហារបាន។ រីឯប្អូនរបស់ខ្ញុំវិញក៏ត្រូវខ្មែរក្រហមសម្លាប់ខណៈពេលចែវទូកទៅកាប់ផ្តៅនៅអុកតាមៀក ខេត្តកោះកុង។

ក្រោយមក ក៏មានការតាមដានសមាជិកគ្រួសាររបស់ខ្ញុំផ្សេងទៀតរួមទាំងខ្ញុំដែរ។ ខ្ញុំបានជួបរឿងរ៉ាវតក់ស្លុត និងឈឺចាប់ជាច្រើន។ ប្រធានពេទ្យឈ្មោះ រឿន តែងតែលើកទឹកចិត្តឲ្យខ្ញុំធ្វើល្អ និងគិតល្អទើបខ្ញុំអាចរក្សាជីវិតបាន។ ទោះបីជាយ៉ាងណា ខ្ញុំនៅតែគិតថា ខ្ញុំមានសំណាងជាងសាច់ញាតិ និងប្រជាជនដទៃទៀត។ ខ្ញុំទទួលបានបបរ សម្លមានសាច់ត្រី ត្រីខ ត្រីចំហុយ ប៉ុន្តែប្រជាជនផ្សេងទទួលបានតែបបររាវ

ដោយមើលសឹងតែមិនឃើញគ្រាប់អង្ករហើយ ថែមទាំងធ្វើការងារលំបាកវេទនា ទាំងយប់ទាំងថ្ងៃ។

ខ្ញុំធ្វើពេទ្យដល់ចុងឆ្នាំ១៩៧៨ រួចខ្ញុំចាកចេញពីកន្លែងពេទ្យមករស់នៅជាមួយប្រជាជនតាមតំបន់វិញ ហើយយើងរត់ភៀសខ្លួនទៅជាមួយគ្នានៅពេលកងទ័ពវៀតណាមវាយចូលមកក្នុងប្រទេសកម្ពុជា នៅដើមខែមករា ឆ្នាំ១៩៧៩។

ខ្ញុំមានបំណងវិលត្រឡប់ទៅស្រុកកំណើតរកម្តាយ និងបងប្អូនរបស់ខ្ញុំ ប៉ុន្តែនៅតាមផ្លូវ ខ្ញុំបានជួបនឹងកងទ័ពខ្មែរក្រហម ដែលបានប្រាប់ខ្ញុំថា កងទ័ពវៀតណាមកំពុងតែវាយនៅតាមទិសដៅដែលខ្ញុំកំពុងតែធ្វើដំណើរឆ្ពោះទៅ។ ព្ធដូច្នេះ ខ្ញុំបានសម្រេចចិត្តមិនបន្តដំណើរទៅមុខទៀតទេ ហើយធ្វើដំណើរត្រឡប់បកក្រោយសំដៅទៅភ្នំវិញ ដើម្បីគេចខ្លួនពីកងទ័ពវៀតណាម។ ចុងក្រោយ ខ្ញុំបានធ្វើដំណើរទៅដល់ជំរំម៉ៃរ៉ូតនៅក្នុងប្រទេសថៃ ដែលមានប្រជាជនខ្មែរជាច្រើនធ្វើដំណើរទៅកាន់ទីនោះ និងត្រៀមចាកចេញទៅកាន់ប្រទេសទី៣ ដូចជា សហរដ្ឋអាមេរិក ប្រទេសបារាំង និងប្រទេសកាណាដា ជាដើម។ ខ្ញុំបានសម្ភាសន៍ជាប់ និងត្រូវចាកចេញទៅរស់នៅឯសហរដ្ឋអាមេរិក ប៉ុន្តែពេលនោះខ្ញុំស្ទាក់ស្ទើរក្នុងចិត្តព្រោះខ្ញុំគ្មានក្រុមគ្រួសារ និងសាច់ញាតិនៅសហរដ្ឋអាមេរិកទេ ហើយខ្ញុំក៏នឹករឭកដល់ក្រុមគ្រួសាររបស់ខ្ញុំណាស់ ដូច្នេះហើយ ខ្ញុំបានសម្រេចចិត្តមិនចាកចេញ។

មិនយូរប៉ុន្មាននៅពេលដែលមានការជ្រើសរើសកងកម្លាំងស្ម័គ្រចិត្ត ខ្ញុំបានសម្រេចចិត្តចូលបម្រើឲ្យកងកម្លាំងខ្មែរក្រហមម្តងទៀត ក្នុងគោលបំណងរិះរកវិធីត្រឡប់មកចូលក្នុងប្រទេសខ្មែរវិញតាមរកម្តាយរបស់ខ្ញុំ។ ប៉ុន្តែដោយសារស្ថានភាពមិនទាន់ស្ងប់ស្ងាត់នៅក្នុងប្រទេស ខ្ញុំនៅតែមិនទាន់បានជួបម្តាយ និងប្អូនៗរបស់ខ្ញុំ។ មិនយូរប៉ុន្មាន ខ្ញុំមានសំណាងបានជួបប្អូនៗ និងបងប្អូនជីដូនមួយរបស់ខ្ញុំវិញ ប៉ុន្តែខ្ញុំបានទទួលដំណឹងអកុសលពីប្អូនរបស់ខ្ញុំថា ម្តាយរបស់ខ្ញុំដែលខ្ញុំតែងតែទន្ទឹងរង់ចាំជួប និងនឹករឭកជារៀងរាល់ថ្ងៃបានស្លាប់ទៅហើយ។

ខ្ញុំបានធ្វើដំណើរទៅលេងស្រុកកំណើតតែម្តងប៉ុណ្ណោះក្នុងឆ្នាំ២០០១។ ខ្ញុំនិងប្អូនៗតែងតែទំនាក់ទំនងសួរសុខទុក្ខគ្នាតាមរយៈទូរសព្ទ។ ចាប់តាំងពីប្រធានកងពលនារី រៀបចំមង្គលការឲ្យខ្ញុំនិងប្តីរបស់ខ្ញុំ យើងបានសម្រេចចិត្តរស់នៅក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដោយប្រកបរបរធ្វើចម្ការរហូតដល់សព្វថ្ងៃនេះ។



ទេសភាពស្ទឹងនៅរដូវវស្សា ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញឹម សំកើ៖ គ្រួសារខ្ញុំត្រូវជម្លៀស ទៅកាន់ស្រុក១០៩

## ដោយសារកំហឹងរបស់កូនស្រីតាម៉ុក

*ផេង ពង្សរ៉ាស៊ី*



ញឹម សំកើ រស់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ញឹម សំកើ បាននិយាយទាំងអស់សំណើចនៅក្រោមរោងលំហែប្រក់ស័ង្កសីនៅចំហៀងផ្ទះ ដោយបែរមុខទៅរកប្រពន្ធរបស់គាត់ឈ្មោះ ណុប សំ អាយុ៧៨ឆ្នាំថា ការជម្លៀសប្រជាជនមួយភូមិចេញទៅស្រុក១០៩ គឺកើតចេញពីកំហឹងរបស់កូនស្រីតាម៉ុក ឈ្មោះ ខុម ដែលជាគណៈឃុំត្រពាំងធំខាងត្បូងក្នុងអំឡុងឆ្នាំ១៩៧៧។ ប្រពន្ធរបស់ សំកើ ក្នុងសម្លៀកបំពាក់ជាអ្នកស្រែប្រឡាក់ដីស្រមកបានបង្ហាញទឹកមុខហួសចិត្ត និងមិនបានតបតអ្វីឡើយក្នុងពេលដែលប្ដីរបស់គាត់កំពុងផាកមើលគាត់ និងនិយាយពីរឿងនេះ។ ឆ្នាំនេះ សំកើ មានអាយុ៧៧ឆ្នាំហើយ។ គាត់មិនប្រកបរបរអ្វីទេ ក្រៅពីជួយការងារស្រែចម្ការនៅជុំវិញផ្ទះរបស់គាត់នៅក្នុងភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។ សំកើ បានរៀបរាប់ពីហេតុការណ៍ដ៏ហួសចិត្តនេះថា ៖

«នៅឆ្នាំ១៩៧៧ មិនចាំខែ តាម៉ុក ហៅតា១០៥ បានចូលមកកាន់ឃុំត្រពាំងធំខាងត្បូង ដែលជាស្រុកកំណើត ស្របពេលដែលកូនស្រីគាត់ឈ្មោះ (យាយ) ខុម កាលនោះគឺជាគណៈឃុំត្រពាំងធំខាងត្បូង កំពុងចែកខោអាវចាស់ៗដែលជាខោអាវគេប្រើរួច ដល់ប្រជាជនដែលកំពុងប្រូតស្រូវនៅភូមិត្រពាំងស្វាយ។ តាម៉ុក បានចូលមកកន្លែងដែលកូនគាត់កំពុងចែកខោអាវ។ គ្រាន់តែឃើញ តាម៉ុក មកដល់ភ្លាម យាយ អ៊ុន ប្រពន្ធតា ស៊ុក បានស្ទុះទៅជួបគាត់រួចរាយការណ៍ថាប្រជាជនក្នុងភូមិនេះក្រណាស់ខ្វះខាត និងគ្មានអ្វីហូបគ្រប់គ្រាន់ឡើយ។ ដល់អ៊ីចឹង! តាម៉ុក ខឹងណាស់ ហើយក៏ហៅ ខុម មកស្ដីឲ្យ (ស្ដីបន្ទោស) ថា ខុម អត់បេះមើលប្រជាជន ធ្វើឲ្យប្រជាជនត្អូញត្អែរប្រាប់គាត់ពីរឿងខ្វះខាត។ ខុម ហ្នឹងគេខឹងរួចចេញទៅបាត់។ ភ្លាមៗក្រោយមក គេក៏មកប្រាប់ឲ្យប្រជាជនទាំងអស់រស់នៅភូមិត្រពាំងស្វាយហ្នឹងឲ្យផ្លាស់ប្ដូរទីលំនៅទៅកាន់ភូមិដើមបេង ឃុំដើមបេង ខាងលិចភ្នំដិន ស្ថិតក្នុងស្រុក១០៩ ទាំងអស់គ្នាហ្មង់ទៅ។ ប្រជាជនគ្រប់គ្នាសុទ្ធតែដឹងថា ការផ្លាស់

ប្តូរទីលំនៅនេះ គឺផ្តើមចេញពីកំហឹងរបស់ ខុម ចំពោះសេចក្តីរាយការណ៍របស់ យាយ អ៊ុន ប្រាប់ដល់ឪពុករបស់គាត់។ កាលនោះ ខ្ញុំនិងប្រពន្ធកូនខ្ញុំ មានរទេះមួយ។ យើងធ្វើដំណើរតាមរទេះគោ ហ្នឹងរហូតទាល់តែដល់ភូមិបេង។ ពួកយើងធ្វើដំណើរដង្ហែគ្នាចាកចេញពីភូមិតាមថ្នល់ជាតិឆ្ពោះទៅស្រុក១០៩។ នៅតាមផ្លូវ យើងមានអង្ករបន្តិចបន្តួចគ្រាន់នឹងដាំបាយហូប។ ត្រឹមតែរយៈពេលមួយថ្ងៃទេ ពួកយើងបានទៅដល់ភូមិបេង ជាកន្លែងដែលពួកយើងរស់នៅអស់រយៈពេលជាងមួយឆ្នាំ។ នៅទីនោះ គេឲ្យពួកយើងស្នាក់នៅក្នុងខ្ទមតូចៗជាច្រើន ដែលបានត្រៀមទុករួចជាស្រេចៗ ខ្ញុំស្នាក់នៅក្នុងខ្ទមប្រក់ស្លឹក និងជញ្ជាំងពាសស្លឹកដូង។ តា ហួន ជាមនុស្សទៅពីស្រុកត្រាំកក់នេះ គឺជាគណៈឃុំដើមបេង។ យើងស្គាល់គ្នា ហើយ តា ហួន ក៏មិនបានធ្វើបាបអ្វីដល់យើងច្រើនពេកដែរ។ ពួកយើងភាគច្រើនហូបតែបបរទេ។ ជួនកាល ហូបបបរលាយពោតក្រហម។ ជួនកាល ហូបបាយលាយគល់ក្តួចៗ ប្រពន្ធខ្ញុំជាអ្នកលាងក្តួច និងភ្លក់ក្តួចមុននឹងយកទៅលាយជាមួយបាយចែកឲ្យអ្នកផ្សេងទៀត»។

ស្ថិតក្នុងស្រុក១០៩ ញឹម សំកើ និងគ្រួសារ មិនដែលបានចាកចេញពីកន្លែងដែលគាត់ស្នាក់នៅ និងទៅធ្វើការនៅកន្លែងផ្សេងឡើយ។ គាត់ភ្ជួរដីរាស់ដីនិងធ្វើស្រូវ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ សំកើ បាននិយាយថា គាត់ពុំដែលឃើញអ្នកស្រុក១០៩ណាម្នាក់ទាល់តែសោះ។ សំកើ បានសន្និដ្ឋានថា អ្នកទាំងនោះបានចាកចេញពីស្រុកកំណើតរបស់ខ្លួនទៅនៅឆ្ងាយ ប៉ុន្តែមិនដឹងទៅកាន់ទីកន្លែងណា។

នៅឆ្នាំ១៩៧៩ សំកើ និងគ្រួសារ បានវិលត្រឡប់មកកាន់ស្រុកកំណើតរបស់ខ្លួនវិញតាមរទេះគោរបស់គាត់ដដែល។ នៅតាមផ្លូវត្រឡប់មកផ្ទះ គាត់និងគ្រួសារត្រូវបានឃាត់សួរនាំម្តងនៅដំណាក់ក្រសាំង។ បន្ទាប់មក គាត់បានធ្វើដំណើរមកដល់ស្រុកកំណើត និងបន្តដំណើរទៅកាន់ស្រុកកំណើតឪពុកក្មេកនៅឃុំស្រែចែង ស្រុកជុំគីរី ខេត្តកំពត ដើម្បីស្នាក់នៅជាបណ្តោះអាសន្ន មុនពេលដែលគាត់វិលត្រឡប់មកកាន់ស្រុកកំណើតវិញនៅក្នុងរដូវប្រូតឆ្នាំ១៩៧៩។ «នៅរដូវប្រូត ឆ្នាំថោះ ខ្ញុំនិងប្រពន្ធបានចេញដំណើរមកស្រុកកំណើត ដោយសារកងទ័ពវៀតណាមចូលមកវាយបណ្តេញខ្មែរក្រហមយ៉ាងប្រសេចប្រសាចពេញស្រុក១០៩។ យើងបានមកដល់ដំណាក់ក្រសាំង ហើយត្រូវខ្មែរក្រហមឃាត់ដំណើរសួរនាំពីការចាកចេញរបស់ខ្ញុំ។ ពេលខ្ញុំមកដល់ស្រុកកំណើតឪពុកមារ ខាងប្រពន្ធខ្ញុំបានឃាត់មិនឲ្យខ្ញុំរត់ទៀតទេ ប៉ុន្តែខ្ញុំមិនស្តាប់គាត់។ ខ្ញុំបានលួចរត់ទៅកាន់ស្រុកឪពុកក្មេកខ្ញុំនៅឃុំស្រែចែង ស្រុកជុំគីរី ខេត្តកំពត។ ខ្ញុំស្នាក់នៅទីនោះបីបួនខែទៀត ទើបខ្ញុំសម្រេចចិត្តចាកចេញមកកាន់ស្រុកវិញ។ ពេលធ្វើដំណើរមកដល់វត្តបក ក្នុងស្រុកជុំគីរីដដែល ប្រពន្ធខ្ញុំឈឺពោះឆ្លងទន្លេកូនស្រីទី ៤ ។ ខ្ញុំបានដើររកឆ្មបមកបង្កើតរហូតទាល់តែជួប ហើយពេទ្យឆ្មបនោះបានជួយសម្រាលកូនរបស់ខ្ញុំបានជោគជ័យ។ ពួកយើងបានមកដល់ស្រុកកំណើតវិញ និងបានកសាងជីវិត និងគ្រួសារឡើងវិញរហូតដល់ពេលនេះ។»

សំកើ មិនដែលនិយាយរឿងរ៉ាវរបស់គាត់ឆ្លងកាត់របបខ្មែរក្រហមប្រាប់ទៅកូនៗរបស់គាត់ឡើយ ព្រោះគាត់គិតថាជាការឥតប្រយោជន៍ និងជាកំហឹងរបស់បុគ្គលម្នាក់ដែលធ្វើឲ្យប្រជាជនដែលមិនដឹងអ្វីទាល់តែសោះត្រូវជម្លៀសចេញពីស្រុកកំណើត។ គាត់ក៏មិនបានដឹងដែរថា តើ ខុម ដែលជាកូនរបស់តាម៉ុក មានវាសនាយ៉ាងដូចម្តេចដែរ? ហើយក៏មិនបានចាប់ទោសអូសដំណើរអ្វីដល់ ខុម ក្នុងពេលនោះដែរ ព្រោះគាត់សំអាងថា ខុម គឺជាកម្មាភិបាលថ្នាក់លើម្នាក់ ដែលមានសិទ្ធិក្នុងការធ្វើអ្វីគ្រប់បែបយ៉ាងបានតាមអំពើចិត្ត។ ផ្ទុយទៅវិញ សំកើ បែរជាហួសចិត្តនិងអស់សំណើចនៅពេលដែលគាត់រំឭករឿងនេះប្រាប់យើង ក្នុងអំឡុងពេលជាង៤៣ឆ្នាំក្រោយរបបខ្មែរក្រហមដួលរលំទៅ។

# គី ហៀង៖ ខ្ញុំចូលធ្វើទ័ពខ្មែរក្រហមដោយសារកំហឹង

*ផេង ពង្សរ៉ាស៊ី*



គី ហៀង សព្វថ្ងៃរស់នៅភូមិត្រពាំងតាសោម ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

គី ហៀង កើតក្នុងគ្រួសារក្រីក្រមួយកាលពីទសវត្សរ៍ឆ្នាំ១៩៥០។ គាត់មិនបានរៀនជ្រៅជ្រះដូចក្មេងឯទៀតក្នុងភូមិឡើយ។ ហៀង នៅតែរំពុកពីរឿងនេះថា គាត់ខ្មាស់ក្មេងឯទៀត និងមិនហ៊ានលេចមុខឲ្យអ្នកទាំងនោះឃើញឡើយ ព្រោះគាត់មិនបានបន្តការសិក្សាទៀតដោយសារឪពុកម្តាយក្រីក្រ។ នៅក្នុងបន្ទុកឪពុកម្តាយ ហៀង តែងតែជួយសម្រាលការងារផ្ទះជំនួសឪពុកម្តាយ ដូចជា ធ្វើស្ករត្នោត និងធ្វើស្រែ។ នៅឆ្នាំ១៩៧១ ហៀង បានរៀបការតាមឪពុកម្តាយផ្សំផ្គុំឲ្យ។ នៅឆ្នាំ១៩៧៣ ហៀង បានចេញទៅធ្វើបដិវត្តន៍ ក្នុងពេលដែលគាត់មានកូនពីរនាក់ក្នុងបន្ទុក។ គាត់បានចាកចោលប្រពន្ធ និងកូនដោយសារតែកំហឹងវណ្ណៈ និងចង់បានសង្គមមួយដែលគ្មានវណ្ណៈជិះជាន់។ ខាងក្រោមនេះ គឺជាការរៀបរាប់របស់ ហៀង អំពីដំណើរជីវិតចាកចេញពីផ្ទះដើម្បីបដិវត្តន៍ និងរឿងរ៉ាវជីវិតជាយុទ្ធជន ដែលចាប់ផ្តើមពីយុទ្ធជនខ្មែរក្រហម រហូតប្រែជាយុទ្ធជនប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហមវិញក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០៖

## ស្ម័គ្រចិត្តចូលបម្រើកងទ័ពដោយសារកំហឹងវណ្ណៈ

នៅឆ្នាំ១៩៧៣ គី ហៀង បានស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហម ដោយសារមិនពេញចិត្តចំពោះព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ និងស្អប់ខ្ពើមភាពខែងរឹងរបស់មេទ័ពនៃរបប លន់ នល់ ឈ្មោះ ហ៊ិន ទឹម ដែលតែងតែបង្ហាញភាពអស្ចារ្យរបស់ខ្លួនក្នុងការដឹកនាំទ័ពចូលទៅវាយកងកម្លាំងខ្មែរក្រហមនៅតាមជើងភ្នំជីរមៀល កាលពីអំឡុងដើមទសវត្សន៍ឆ្នាំ១៩៧០។ «ខ្ញុំឃើញមេទាហាន លន់ នល់ ម្នាក់ឈ្មោះ ហ៊ិន ទឹម ដើរកាន់ឈើច្រត់នៅពីមុខកងទ័ពរបស់គាត់ ចេញពីវាយប្រហារកងកម្លាំងខ្មែរក្រហមនៅក្នុងព្រៃកាត់តាមភូមិខ្ញុំ ហើយមើលទៅគាត់បញ្ចេញឫកពារក្រអឺតក្រទមណាស់។ នរណាៗក៏ខ្លាចគាត់ដែរ។ កាលពីមានព្រឹត្តិការណ៍ឃាតកម្មនៅអង្គតាសោមថ្ងៃ១៨ មីនា ១៩៧០ តា ហ៊ិន ទឹម នេះបានបាញ់សម្លាប់សិស្សនិស្សិត និងប្រជាជនដែលចូលរួមធ្វើបាតុកម្មច្រើននាក់ណាស់។ ខ្ញុំមិនពេញចិត្តចំពោះឫកពារដូច្នេះទេ

ហើយក៏មិនចង់ឃើញគាត់ដើរប្រងើងប្រង៉ាងនៅក្នុងភូមិខ្ញុំតទៅទៀតដែរ»។

តី ហៀង បានចាកចេញពីផ្ទះនៅវេលាម៉ោងប្រហែល៩ព្រឹក ឆ្ពោះទៅកាន់មន្ទីរឃុំត្រពាំងធំខាងត្បូង ដើម្បីសុំចុះឈ្មោះចូលបម្រើកងទ័ពខ្មែរក្រហម។ គណៈឃុំឈ្មោះ ហួន និង ចិន ជាអ្នកទទួល ហៀង ឲ្យចូលបម្រើបដិវត្តន៍។ ទៅជាមួយ ហៀង មានឈ្មោះ សុន (បច្ចុប្បន្នជាមេភូមិមួយក្នុងឃុំត្រពាំងធំខាងត្បូង), លីន (ស្លាប់), ម៉ៅ ម៉ាក់ (ស្លាប់), ឃឹម ថន (នៅរស់) និង យា មាន (ស្លាប់)។ ដំបូងឡើយ អ្នកទាំង៦នាក់ ត្រូវបញ្ជូនទៅកាន់មន្ទីរស្រុកដើម្បីរៀនក្បួនយុទ្ធសាស្ត្រ និងចូលធ្វើជាកងទ័ពស្រុកត្រាំកក់។ បន្ទាប់មក អ្នកទាំងនោះត្រូវបានបញ្ជូនទៅកាន់តំបន់១៣ ដើម្បីត្រៀមប្រយុទ្ធជាមួយទាហាន លន់ នល់។ «ខ្ញុំបានចេញពីផ្ទះនៅម៉ោង៩ព្រឹក នាថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៣។ ខ្ញុំបានស្ម័គ្រចិត្តចូលបម្រើកងទ័ពខ្មែរក្រហម។ ខ្ញុំបានបបួលគ្នា៥នាក់ទៀតគឺ សុន, លីន, ម៉ៅ ម៉ាក, ឃឹម ថន និងយា មាន ទៅជាមួយ ដើម្បីបានជាគ្នាទៅ ស្ម័គ្រចិត្តចូលបម្រើកងទ័ព។ ខ្ញុំចូលនៅមន្ទីរឃុំត្រពាំងធំខាងត្បូង ដោយមាន តា ហួន និងតា ចិន គណៈឃុំ ជាអ្នកទទួលពួកខ្ញុំ។ ក្នុងចំណោមគ្នាខ្ញុំទាំង ៦នាក់ មកដល់បច្ចុប្បន្ននេះ ស្លាប់អស់បីនាក់ហើយគឺ លីន, ម៉ាក និងមាន។ កាលពីខ្ញុំចូលធ្វើកងទ័ពដំបូង ខ្ញុំត្រូវមេបញ្ជាការយោធាស្រុកបញ្ជូនឲ្យចូលរៀនក្បួនសឹកនៅដុកសាប ក្នុងឃុំសំរោង ស្រុកត្រាំកក់ ហើយមេបញ្ជាការគឺជាអ្នកបង្រៀនផ្ទាល់។ កាលនោះ ខ្ញុំស្ថិតនៅក្នុងកងស្រុកត្រាំកក់ (យោធាស្រុក)។ មេរៀនដែលខ្ញុំបានរៀនគឺ របៀបលូន និងក្រាប របៀបបាញ់ របៀបដោះគ្រាប់ និងមនោគមវិជ្ជាបដិវត្តន៍»។

## បម្រើការនៅអង្គភាព ៣៣០ តំបន់ ១៣

ហៀងបានចូលរួមធ្វើសង្គ្រាមជាច្រើនសមរភូមិនៅក្នុងស្រុកត្រាំកក់ និងស្រុកគិរីវង់ មុនពេលដែលប្រទេសជាតិត្រូវធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមភាគច្រើនត្រូវបានរំសាយ និងបញ្ជូនមកកាន់ស្រុកកំណើតវិញដើម្បីចូលរួមបង្កបង្កើនផល ហើយមានតែកងទ័ពភាគតិចតែប៉ុណ្ណោះ ដែលទទួលបានការផ្លាស់ប្តូរតួនាទី ឬកន្លែងធ្វើការ។ «ខ្ញុំត្រូវអង្គការថ្នាក់លើផ្ទេរភារកិច្ចឲ្យមកធ្វើការនៅក្នុងអង្គភាព ៣៣០ ជាអង្គភាពបម្រើការខាងផ្នែករោងចក្រខស្បៀងហកម្ម របស់តំបន់១៣ វិញ។ អង្គភាពនេះ មានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ។ ខ្ញុំធ្វើការនៅទីនោះអស់រយៈពេលជាងបីឆ្នាំ ទើបអង្គការស្នើខ្ញុំឲ្យទៅរៀនខាងមុខជំនាញវារីអគ្គិសនីនៅភ្នំពេញ និងកំពង់ស្ពឺត្រង់ចំណុចទំនប់រលាំងជ្រៃ ជាមួយជំនាញការចិន។ ខ្ញុំចេញពីអង្គភាព៣៣០ នៅក្នុងរដូវប្រាំងឆ្នាំ១៩៧៨។ ខ្ញុំធ្លាប់ទទួលបានការតែងតាំងជាជំនួយការអង្គភាពបន្ទាប់ពីអង្គការថ្នាក់លើចាប់ខ្លួន យោគ គឺជាប្រធានអង្គភាព និង សុខ ជាអនុប្រធានអង្គភាព កាលពីឆ្នាំ១៩៧៧។ ក្នុងតំណែងជាជំនួយការ ខ្ញុំបានធ្វើការយ៉ាងជិតស្និទ្ធជាមួយ លាង គឺជាប្រធានអង្គភាពដែលទើបនឹងផ្លាស់មក និង វ៉ាន់ គឺជាអនុប្រធាន រហូតដល់គាត់មានការផ្លាស់ប្តូរមករៀនសូត្របន្ត»។

## ខិលចូលបម្រើការជាកងទ័ពខ្មែរក្រហមម្តងទៀត និងបង្កើតកងថ្មី

ក្នុងព្រឹត្តិការណ៍ច្របូកច្របល់នៅចុងឆ្នាំ១៩៧៨ ជាពេលដែល ហៀង កំពុងបន្តការសិក្សាផ្នែកវារីអគ្គិសនីនៅរលាំងជ្រៃ។ កម្មាភិបាលខ្មែរក្រហមទាំងអស់បានរត់បោលផ្ទះ និងភារកិច្ចរបស់ខ្លួន ហើយរត់ភៀសខ្លួនទៅកាន់ទីជៅចុងក្រោយរបស់ខ្លួននៅភាគខាងលិចប្រទេសកម្ពុជា។ ហៀង និងសមមិត្តរួមជំនាន់ បានរត់ភៀសខ្លួនទៅភាគខាងលិចដូចកម្មាភិបាលខ្មែរក្រហមដទៃទៀត។ គាត់បានធ្វើដំណើរកាត់តាមបុសដង់ អន្ទង់ភ្លៀវ និងឆ្លងកាត់តាមផ្លូវជាតិលេខ៤ឆ្ពោះទៅទិសខាងលិច។ ក្នុងពេលដែលកំពុងភៀសខ្លួននៅតាមផ្លូវ ហៀង និងអ្នកឯទៀតបានជួបមេបញ្ជាការវរសេនាធំ (មិនចាំលេខ) ឈ្មោះ ប៊ូរ៉ាន ហើយត្រូវ ប៊ូរ៉ាន បញ្ចុះបញ្ចូលឲ្យចូល

ក្នុងជួរកងទ័ពឡើងវិញ ដើម្បីតស៊ូ ប្រយុទ្ធប្រឆាំងជាមួយនឹងវត្តមានរបស់កងទ័ពវៀតណាមដែលកំពុងវាយរុញច្រានកងទ័ពខ្មែរក្រហមឲ្យចុះចាញ់ៗ បូរ៉ានបានបំពាក់អាវុធដល់ ហៀង និងយុទ្ធមិត្តឯទៀតព្រមទាំងបានបង្កើតកងថ្មីមួយទៀតឈ្មោះថា «កងពិសេស» ឬ «កងគ្មានលេខ»។ កងនេះ ត្រូវបានបង្កើតឡើងភ្លាមៗ និងមិនមានការចាត់តាំងត្រឹមត្រូវពីថ្នាក់ដឹកនាំភូមិភាគ ឬតំបន់ឡើយ ហើយកងទ័ពដែលមាននៅក្នុងកងនេះ ក៏មិនមានគ្នាច្រើនដែរ។

## បរាជ័យចុងក្រោយ និងការវិលត្រឡប់មកស្រុកកំណើត

បន្ទាប់ពីបង្កើតបានកងថ្មីរួចហើយ កងនេះបានអនុវត្តក្បួនសឹកមួយឈ្មោះថា «ប្រែះស៊ីដែក» ដើម្បីបំផ្លាញ ឬបង្អាក់ដំណើរកងទ័ពវៀតណាមដែលដេញវាយកងទ័ពខ្មែរក្រហមពីក្រោយ។ តាមការឲ្យដឹងពី ហៀង ថា សង្គ្រាមប្រែះស៊ីដែក គឺសំដៅលើសង្គ្រាមឆ្មក់ ឬសង្គ្រាមវាយដកៗ ឬសង្គ្រាមឈ្លប។ នៅដើមឆ្នាំ១៩៧៩ ហៀង និងកងពិសេស រួមទាំង បូរ៉ាន ផងបានចាញ់សង្គ្រាម និងបានដកថយរហូតដល់ភាគខាងលិចប្រទេស។ ក្រោយមក កងពិសេស ឬកងគ្មានលេខ ត្រូវបានរំលាយ។ បូរ៉ាន បានស្លាប់ដោយសារផ្ទុះមីនរបស់ខ្លួនឯង។ អ្នកឯទៀតបានចាកចេញទៅកាន់ទីកន្លែងផ្សេងៗដែលពួកគេចង់ទៅ។ ហៀង បានវិលត្រឡប់មកផ្ទះវិញជាមួយបងប្រុសបង្កើត។ នៅតាមផ្លូវ បងប្រុសរបស់ ហៀង បានស្លាប់ ហើយគាត់បានធ្វើដំណើរទៅដល់ខេត្តកោះកុង ជាកន្លែងដែលគាត់ត្រូវបានចាប់ខ្លួនដោយកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ គាត់ត្រូវបានបញ្ជូនមកកាន់កំពង់សោម ដើម្បីឃុំឃាំង។ នៅខែកក្កដា ឆ្នាំ១៩៧៩ ហៀង ត្រូវបានដោះលែងឲ្យវិលត្រឡប់មកស្រុកកំណើតវិញ។ មុនពេលដោះលែង ហៀង ទទួលបានលិខិតមួយច្បាប់ចេញដោយអាជ្ញាធរខេត្តកំពង់សោម និងមានបោះត្រាក្រហមពីជំនាញការវៀតណាមប្រចាំនៅខេត្តនោះ ដើម្បីឲ្យ ហៀង ប្រើប្រាស់ជាលិខិតបើកផ្លូវសម្រាប់ការធ្វើដំណើរត្រឡប់មកផ្ទះសម្បែងវិញរបស់គាត់។

## ចូលកាន់អាវុធម្តងទៀត ប្រយុទ្ធប្រឆាំងនឹងក្រុមឧទ្ទាមខ្មែរក្រហម

នៅឆ្នាំ១៩៨៣ ហៀង ត្រូវបានស្នើឲ្យចូលធ្វើជាប្រធានភូមិត្រពាំងតាសោម និងគ្រប់គ្រងកងសេនាជនភូមិ។ តាំងពីមានការចាត់តាំងមក ហៀង ពុំសូវបានស្នាក់នៅផ្ទះនៅពេលយប់ទេ។ ហៀង និងសេនាជនក្នុងភូមិ ត្រូវទទួលបន្ទុកយាមកាមភូមិ និងត្រៀមប្រយុទ្ធគ្រប់ពេលជាមួយក្រុមឧទ្ទាមខ្មែរក្រហមដែលមានមូលដ្ឋាននៅក្នុងព្រៃនាជើងភ្នំដំរីរមៀល។ ភារកិច្ចនេះ ត្រូវ ហៀង កាន់ក្តាប់រហូតដល់គាត់ទទួលបានការប្រកាសថ្មីមួយទៀតថា ជាកងជីវពលប្រចាំស្រុកត្រាំកក់ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៩៨ និងចេញប័ណ្ណប្រើប្រាស់ចុះហត្ថលេខាដោយវរៈសេនីយ៍ឯក កង សំអឿន។ ប័ណ្ណដដែលនេះ បានបញ្ជាក់ថា ហៀង ទទួលបានការប្រើប្រាស់អាវុធប្រភេទអាកា លេខ៦៦៦១៦ សម្រាប់ការពារភូមិឃុំពីការវាយឆ្មក់នានាពីទ័ពព្រៃខ្មែរក្រហមដែលមានទីតាំងស្ថិតនៅជើងភ្នំដំរីរមៀល។ សុពលភាពនៃការប្រើប្រាស់អាវុធ និងប័ណ្ណសម្គាល់របស់ ហៀង បានបញ្ចប់នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨។

## ជីវិតសាមញ្ញនាពេលបច្ចុប្បន្ន

សព្វថ្ងៃ ហៀង មានអាយុ៧២ឆ្នាំហើយ។ គាត់បានស្នើសុំឈប់បម្រើការជាមេភូមិនៅឆ្នាំ២០១៨ បន្ទាប់ពីគាត់បានបម្រើការជាមេភូមិអស់រយៈពេលជាង៣០ឆ្នាំរួចមក។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏គាត់នៅតែជាអ្នកជួយជ្រោមជ្រែង និងចាត់ចែងការងារនៅក្នុងភូមិដដែល។ ជារៀងរាល់ថ្ងៃសីល ហៀង តែងទៅកាន់វត្តអារាមដែលនៅក្បែរផ្ទះរបស់គាត់ ស្ថិតនៅជាប់នឹងជើងភ្នំដំរីរមៀល ដើម្បីសុំសីល និងរៀបចំកម្មវិធីសាសនាផ្សេងៗ។ ហៀង បានប្រាប់ថា ជីវិតគាត់នាពេលបច្ចុប្បនេះ គឺគិតតែពីការសាងបុណ្យកុសលដើម្បីគាត់ទទួលបានការតបស្នងមកវិញនូវ សេចក្តីសុខផ្លូវអារម្មណ៍ និងផ្លូវចិត្ត។

# យុវជនមកពីស្រុកកំចាយមារ

## ស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង នាចុងសប្តាហ៍

ភា រស្មី



យុវជនមកពីស្រុកកំចាយមារស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅការិយាល័យរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង បានស្វាគមន៍ដំណើរមកកាន់ការិយាល័យរបស់ខ្លួន ពីសំណាក់ក្រុមយុវជននិងយុវនារី ចំនួន ៤៣នាក់ ក្នុងនោះមានស្រី២៨នាក់មកពីស្រុកកំចាយមារខេត្តព្រៃវែង។ យុវជនទាំងនេះ បានចំណាយពេលវេលារបស់ខ្លួនបន្ទាប់ពីសម្រាកពីការសិក្សានៅក្នុងវិទ្យាល័យហ៊ុនសែនកំចាយមារ ដោយប្រើប្រាស់សិទ្ធិជាយុវជនជំនាន់ក្រោយ ក្នុងការចង់ស្វែងយល់បន្ថែមពីប្រវត្តិ-សាស្ត្រខ្មែរក្រហមពីវេទិកាថ្នាក់រៀនស្តីអំពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) ដែលត្រូវបានរៀបចំឡើងនៅក្នុងការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នាចុងសប្តាហ៍ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២។ គោលបំណងនៃការមកកាន់ទីតាំងការិយាល័យរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងគឺដើម្បីរៀនសូត្របន្ថែមពីមាតិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-

១៩៧៩) និងស្តាប់ការពន្យល់ពីលោក ផេង ពង្សរ៉ាស៊ី គ្រូខ្មែរ ទាក់ទងនឹងនិយមន័យនៃឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើហិង្សានានា ដែលអាចឈានដល់ការកកើតអំពើប្រល័យពូជសាសន៍។

យុវជនទាំងអស់ ត្រូវបានណែនាំឲ្យទស្សនាពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅក្នុងការិយាល័យ អមដោយការធ្វើបទបង្ហាញរបស់គ្រូខ្មែរ ព្រោះនៅខាងក្រៅការិយាល័យមានភ្លៀងរលឹម និងពិបាកក្នុងការធ្វើដំណើរទៅទស្សនាពិព័រណ៍ដែលត្រូវបានដាក់តាំងបង្ហាញនៅតាមសួនច្បារ។ បន្ទាប់មក គ្រូខ្មែរបានណែនាំពីមាតិកាប្រវត្តិសាស្ត្រខ្មែរក្រហមដោយសង្ខេប។ នៅក្នុងកម្មវិធីទស្សនកិច្ច និងវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះ គ្រូខ្មែរបានផ្តល់ដល់ក្រុមយុវជននូវទិដ្ឋភាពរួមទាក់ទងនឹងវិធីសាស្ត្រសំខាន់ៗមួយចំនួន ក្នុងការទប់ស្កាត់អំពើហិង្សា ដែលអាចឈានដល់ការកកើតអំពើប្រល័យពូជសាសន៍។

យុវជនច្រើនលើសលប់បានសម្តែងនូវអារម្មណ៍រីករាយដែលទទួលបានចំណេះដឹងថ្មីស្តីអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហម។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានយុវជនតិចតួចប៉ុណ្ណោះ បានបង្ហាញពីភាពអស់កម្លាំង និងនឿយហត់ ដោយសារតែយុវជនទាំងនោះធ្វើដំណើរឆ្ងាយ។ នៅចុងបញ្ចប់នៃកម្មវិធីយុវជនបានចាប់ផ្តើមផ្លង់ការគិត និងយកចិត្តទុកដាក់ឡើងវិញ ព្រមទាំងបានសួរសំណួរមួយចំនួនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅវាគ្មិនទៀតផង។

លោក ជិន ភិរម្យ នាយកវិទ្យាល័យកំចាយមារ ដែលបានដឹកនាំក្រុមយុវជនមកកាន់ការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានបង្ហាញពីអារម្មណ៍រីករាយ និងបានថ្លែងអំណរគុណមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលផ្តល់ឱកាសដល់យុវជនក្មេងៗជំនាន់ក្រោយ បានចូលរួមស្វែងយល់ និងបង្កើនចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោក ភិរម្យ ក៏បានស្នើសុំឲ្យយុវជនដទៃទៀតចូលរួមវេទិកាថ្នាក់រៀននៅឱកាសក្រោយទៀតផងដែរ។









យុវជនមកពីស្រុកកំចាយមារស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅការិយាល័យរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សវិទ្យាល័យ ឈីន លាន ហាន់ជ័យ
## ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ និង ទស្សនកិច្ចសិក្សា ទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍

*ទូច វណ្ណេត*



លោក រស់ សំពៅ នាយកបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចែករំលែកចំណេះដឹងអំពីប្រភេទឯកសារខ្មែរក្រហម និងរំឭកអំពីសារសំខាន់នៃការស្រាវជ្រាវសម្រាប់សិស្សានុសិស្សនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃសៅរ៍ ទី០៩ ខែកក្កដា ឆ្នាំ២០២២ សិស្សានុសិស្សថ្នាក់ទី ១២ ចំនួន ៥០នាក់ ដឹកនាំដោយលោក ឃ្លាំង នរា នាយករង និងលោកគ្រូ-អ្នកគ្រូមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងធ្វើទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ រៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ចាម។ ការរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លើកទី៥នេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដល់អ្នកចូលរួមនិងសិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់ទី១២។ ក្នុងអំឡុងពេលទស្សនកិច្ចសិក្សានៅចេតិយរំឭកសម្រាប់សហគមន៍ សិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូ ជួបសន្ទនាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅមូលដ្ឋានដើម្បីស្វែងយល់អំពីរឿងរ៉ាវរបស់ប្រជាជនរស់នៅក្នុងរបបខ្មែរក្រហម។

ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ស្វាគមន៍ និងដឹកនាំសិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូ ទស្សនាពិព័រណ៍រូបថតចំនួន១០ ផ្ទាំងធំៗ ដែលបង្ហាញអំពី ប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន និងការធ្វើការងារនៅការដ្ឋានទំនប់ និងពិព័រណ៍រូបថតចំនួន៨ផ្ទាំងទៀតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងស្រុកកំពង់សៀម ដែលបានស្រាវជ្រាវ និងចងក្រងដោយអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម។ ជាមួយគ្នានេះដែរ លោក ស៊ាង ចិន្តា បានធ្វើបទបង្ហាញដល់សិស្សានុសិស្សអំពីឯកសារខ្មែរក្រហម, កិច្ចការងារស្រាវជ្រាវ និងវេទិកាអប់រំអំពីប្រវត្តិសាស្រ្តខ្មែរក្រហមដែលមាននៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលសិស្សានុសិស្សអាចមកធ្វើការសិក្សាស្រាវ និងមកចូលរួម។ ឆ្លៀតក្នុងឱកាសនេះ លោក រស់ សំពៅ នាយកបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចែករំលែកចំណេះដឹងអំពីប្រភេទឯកសារខ្មែរក្រហម និងរំឭកអំពីសារសំខាន់នៃការស្រាវជ្រាវសម្រាប់សិស្សានុសិស្ស។

ជាកិច្ចបន្តលោកដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញអំពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ទ្រឹស្តី និងវិធីសាស្រ្តទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដែលមានរយៈពេលជិត ២ម៉ោង។

កម្មវិធីចុងក្រោយនៃវេទិកាថ្នាក់រៀននេះ គឺជាដំណើរទស្សនកិច្ចទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ ស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ នៅពេលទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍នេះ សិស្សានុសិស្ស បានជួបសន្ទនាផ្ទាល់ជាមួយលោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិប។ លោក សុភា បាននិយាយប្រាប់អំពីរឿងរ៉ាវជីវិតការបាត់បង់ឪពុក និងការចាប់ខ្លួនអ្នកភូមិយកទៅសម្លាប់ដោយកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី។ ជាចុងក្រោយ លោក សុភា បានអរគុណដល់ក្រុមការងារដែលបានរៀបចំឡើងនូវកិច្ចសន្ទនានេះ ដែលអាចឲ្យខ្លួនបានចែករំលែកអំពីដំណើរជីវិត និងរឿងរ៉ាវកើតឡើងក្នុងភូមិនៅក្នុងរបបខ្មែរក្រហម និងផ្តាំផ្ញើសារដល់សិស្សានុសិស្សទាំងអស់ឲ្យខិតខំរៀនសូត្រ ស្វែងយល់អំពីប្រវត្តិសាស្រ្តខ្មែរក្រហម និងចូលរួមការការពារកុំឲ្យរបបខ្មៅងងឹតនេះវិលត្រឡប់មកវិញ។



សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ មកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ដើរទស្សនាពិព័រណ៍រូបថតចំនួន៨ផ្ទាំងអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងស្រុកកំពង់សៀម ដែលបានស្រាវជ្រាវនិងចងក្រងដោយអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម។
( ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )



សិស្សានុសិស្សនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ( ១៩៧៥-១៩៧៩ ) នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

បន្ទាប់ទស្សនកិច្ចសិក្សានៅ ទីតាំងចេតិយរំឭក សម្រាប់សហគមន៍បានបញ្ចប់ សិស្សានុសិស្សបង្ហាញទស្សនយល់ឃើញរបស់ខ្លួនដូចខាងក្រោម ៖



ឡុន ម៉េងហ៊ាង រៀនថ្នាក់ទី១២-B មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីនលាន ហាន់ជ័យ ឈរនៅចេតិយរំឭកសម្រាប់សហគមន៍នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ (ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សឈ្មោះ ឡុន ម៉េងហ៊ាង រៀនថ្នាក់ទី១២-B មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីនលាន ហាន់ជ័យ បាននិយាយថា «ខ្ញុំទទួលបានចំណេះដឹងប្រវត្តិសាស្ត្រជាច្រើនចេញពីការទស្សនាផ្ទាំងរូបភាពប្រវត្តិសាស្ត្រ ការធ្វើបទបង្ហាញ និងការស្ដាប់រឿងរ៉ាវជីវិតរបស់អ៊ំប្រុស សុភា ដែលរួចផុតជីវិតពីរបបខ្មែរក្រហម។ ខ្ញុំពិតជាអាណិតអាសូរដល់ប្រជាជនខ្មែរជំនាន់មុនដែលបានឆ្លងកាត់សង្គ្រាម និងរបបខ្មែរក្រហម។ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំខិតខំរៀនសូត្រ និងចូលរួមទប់ស្កាត់កុំឲ្យរបបនេះមកវិញម្ដងទៀត»។



អុន ម៉េងហួ រៀនថ្នាក់ទី១២-B មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីនលាន ហាន់ជ័យ ឈរនៅចេតិយរំឭកសម្រាប់សហគមន៍នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សឈ្មោះ អុន ម៉េងហួ រៀនថ្នាក់ទី១២-B មុខវិជ្ជាវិទ្យាសាស្ត្រសង្គម នៃវិទ្យាល័យ ឈីនលាន ហាន់ជ័យ បានចែករំលែកអ្វីដែលខ្លួនទទួលបានថា «ខ្ញុំពេញចិត្តចំពោះកម្មវិធីនេះ ពីព្រោះខ្ញុំទទួលបានចំណេះដឹងពីរបបខ្មែរក្រហមដែលបានបង្កការស្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លិចបំផ្លាញប្រទេសជាតិ។ ចំណេះដឹងថ្មីដែលខ្ញុំទទួលបានគឺផលវិជ្ជមានបន្សល់ទុកដោយខ្មែរក្រហមរួមមានការដ្ឋានទំនប់ចំនួន៥ បានប្រែក្លាយទៅជាទីកន្លែងស្ដុកទុកទឹកសម្រាប់ផ្គត់ផ្គង់ដំណាំកសិកម្ម»។



ម៉ុន សុម៉ា ឡា រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ឈីនលាន ហាន់ជ័យ ឈរនៅចេតិយរំឭកសម្រាប់សហគមន៍នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សឈ្មោះ ម៉ុន សុម៉ា ឡា រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិតនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ បង្ហាញអារម្មណ៍របស់ខ្លួន បន្ទាប់ពីបានស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតនៅចេតិយរំឭក សម្រាប់សហគមន៍ថា «ខ្ញុំមានអារម្មណ៍អាណិត

អាសូរចំពោះអ៊ំប្រុសដែលបានរស់នៅយ៉ាងលំបាក និងបាត់បង់ឪពុកជាទីស្រឡាញ់ ដោយខ្មែរក្រហមបានយកឪពុកគាត់ទៅសម្លាប់។ ទុក្ខលំបាក និងការបាត់បង់ឪពុករបស់អ៊ំ គឺនៅតែនៅក្នុងការចងចាំរបស់ខ្ញុំ។ ខ្ញុំនឹងយកអ្វីដែលខ្ញុំទទួលបានថ្ងៃនេះ ទៅសួរឪពុកម្ដាយ និងជីដូនរបស់ខ្ញុំអំពីហេតុការដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម»។



សា៊រ៉ន ហ្គេកគីម រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ឈីនលាន ហាន់ជ័យ ឈរនៅចេតិយរំឭកសម្រាប់សហគមន៍នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។
( ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

សិស្សឈ្មោះ **សារ៉ន ហ្គេកគីម** រៀនថ្នាក់ទី១២-A មុខវិជ្ជាវិទ្យាសាស្ត្រពិត នៃវិទ្យាល័យ ឈីន លាន ហាន់ជ័យថ្នាក់បានលើកឡើងអំពីចំណេះដឹងដែលខ្លួនទទួលបានពីវេទិកាអប់រំចុងសប្ដាហ៍នេះថា «ខ្ញុំទទួលបានចំណេះដឹងជាច្រើន និងឃើញរូបភាពជាច្រើនដែលបានបន្សល់ទុកពីសម័យ ប៉ុល ពត។ ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ រឿងរ៉ាវទាំងអស់នេះ គឺឆ្លុះបញ្ចាំងរាល់ទិដ្ឋភាពនៅក្នុងមេរៀនដែលខ្ញុំរៀននៅក្នុងថ្នាក់»។



សិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ សួរសំណួរទៅកាន់វាគ្មិន។
(ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )



សិស្សានុសិស្សនៃវិទ្យាល័យ ឈីន លាន ហាន់ជ័យ កំពុងស្ដាប់ការនិយាយប្រាប់អំពីរឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមរបស់ តុង សុភា នៅទីតាំងចេតិយរំឭកសម្រាប់សហគមន៍។
( ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )



លោក តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិប។
(ទូច វណ្ណេត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ ស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្ស មកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ

*សួគ វិចិត្រ*




*សិស្សានុសិស្ស និងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ថតរូបជុំគ្នានៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ស្ថិតនៅលើភ្នំដងរែក ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ សិស្សានុសិស្សចំនួន ១៥នាក់ ក្នុងនោះមានសិស្សស្រី ៦នាក់ មកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងតាវ បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ វេទិកានេះ មានគោលបំណង «លើកកម្ពស់ការចងចាំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ (១៩៧៥-១៩៧៩) និងទ្រឹស្តីមួយចំនួនទាក់ទងនឹងការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ដល់យុវជនស្រុកអន្លង់វែង។*

*បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានផ្ញើបទបង្ហាញទៅកាន់សិស្សានុសិស្ស ស្តីអំពីអំពើប្រល័យពូជសាសន៍ ដោយផ្អែក*

ទៅលើការបញ្ចាំងកុនឯកសារ «មន្ទីរស-២១ ប្តុគុកទួលស្លែង»។ ការចាក់បញ្ចាំងកុនឯកសារ «មន្ទីរស-២១ ប្តុគុកទួលស្លែង» បានបង្កើតឲ្យមានការពិភាក្សានៅក្នុងវេទិកាថ្នាក់រៀន និងបានរកឃើញថារបបខ្មែរក្រហមបានគាបសង្កត់សិទ្ធិសេរីភាព, ការមិនបានផ្តល់អាហារឲ្យប្រជាជនបរិភោគគ្រប់គ្រាន់ ការធ្វើទារុណកម្ម និងការសម្លាប់។ មន្ទីរស-២១ គឺជាគុកសម្ងាត់របស់ខ្មែរក្រហម សម្រាប់ឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្មអ្នកទោស មុននឹងយកទៅសម្លាប់នៅឯវាលពិឃាតបឹងជើងឯក។ មានអ្នកទោស ១២ នាក់ ក្នុងចំណោមអ្នកទោសប្រមាណជាង ១៤,០០០ នាក់បាននៅរស់រានមានជីវិតបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ។ ខ្សែភាពយន្តឯកសារដ៏កម្រនេះត្រូវបានរក្សាទុកនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងជាប្រភពឯកសារដែលបានផ្តល់នូវការពិចារណាយ៉ាងទូលំទូលាយដល់យុវជនពីអំពើឃោរឃៅ និងទង្វើអមនុស្សធម៌របស់ខ្មែរក្រហមទៅលើប្រជាជនស្លូតត្រង់។

នៅក្នុងការពិភាក្សានេះ សិស្សានុសិស្សមួយចំនួនធ្លាប់បានឮអំពើឃោរឃៅរបស់ខ្មែរក្រហមតាមរយៈឪពុកម្តាយ ឬជីដូនជីតារបស់ខ្លួនធ្លាប់ដំណាលប្រាប់ថា ខ្មែរក្រហមបានសម្លាប់មនុស្សដោយអារកនឹងធាងត្នោត។ ដូច្នេះ បានជំរុញឲ្យសិស្សានុសិស្សទាំងនោះចង់ស្វែងយល់បន្ថែមនូវការសម្លាប់ដ៏ឃោរឃៅនោះ។

សិស្សានុសិស្សមួយចំនួនទៀតយល់ឃើញថា ការស្លាប់របស់ប្រជាជនកម្ពុជាដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ប្រាកដជាមានការចូលរួមពីជាតិសាសន៍ដទៃផ្សេងទៀតដើម្បីបំផ្លាញជាតិសាសន៍ខ្មែរ។

បន្ទាប់មក បណ្ឌិត លី សុខឃាង បានបែងចែកសិស្សានុសិស្សជាក្រុមផ្សេងគ្នា ដោយប្រើវិធីសាស្ត្របង្រៀនបែបសហការ។ ក្រុមនីមួយៗត្រូវសង្ខេបខ្លឹមសារចេញពីជំពូកសំខាន់ៗក្នុងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ តមក សិស្សានុសិស្សត្រូវធ្វើបទបង្ហាញទៅកាន់អ្នកចូលរួមទាំងអស់ ព្រមទាំងត្រូវឆ្លើយរាល់សំណួររបស់អ្នកចូលរួមផងដែរ។

នៅក្នុងឱកាសនោះ បណ្ឌិត លី សុខឃាង បានពិពណ៌នាអំពីរូបភាពនៃរណ្តៅសាកសពរួម និងបានចាក់បញ្ចាំងកុនឯកសារដែលមានចំណងជើងថា «កុមារកម្ពុជា» ដើម្បីធ្វើជាប្រធានបទសម្រាប់សិស្សានុសិស្សពិភាក្សាបន្ត។ បណ្ឌិត លី សុខឃាង បានរៀបរាប់ថា អំពើឃោរឃៅរបស់ខ្មែរក្រហម និងវិនាសកម្មគឺមានទំហំធំធេងណាស់ ដូច្នេះ ទាមទារឲ្យរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា តាមរយៈការ



សិស្សានុសិស្សមកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងគាវ ចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងបង្ហាញផែនទីប្រទេសកម្ពុជាដល់សិស្សានុសិស្សមកពីវិទ្យាល័យតេជោ ហ៊ុន សែន ត្រពាំងគាវ នៅក្នុងវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សកំពុងស្តាប់លោក សួត វិចិត្រ ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបរាប់អំពីព័ត៌មានរូបថតដែលដាក់តាំងបង្ហាញនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងលើខ្នងភ្នំដងរែក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលចាប់ផ្តើមដំណើរការកាត់ក្តីដំបូងនៅក្នុងឆ្នាំ២០០៧។ តុលាការកូនកាត់នេះ រួមបញ្ចូល ទាំងច្បាប់ជាតិ និងអន្តរជាតិ ដើម្បីស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ និងផ្សព្វផ្សាយទៅកាន់ពិភពលោកថា អំពើប្រល័យពូជសាសន៍នៅកម្ពុជាមិនមែនជារឿងនិទាននោះទេ។

ខែ្សភាពយន្តឯកសារ «កុមារកម្ពុជា» បានបង្ហាញពីស្ថានភាពជីវិតរបស់កុមារបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។ ស្ថានភាពជីវិតកុមារកម្ពុជាមានភាពខុសប្លែកទៅនឹងកុមារដទៃ ទៀតជុំវិញពិភព-លោក។ ស្ថានភាពនៃការលូតលាស់របស់កុមារកម្ពុជាបានបង្អាក់ដោយការអត់ឃ្លាន, ខ្វះអនាម័យ និងខ្វះភាពកក់ក្តៅ។ កុមារបង្ខំចិត្តធ្វើអ្វីៗដើម្បីរស់ ដូចជាហូបស្លឹកឈើ និងហូបអាហារដែលខ្វះអនាម័យ។

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀន បណ្ឌិត លី សុខឃាង បានចាក់បញ្ចាំងកុនឯកសារដែលមានចំណងជើងថា «ខ្មែរបាត់បង់តន្ត្រីរ៉ក់»។ ខ្សែភាពយន្តឯកសារនេះបានរំឭកដល់ការវិវត្តន៍នៃតន្ត្រីខ្មែរ



សិស្សានុសិស្សកំពុងពិភាក្សានៅក្នុងក្រុម នៅអំឡុងពេលចូលរួមវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅតាមសម័យកាលនីមួយៗមិនឡើយណាយ។ តន្ត្រីបានបញ្ឆេះពីស្ថានភាពជីវិតរស់នៅរបស់ប្រជាជនវប្បធម៌ និងអត្តសញ្ញាណជាតិ បើទោះបីជាសង្គមធ្លាក់ទៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ។



សិស្សានុសិស្សកំពុងមើលរូបថតដាក់តាំងនៅក្នុងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សូត វិចិត្រ អ្នកស្រាវជ្រាវមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កំពុងរៀបរាប់ពីទីតាំងបូជាសព ប៉ុល ពត ទៅកាន់សិស្សានុសិស្ស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



បឹងអន្លង់វែង ឬ បឹងតាម៉ុក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះ សិស្សចំនួន២នាក់ មានចំណាប់អារម្មណ៍ និងការយល់ឃើញដូចខាងក្រោម៖

**ស៊ិន ចំប៉ា** ភេទស្រី អាយុ១៩ឆ្នាំ យល់ឃើញថា ពេលខ្ញុំរៀនសូត្រពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅក្នុងរបបខ្មែរក្រហម បានធ្វើឲ្យខ្ញុំដឹងអំពីការលំបាក គ្មានសិទ្ធិសេរីភាព ការខ្វះខាតអាហារហូបចុក និងការជិះជាន់របស់ខ្មែរក្រហមទៅលើប្រជាជន។ ប្រសិនបើឧក្រិដ្ឋកម្មឃោរឃៅកើតឡើងម្តងទៀត ខ្ញុំគិតថា វានឹងបំផ្លាញសិទ្ធិសេរីភាព គ្មានភាពកក់ក្តៅ កង្វះខាតក្នុងការហូបចុក និងគ្មានទីជម្រក។ ក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងចូលរួមទប់ស្កាត់ការកកើតឡើងនូវឧក្រិដ្ឋកម្មឃោរឃៅ និងចូលរួមផ្សព្វផ្សាយឲ្យក្មេងជំនាន់ក្រោយបានដឹងអំពីផលលំបាក ព្រមទាំងជំរុញឲ្យយុវជនយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្បាស់លាស់។

**គង់ សម្បត្តិ** ភេទប្រុស អាយុ១៨ឆ្នាំ រៀបរាប់ថា នៅក្នុងសម័យខ្មែរក្រហម មានការសម្លាប់មនុស្សយ៉ាងឃោរឃៅ គ្មានសិទ្ធិសេរីភាពក្នុងការបញ្ចេញនូវគំនិត ថែមទាំងមានការលុបបំបាត់នូវជនជាតិ ជាតិពន្ធុជាតិសាសន៍ ឬសាសនា។ នៅពេលរៀបការ បុគ្គលម្នាក់ៗគ្មានសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ និងការសម្រេចចិត្តដោយខ្លួនឯង គឺស្ថិតនៅក្រោមការបង្ខិតបង្ខំ។ ប្រសិនបើឧក្រិដ្ឋកម្មឃោរឃៅនេះកើតឡើងម្តងទៀត ប្រទេសជាតិនឹងជួបប្រទះភាពចលាចល ការបាត់បង់សមាជិកគ្រួសារ ការសម្លាប់គ្នាទៅវិញទៅមក បាត់បង់អ្នកចេះដឹង និងសាសនា។ ខ្ញុំចង់ឲ្យជាយុវជនជំនាន់ក្រោយ ចេះគោរពគ្នាទៅវិញទៅមក ផ្តល់តម្លៃឲ្យគ្នា ចេះយោគយល់គ្នា និងយល់ដឹងអំពីប្រវត្តិសាស្ត្រឲ្យបានច្រើន។













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!















# វេទិកាថ្នាក់រៀនចុងសប្តាហ៍

## ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម

*គាត ស្រីឡែន និង ឈុំ រ៉ា*



លោកផេង ពង្ស៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់សិស្សានុសិស្ស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២ សិស្សានុសិស្សចំនួន ៥១នាក់ ក្នុងនោះមានសិស្សស្រី ៣៣នាក់ និងអ្នកគ្រូចំនួន ២នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ខ្នារ និង វិទ្យាល័យក្រែក ខេត្តត្បូងឃ្មុំ បានចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។

ការរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍នេះក្នុងគោលបំណងដូចខាងក្រោម៖

- ផ្តល់ឱកាសដល់សិស្សានុសិស្សក្នុងការចែករំលែក និងបង្ហាញពីចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេនៅលើអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។



លោកផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ណែនាំសិស្សានុសិស្សក្នុងពេលបំពេញសំណួរស្តាប់ស្ទង់មតិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់សិស្សានុសិស្ស។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- លើកទឹកចិត្តសិស្សឲ្យគិតពិចារណាលើផលវិបាកអន្តរកាលនៃកេរដំណែលនេះ ក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។
- ជំរុញការពិភាក្សាអំពីកេរដំណែលនេះនៅក្នុងគ្រួសារ និងសហគមន៍។
- ជំរុញការពិភាក្សាអំពីយុទ្ធសាស្ត្រមួយចំនួនក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។
- ចែកសៀវភៅសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ (១៩៧៥-១៩៧៩)។

ជាកិច្ចចាប់ផ្តើមវេទិកាថ្នាក់រៀនចុងសប្តាហ៍លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានណែនាំខ្លួន និងបង្ហាញអំពីគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្ម នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំយុវជន និងកីឡា ក្រសួងការពារជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់មកលោក ឡុង ដានី បាននាំសិស្សានុសិស្ស និងអ្នកគ្រូដើរទស្សនាពិព័រណ៍នៃបណ្តុំរូបថត រូបគំនូរ និងផែនទីនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដោយចាប់ផ្តើមពីបណ្តុំរូបថតនៃសង្គ្រាមនៅទសវត្សរ៍ឆ្នាំ១៩៦០ នៅតំបន់កោះថ្ម, បណ្តុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បណ្តុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម នាំសិស្សានុសិស្ស និងអ្នកគ្រូដើរទស្សនាពិព័រណ៍នៃបណ្តុំរូបថត រូបគំនូរ និងផែនទីដែលដាក់តាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្សកត់ត្រា នៅពេលលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ធ្វើបទបង្ហាញទាក់ទងនឹងបណ្តុំរូបថត រូបគំនូរ និងផែនទីដែលដាក់តាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, បណ្តុំរូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បណ្តុំរូបគំនូរដែលសមមិត្ត ហ៊ុន សែន (សម្តេចតេជោ ហ៊ុន សែន) និងយុទ្ធមិត្ត ៤រូប ចាកចេញទៅប្រទេសវៀតណាម ដើម្បីរៀបចំកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងផែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត ៤រូប បានចាកចេញពីបន្ទាយយោធានៅភូមិកោះថ្មទៅតំបន់ព្រំដែនអាងដាច់ដើមត្រយឹង (X-16) និងទីតាំងមួយចំនួននៅក្នុងស្រុកឡុកនិញ ខេត្តសុងបេ៊ ប្រទេសវៀតណាម និងការបង្កើតអង្គភាព១២៥ ដែលជាកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាដំបូងបង្អស់ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។

ជាកិច្ចបន្តលោក ផេង ពង្ស៊ីរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់សិស្សានុសិស្សមានដូចខាងក្រោម ៖

- វាស់ស្ទង់ចំណេះដឹងសិស្សមុនវេទិកាចាប់ផ្តើមដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។
- ចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សទាំងអស់។
- ពន្យល់ពីនិយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។
- បង្រៀនមេរៀនប្រវត្តិសាស្ត្រជំពូកទី៣ នៃសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ៖ ការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី១ និងដំណាក់កាលទី២។

លោកផេង ពង្ស៊ីរ៉ាស៊ីបានពន្យល់សិស្សានុសិស្សថា នៅដំណាក់កាលដំបូងយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ និងចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងប្រមាណ២លាននាក់ក្រោមមូលហេតុផ្សេងៗដូចជា ៖



សិស្សានុសិស្សសួរសំណួរ អំឡុងពេលចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សិស្សានុសិស្ស អ្នកគ្រូ មកពីវិទ្យាល័យ ហ៊ុន សែនខ្នារ និង វិទ្យាល័យក្រែក ខេត្តត្បូងឃ្មុំ ចូចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

១) សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុង
២) ដើម្បីបោសសម្អាតទីក្រុង
៣) ពិនិត្យមើលខ្មាំងចុងក្រោយ
៤) មិនចង់ឲ្យប្រជាជនរស់នៅលាយឡំជាមួយខ្មាំង
៥) ឲ្យប្រជាជនចេញទៅយកស្បៀងអាហារនៅទីជនបទ។

ការជម្លៀសដោយបង្ខំនេះ បានបណ្តាលឲ្យប្រជាជនរាប់ពាន់នាក់ជាពិសេសកុមារ មនុស្សចាស់ជរា និងអ្នកជំងឺបានស្លាប់។ ស្ត្រីមានផ្ទៃពោះជាច្រើនបានស្លាប់នៅពេលសម្រាលកូនដោយសារគ្មានថ្នាំសង្កូវ ឬសេវាសុខាភិបាល។ ក្មេងៗបានវង្វេងបាត់ពីឪពុកម្តាយ។ ប្រជាជនភាគច្រើនមិនដឹងថា តើមានអ្វីកំពុងតែកើតឡើងនោះទេ។

លោកដេង ពង្សរ៉ាស៊ី បានបន្តថាការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី ២ គឺខ្មែរក្រហមបានជម្លៀសប្រជាជននៅភូមិភាគបូព៌ា រួមមានខេត្តស្វាយរៀង ខេត្តព្រៃវែង និងផ្នែកខ្លះនៃខេត្តកំពង់ចាម ដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាលបន្ទាប់ពីខ្មែរក្រហមបានចោទប្រកាន់មេដឹកនាំ និងកម្មាភិបាលនៅភូមិភាគបូព៌ាក្បត់ដោយបានចូលជាមួយប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ ការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្តាលនេះបានបណ្តាលឲ្យប្រជាជនបូព៌ាជាច្រើនបានស្លាប់ដោយសារការយកទៅសម្លាប់ ដោយសារជំងឺ និងអត់អាហារ។

នៅចុងបញ្ចប់វេទិកាថ្នាក់រៀន លោក ដេង ពង្សរ៉ាស៊ី ឲ្យសិស្សធ្វើកិច្ចការដូចខាងក្រោម៖

- សួរសំណួរនិងឆ្លើយសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
- ឲ្យសិស្សបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងក្រោយវេទិកាបញ្ចប់។
- ថតរូបអនុស្សាវរីយ៍។

បន្ទាប់មក គ្រូ និងសិស្សបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម ៖

អ្នកគ្រូ ហុង ស្រីរ័ត្ន បង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៃវិទ្យាល័យ ហ៊ុន សែន ខ្នារ មានប្រសាន៍ថា នៅពេលខ្ញុំមកមជ្ឈមណ្ឌលឯកសារកោះថ្មភ្លាម ខ្ញុំបានចាប់អារម្មណ៍ទៅលើផ្ទាំងគំនូរនៅលើជញ្ជាំងជាច្រើនទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមចាប់ពីការកកើតឡើង

រហូតដល់មានការរំដោះប្រទេសចេញពីរបបខ្មែរក្រហម។ ចំណែករូបភាពមួយចំនួនបានបង្ហាញពីសោកនាដកម្ម ដូចជា សាកសព គ្រោងឆ្អឹង ព្រមទាំងមានរូបភាពផ្សេងៗទៀត។ ខ្ញុំសង្កេតឃើញសិស្សានុសិស្សមានសកម្មភាព មានការយកចិត្តទុកដាក់សិក្សា ចាប់អារម្មណ៍ទៅលើការធ្វើបទបង្ហាញរបស់គ្រូខទ្ទេសដែលធ្វើឲ្យសិស្សទទួលបាននូវចំណេះដឹងបន្ថែមពីលើសៀវភៅសិក្សាគោលដែលបង្រៀននៅតាមសាលា។ ម្យ៉ាងទៀតសិស្សដែលបានចូលរួមក្នុងវេទិកាថ្នាក់រៀននេះ គឺបានឃើញទីតាំងផ្ទាល់ និងរូបភាពជាច្រើនទាក់ទងនឹងសម្តេច ហ៊ុន សែន និងយុទ្ធមិត្តទាំង៤រូប កាលពីអតីតកាល។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឱកាសឲ្យនាងខ្ញុំ និងសិស្សានុសិស្សបានចូលរួមសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចង់ឲ្យមជ្ឈមណ្ឌលឯកសារកោះថ្មនៅតែផ្តល់ឱកាសឲ្យសិស្សានុសិស្សក្រោយៗបានមកសិក្សាបន្ថែមទៀត។

យុវសិស្ស **ថន រថន** ភេទប្រុស អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២Aនៅវិទ្យាល័យ ហ៊ុន សែន ខ្សារ និយាយថា ខ្ញុំសប្បាយរីករាយនៅពេលដែលបានមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ វេទិកានេះធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងប្រវត្តិសាស្ត្រខ្មែរក្រហមថ្មីៗបន្ថែមទៀត និងបានដឹងពីផលពិបាកនៃសង្គ្រាម។ ម្យ៉ាងទៀតខ្ញុំក៏ទទួលបានព័ត៌មានកាន់តែច្រើនអំពីជីវភាពរស់នៅលំបាកវេទនារបស់ប្រជាជននៅក្នុងរបបខ្មែរក្រហម។ ចំពោះខ្លួនខ្ញុំផ្ទាល់ គឺមិនចង់ឲ្យមានសង្គ្រាម និងរបបប្រល័យពូជសាសន៍កើតឡើងវិញម្តងទៀតឡើយ។

យុវសិស្ស **លាង រតនា** ភេទស្រី អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២B នៅវិទ្យាល័យ ហ៊ុន សែនខ្សារ បានឲ្យដឹងថា ខ្ញុំមានអារម្មណ៍រីករាយ ពីព្រោះកាលពីមុនខ្ញុំបានសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ប៉ុន្តែមិនបានស៊ីជម្រៅ។ ក្រោយពីខ្ញុំបានចូលរួមនៅការសិក្សាប្រវត្តិសាស្ត្រនៅថ្ងៃនេះ ខ្ញុំបានយល់ដឹងកាន់តែច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយក៏បានទទួលបានចំណេះដឹងកាន់តែច្រើនអំពីដំណើររបស់សម្តេច ហ៊ុន សែន និងយុទ្ធមិត្តដើម្បីសុំការអន្តរាគមន៍ពីប្រទេសវៀតណាមដើម្បីកសាងកងកម្លាំងប្រដាប់អាវុធមករំដោះប្រទេសជាតិ។ លើសពីនេះទៀត ខ្ញុំក៏យល់ដឹងអំពីវិធីទប់ស្កាត់របបខ្មែរក្រហមកុំឲ្យកើតឡើងម្តងទៀតដែរ។

សិស្សានុសិស្ស អ្នកគ្រូ មកពីវិទ្យាល័យ ហ៊ុន សែន ខ្សារ និង វិទ្យាល័យក្រែក ខេត្តត្បូងឃ្មុំ និងក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាថ្នាក់រៀនចុងសប្តាហ៍ នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ

*សៀង កញ្ញា*



លោក ផេង ពង្សរ៉ាស៊ី កំពុងធ្វើបទបង្ហាញទៅកាន់សិស្សដែលបានចូលរួមវេទិកាប្រវត្តិសាស្ត្រប្រចាំសប្តាហ៍ នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២។
(កាន់ សុខភាព/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ ការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ជាមួយសិស្សចំនួន ៣០ នាក់មកពីស្រុកគិរីវង់។ សិស្សដែលបានមកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ ដឹកនាំដោយអ្នកស្រីនាយិកា កែវ គឹមស្រ៊ុន និងគ្រូបង្រៀនចំនួនពីរនាក់។ អាណាព្យាបាលយុវជនម្នាក់ ក៏បានមកចូលរួមជាមួយកូនរបស់គាត់ និងក្រុមយុវជនទាំងអស់ដែរ។ វេទិកាចុងសប្តាហ៍នេះត្រូវបង្កើតឡើងដើម្បីផ្តល់ដល់យុវជន និងអាណាព្យាបាលយុវជនកើតក្រោយឆ្នាំ១៩៧៩ នូវចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបណ្តុះគំនិតយុវជនឲ្យចេះស្រឡាញ់សន្តិភាព ស្អប់ខ្ពើម និងប្រឆាំងចំពោះការកកើតអំពើប្រល័យពូជសាសន៍រួម ទាំងឲ្យចេះរួបរួមគ្នាដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

នៅពេលលោកគ្រូ អ្នកគ្រូ យុវជន និងអាណាព្យាបាល អញ្ជើញមកដល់ការិយាល័យមជ្ឈមណ្ឌល

ឯកសារ ខេត្តតាកែវ ដំបូងក្រុមការងារបានបាញ់ទឹកអាកុល និងគោរពតាមការណែនាំរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ជំងឺកូវីដ១៩។ គ្រូខបទេ្ទសបានសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ ដែលជាអ្នកដឹកនាំសិស្ស ហើយយុវជនមើលផ្ទាំងរូបភាពតាំងពិព័រណ៍ដែលតាំងបញ្ឈរនៅ ខាងមុខការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ បន្ទាប់មក លោកគ្រូខបទេ្ទសណែនាំក្រុមយុវសិស្សអំពីផ្ទាំងពិព័រណ៍ និងឲ្យយុវជនអានចំណងជើងដែលស្ថិតនៅផ្នែកខាងក្រោមផ្ទាំងរូបថត ហើយធ្វើការពន្យល់បន្ថែមអំពីរូបភាពនីមួយៗយ៉ាងក្បោះក្បាយ។ ទន្ទឹមនឹងការស្តាប់គ្រូខទេ្ទសពន្យល់ ក្រុមសិស្សខ្លះកត់ត្រានូវរាល់ចំណុចសំខាន់ៗ ដែលខ្លួនមិនធ្លាប់ដឹងពីមុនមក។ ឆ្លៀតពេលនោះយុវជនខ្លះបានសួរសំណួរមួយចំនួនដែលខ្លួនមិនទាន់យល់ច្បាស់ទៅកាន់លោក ផេង ពង្សរ៉ាស៊ី ហើយលោកគ្រូខទេ្ទស ក៏បានឆ្លើយតបទៅនឹងសំណួរនោះភ្លាមៗវិញផងដែរ។

លោក ផេង ពង្សរ៉ាស៊ី ចាប់ផ្តើមធ្វើបទបង្ហាញទាក់ទងនឹងនិយមន័យឧក្រិដ្ឋកម្មឃោរឃៅ និងធាតុផ្សំមួយចំនួនអាចបង្កើតទៅជាឧក្រិដ្ឋកម្ម។ នៅពេលលោកគ្រូខទេ្ទស កំពុងធ្វើបទបង្ហាញ យុវជនទាំងអស់ស្តាប់ដោយយកចិត្តទុកដាក់ ហើយមានការកត់ត្រា។ បទបង្ហាញរបស់លោកគ្រូខទេ្ទស សម្រេចធ្វើបទបង្ហាញលើចំណុចចំនួនពីរគឺ៖ ១) ផែនការ និងការចូលមកដល់ទីក្រុងភ្នំពេញរបស់ខ្មែរក្រហម ២) ការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី១ និងទី២។ លោក ផេង ពង្សរ៉ាស៊ី បានបង្ហាញរូបភាពជាច្រើនសន្ធឹកស្តីអំពីទិដ្ឋភាពការចូលមកដល់ទីក្រុងភ្នំពេញ និងទិដ្ឋភាពនៃការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជាក្នុងទីក្រុងភ្នំពេញ។ រូបថតទាំងនោះគឺជាប្រភេទរូបភាពស-ខ្មៅ និងអមដោយការពន្យល់ខ្លឹមសារលម្អិត។ សំណួរ និងចម្លើយអំពីប្រវត្តិសាស្រ្ត បន្ទាប់ពីការធ្វើបទបង្ហាញរួចអ្នកស្រីនាយិកាបានជំរុញបន្ថែមដល់ក្រុមយុវជនទាំងអស់ ឲ្យសួរសំណួរទៅកាន់លោកគ្រូខទេ្ទស។ យុវជនមួយចំនួន ភាគច្រើនជាស្រ្តីបានសួរសំណួរអំពីប្រវត្តិសាស្រ្ត ហើយសំណួរទាំងនោះជាសំណួរដែល ទាក់ទងនឹងការជម្លៀស ផែនការ៤ឆ្នាំរបស់ខ្មែរក្រហម កិច្ចការបរទេសរបស់ខ្មែរក្រហម និងការដួលរលំរបស់ខ្មែរក្រហម។ បន្ទាប់ពីសួរ និងឆ្លើយសំណួររួច គ្រូខទេ្ទសបានឲ្យក្រុមការងារចែកកម្រងសំណួរឲ្យយុវជនម្តងទៀត ដើម្បីវាស់ស្ទង់ពីចំណេះដឹងរបស់យុវជន តើមានការកើនឡើងកម្រិតណា? ឆ្លៀតពេលដែលយុវជនបំពេញកម្រងសំណួរវាស់ស្ទង់រួច ក្រុមការងារបានសួរចំណាប់អារម្មណ៍



លោក ផេង ពង្សរ៉ាស៊ី កំពុងធ្វើបទបង្ហាញទៅកាន់សិស្សដែលបានចូលរួមវេទិកាប្រវត្តិសាស្រ្តប្រចាំសប្តាហ៍ នៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២
(កាន់ សុខភាព/ មជ្ឈមណ្ឌលឯកសារកម្ពុជា)




សិស្សកំពុងមើលផ្ទាំងពិព័រណ៍ ដាក់តាំងបង្ហាញនៅការិយាល័យមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២។
(កាន់ សុខភាព/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅកាន់គ្រូដឹកនាំ និងសិស្សហើយពួកគាត់លើកឡើងស្រដៀងគ្នាបីចំណុច ១) ចំណាប់អារម្មណ៍របស់ពួកគាត់មានការចូលចិត្តនូវមុខវិជ្ជាប្រវត្តិសាស្ត្រ ដោយសារពួកគាត់អាចទទួលបានចំណេះដឹងជាច្រើន និងមានការសប្បាយរីករាយដែលបានមកចូលរួមកម្មវិធីវេទិកាថ្នាក់រៀនប្រចាំសប្តាហ៍ ២) ពួកគាត់សូមលោកគ្រូខ្មេសឲ្យមានការបើកវេទិកាថ្នាក់រៀនបែបនេះបន្តទៀតដើម្បីឲ្យយុវជនផេ្សងទៀតអាចមានឱកាសចូលរួមដូចពួកគាត់ ៣) ពួកគាត់បានស្នើសុំឲ្យមានទីកន្លែងទូលាយជាងនេះ ដើម្បីអាចឲ្យសិស្សចូលរួមបានច្រើន។

បន្ទាប់មកក៏មានការចែកជូនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សចូលរួមចំនួន ៣០នាក់។ វេទិកានេះក៏មានដំណើរទស្សនកិច្ចទៅកាន់មជ្ឈមណ្ឌលឧក្រិដ្ឋកម្មក្រាំងតាចាន់ដែលជាអតីត មន្ទីរសន្តិសុខក្នុងរបបខ្មែរក្រហម គឺមន្ទីរសន្តិសុខក្រាំងតាចាន់។ នៅទីនោះ លោកគ្រូ ផេង ពង្ស៉រ៉ាស៊ី បានពន្យល់ដល់ក្រុមយុវជន បន្ថែមទៀតពីការកកើត ការប្រតិបត្តិ ការធ្វើទារុណកម្មអ្នកទោស និងការសម្លាប់អ្នកទោសនៅក្នុងមន្ទីរសន្តិសុខ។



សិស្សកំពុងយកចិត្តទុកដាក់ស្តាប់បទបង្ហាញរបស់គ្រូខ្មេស អំឡុងវេទិកាថ្នាក់រៀនប្រចាំសប្តាហ៍កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២
( កាន់ សុខភាព/ មជ្ឈមណ្ឌលឯកសារកម្ពុជា )



សិស្សទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មក្រាំងតាចាន់ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២។
( កាន់ សុខភាព/ មជ្ឈមណ្ឌលឯកសារកម្ពុជា )



សិស្ស និងគ្រូខ្មេសថតរូបជុំគ្នានៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២។
( កាន់ សុខភាព/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

# និស្សិតមកពីវិទ្យាស្ថានពហុបច្ចេកទេស ខេត្តកំពង់ចាម ចូលរួមវេទិកាអន្តរជំនាន់អំពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

*អេង វណ្ណារីកា*



*វេទិកាអន្តរជំនាន់នៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ ( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

នៅវេលាម៉ោង៩ ព្រឹកថ្ងៃអាទិត្យ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម រៀបចំវេទិកាអន្តរជំនាន់ដោយមានការចូលរួមដោយ ម៉ៅ វណ្ណា និង ឡុង គឹមស្រ៊ាង គឺជាមិត្តភក្តិពីកុមារភាពនិងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមនឹងនិស្សិតចំនួន ១៨ នាក់ មកពីវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម។ វេទិកាអន្តរជំនាន់នេះរៀបចំឡើងក្នុងគោលបំណងផ្តល់ឱកាសដល់និស្សិតអាចស្តាប់រឿងរ៉ាវជីវិតរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជំរុញឲ្យការយល់ដឹងបន្ថែមលើប្រវត្តិសាស្ត្រខ្មែរក្រហម។ មុនពេលចាប់ផ្តើមវេទិកាអន្តរជំនាន់នេះ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម បានទទួលស្វាគមន៍ទៅកាន់និស្សិតទាំងអស់ និងធ្វើបទបង្ហាញអំពីផ្ទាំង ពិព័រណ៍ធំៗពីប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន និងការធ្វើការងារនៅការដ្ឋានៗ ឆ្លៀតក្នុងឱកាសនេះផងដែរ និស្សិតបានចូលទៅទស្សនាបន្ទប់ឯកសារអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលផ្ទុកឯកសាររាប់សែនទំព័រ។ និស្សិតបានពិនិត្យមើល នឹងចាប់អារម្មណ៍ ឯកសារបទសម្ភាសន៍ដែលចងក្រងអស់រយៈពេលជាច្រើនឆ្នាំ។



ម៉ៅ វណ្ណា (រូបស្តាំ) និង ឡុង គីមស្រ៊ាង (រូបឆ្វេង) ចែករំលែករឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមទៅកាន់និស្សិត មកពីវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ម៉ៅ វណ្ណា ប្រគល់ទស្សនាវដ្ដីស្វែងរកការពិតដល់និស្សិតនៃវិទ្យាស្ថានពហុបច្ចេកទេសកំពង់ចាម។ (លី ដេវីដ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាកិច្ចបន្ត ម៉ៅ វណ្ណា ចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនទៅកាន់និស្សិតចូលរួម ដោយចាប់ផ្ដើមពីពេលវេលារៀននៅសាលាបឋមសិក្សាជាមួយមិត្តភក្ដិពីកុមារភាពជាមួយ ឡុង គីមស្រ៊ាង រហូតដល់ពេលវេលាធ្វើការនៅកងចល័តរយនៅការដ្ឋានឆ្ន័ត្រ។

ម៉ៅ វណ្ណា បន្តថា៖ «នៅវ័យកុមារ ខ្ញុំរៀនសូត្រជាមួយមិត្តរបស់ខ្ញុំឈ្មោះ គីមស្រ៊ាង នៅសាលាបឋមសិក្សាវត្តគ្រូអ៊ុក ស្ថិតនៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន។ ខ្ញុំ និង គីមស្រ៊ាង បានបែកគ្នានៅពេលដែលសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះឡើងនៅឆ្នាំ១៩៧២។ នៅពេលនោះ ភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន គឺជាសមរភូមិប្រទាញប្រទង់គ្នាយ៉ាងខ្លាំង។ ខ្ញុំចាកចេញពីភូមិទី៨ ទៅរស់នៅជាមួយឪពុកបង្រៀននៅវិទ្យាល័យជម្ពូវ័ន្តទីក្រុងភ្នំពេញ ហើយខ្ញុំបន្តការសិក្សានៅទីនោះ ចំណែកឯ គីមស្រ៊ាង រត់ភៀសខ្លួនទៅខាងដីហែគឺជាតំបន់រំដោះខ្មែរក្រហមនៅពេលនោះ។ នៅពេលទីក្រុងភ្នំពេញត្រូវវាយបែកដោយកងទ័ពរំដោះខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំ និងគ្រួសារ បានជម្លៀសមកកាន់ភូមិទី៨វិញ។ នៅឆ្នាំ១៩៧៧ ខ្ញុំជួបគ្នាជាមួយ គីមស្រ៊ាង ជាថ្មីម្ដងទៀត គឺនៅកងចល័តរយនៅការដ្ឋានឆ្ន័ត្រ។ នៅពេលនោះ ខ្ញុំគឺជាប្រជាជនថ្មីត្រូវបានដាក់ឲ្យធ្វើការនៅកងចល័តតាមការដ្ឋាន រួមមាន លើកដី ភ្ជួររាស់ និងដាំដំណាំ។ ចំណែក គីមស្រ៊ាង គឺជាប្រធានកងចល័តរយទទួលបន្ទុកដឹកនាំខ្ញុំ និងសមមិត្ដផ្សេងទៀតក្នុងការ



និស្សិតមកពីវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ទស្សនាពិព័រណ៍នៅបរិវេណមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ ( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ការបង្ហាញឯកសារបទសម្ភាសន៍ទៅកាន់និស្សិតមកពីវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាមនៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
( លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ធ្វើការងារប្រចាំថ្ងៃ។ នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូល មកដល់ និងចាប់ផ្តើមស្រាវជ្រាវប្រវត្តិប្រជាជនថ្មីដើម្បីយកទៅសម្លាប់។ កងចល័តរយ គឺមានប្រជាជនថ្មីសរុបចំនួន ១២នាក់ ។ ខ្ញុំមានឈ្មោះនៅក្នុងចំណោមប្រជាជនថ្មីទាំង១២នាក់នោះ។ នៅយប់មួយ គឹម ស្រ៊ាង ជាប្រធានកងចល័តរយ ដើរស្រង់ឈ្មោះដើម្បីយកទៅសម្លាប់។ នៅពេលនោះ គឹម ស្រ៊ាង ស្រង់ឈ្មោះប្រជាជនថ្មីត្រឹមតែ ១១នាក់ តែប៉ុណ្ណោះ។ នៅព្រឹកបន្ទាប់ អ្នកទាំង ១១នាក់ ដែលសមមិត្ត គឹមស្រ៊ាង ស្រង់យកគឺត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីយកទៅសម្លាប់ទាំងអស់។ ខ្ញុំរួចផុតពីសេចក្តីស្លាប់នៅពេលនោះ និងនៅតែគិតថាមិត្តភក្តិពីកុមារភាពរបស់ខ្ញុំ គឹមស្រ៊ាង បានជួយជីវិតរបស់ខ្ញុំ។ បើទោះបីជាខ្ញុំមានវាសនារួចផុតពីសេចក្តីស្លាប់ឪពុកម្តាយ និងបងប្អូនប្រុសស្រីរបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់យ៉ាងព្រៃផ្សៃដោយបានចងទម្លាក់ចូលក្នុងទន្លេ»។

វាគ្មិនបន្ទាប់គឺ ឡុង គឹមស្រ៊ាង និយាយប្រាប់អំពីបទពិសោធន៍ជីវិតរបស់ខ្លួនថា៖ «ខ្ញុំឈ្មោះ ឡុង គឹមស្រ៊ាង អាយុ៦៨ឆ្នាំ រស់នៅភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ នៅវ័យកុមារ ខ្ញុំរៀននៅសាលាបឋមសិក្សាវត្តគ្រូអ៊ុកត្រឹមថ្នាក់ទី១០ ជាមួយមិត្តរបស់ខ្ញុំ វណ្ណា។ ខ្ញុំ ឃើញអ្នកភូមិជាច្រើនចូលរួមបាតុកម្មដង្ហែទៅទីរួមខេត្តកំពង់ចាម បន្ទាប់ពី

រដ្ឋប្រហារនៅឆ្នាំ១៩៧០។ នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមចាប់ផ្ដើមចូលមកក្នុងភូមិជាបណ្ដើរៗ និងសូមផ្ទះអ្នកភូមិស្នាក់នៅ។ នៅឆ្នាំ១៩៧២ ខ្ញុំឃើញមានយន្តហោះទ្រង់ជ្រូកហោះមកទម្លាក់គ្រាប់បែកយ៉ាងខ្លាំងនៅភូមិ។ ពេលនោះ ខ្ញុំរត់គេចខ្លួនទៅរស់នៅភូមិមហាលាភ។ នៅឆ្នាំ១៩៧៥ ខ្ញុំវិលត្រឡប់មកភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៦ ខ្ញុំចូលធ្វើការនៅក្នុងកងចល័តនារី និងកងចុងភៅរោងបាយរួមស្ថិតនៅកោះសូទិន។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវដាក់ធ្វើជាប្រធានកងរយ ដែលក្តាប់មនុស្សចំនួន ៩៧ នាក់។ កងចល័តរយគឺមានទិសដៅធ្វើការងារនៅការដ្ឋានធ្នឹត្រស្ថិតនៅខាងអូររាំងឪ។ នៅឆ្នាំ១៩៧៧ដដែល ខ្ញុំទទួលបានបទបញ្ជាឲ្យស្រង់ឈ្មោះសមមិត្តចំនួន៣៨នាក់ ដែលកំពុងធ្វើការនៅក្នុងកងចល័តរយនេះ។ ដោយគ្មានជម្រើសអ្វី ខ្ញុំដើរស្រង់ឈ្មោះមិត្តចំនួន៣៨នាក់នោះ និងប្រគល់ដល់ប្រធានក្តាប់ធំ គឺសមមិត្ត ជុន។ នៅថ្ងៃបន្ទាប់ ខ្ញុំដឹងថាឈ្មោះមិត្តទាំងចំនួន៣៨នាក់នោះត្រូវបានសម្លាប់នៅទីវាលក្រោយភូមិ ទីតាំងសម្លាប់នោះ គឺជាគុកចាន់អណ្ដែត។ បន្ទាប់មកខ្ញុំត្រូវ បញ្ជាឲ្យបន្តស្រង់ឈ្មោះប្រជាជនថ្មី ដែលនៅសេសសល់ក្នុងកងចល័តរយនោះ។ ខ្ញុំស្រង់បានឈ្មោះត្រឹមតែ១១នាក់តែប៉ុណ្ណោះ។ នៅពេលនោះ ខ្ញុំមិនដឹងថាសមមិត្ត វណ្ណា គឺជាប្រជាជនថ្មីដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញនោះឡើយ ទើបខ្ញុំមិនបានដាក់ឈ្មោះរបស់វណ្ណានៅក្នុងបញ្ជីសម្លាប់។ ខ្ញុំគ្រាន់តែដឹងថា វណ្ណាក៏ជាប្រជាជនមូលដ្ឋានដូចខ្ញុំដែរ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំឮដំណឹងអំពីសារាចរឈប់សម្លាប់មនុស្ស និងបានវិលត្រឡប់មកភូមិវិញ»។

បន្ទាប់ពីការនិយាយប្រាប់រឿងរ៉ាវជីវិតរបស់វាគ្មិនទាំងពីរមក និស្សិតចូលរួមបានស្តាប់យ៉ាងយកចិត្តទុកដាក់ជាមួយភាពសោកសង្រេង និងការបាត់បង់គ្រួសារនៅក្នុងរបបខ្មែរក្រហម និងបានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖

**សុខ ចំរើន** គឺជានិស្សតឆ្នាំទី១នៃវិទ្យាស្ថានពហុបច្ចេកទេសកំពង់ចាម លើកឡើងថា៖ «ខ្ញុំមានអារម្មណ៍អាណិតអាសូរដល់អ៊ំស្រីទាំងពីរ ដែលរស់នៅក្នុងភាពលំបាកទាំងផ្លូវកាយ ទាំងផ្លូវចិត្ត និងការបាត់បង់សមាជិកគ្រួសារ។ ខ្ញុំពិតជារំភើបនៅចំពោះមិត្តភាពរបស់អ៊ំស្រីទាំងពីរនាក់។ បើទោះបីជាសង្គ្រាម និងរបបខ្មែរក្រហមបានបំបែកភាពស្និតស្នាល និងទំនុកចិត្តយ៉ាងណាក៏ដោយ អ៊ំស្រីទាំងពីរនៅតែគោរពរាប់អានគ្នាជាមិត្តភក្តិពីកុមារភាព»។



និស្សិត សុខ ចំរើន រៀនឆ្នាំទី១នៃវិទ្យាស្ថានពហុបច្ចេកទេសកំពង់ចាម។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**ដឿង គីមឡាង** គឺជានិស្សិតឆ្នាំទី១នៃវិទ្យាស្ថានពហុបច្ចេកទេសកំពង់ចាម បង្ហាញអារម្មណ៍របស់ខ្លួនថា៖ «ខ្ញុំទទួលអារម្មណ៍លំបាកវេទនា និងខ្លោចផ្សារ។ ខ្ញុំមិនបានដឹងពីរឿងរ៉ាវកើតឡើងនៅក្នុងរបបខ្មែរក្រហមជ្រាលជ្រៅប៉ុន្មានទេ គឺខ្ញុំគ្រាន់តែឮតាមជីដូនរបស់ខ្ញុំនិយាយប្រាប់ខ្លះនៅពេលនោះ។ ក្រោយពីបានស្តាប់ផ្ទាល់បែបនេះ ខ្ញុំពិតជាអាណិតអាសូរដល់អ្នកដែលបានរស់នៅក្នុងរបបខ្មែរក្រហម រួមទាំងជីដូនរបស់ខ្ញុំផងដែរ»។



និស្សិត ដឿង គីម ឡាង រៀនឆ្នាំទី១នៃវិទ្យាស្ថានពហុបច្ចេកទេសកំពង់ចាម។ (លី ដេវីដ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្វែងរកបងដែលបាត់ខ្លួន



*លីម គីមហោ បច្ចុប្បន្នរស់នៅភូមិពាក់ស្នែង ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប។*

ខ្ញុំឈ្មោះ **លីម គីមហោ**។ ស្រុកកំណើតរបស់ខ្ញុំនៅតាំងគោក ភូមិរស្មី ឃុំទ្រយោង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ បច្ចុប្បន្ន ខ្ញុំផ្លាស់មកនៅភូមិពាក់ស្នែង ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប។ ខ្ញុំមានឪពុកឈ្មោះ លីម សេងហួ។ ម្តាយខ្ញុំឈ្មោះ ញ៉ៅ យ៉េង។ គាត់បានស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនប្រាំនាក់។ ក្នុងចំណោមបងប្អូនខ្ញុំទាំងប្រាំស្លាប់អស់២នាក់ បាត់ខ្លួនម្នាក់។ បច្ចុប្បន្ននៅសល់តែខ្ញុំនិងប្អូនរបស់ខ្ញុំម្នាក់ឈ្មោះ លីមគីមសានហៅ ឈីវ។ បងរបស់ខ្ញុំដែលបានបាត់ខ្លួនឈ្មោះ លីម គីមយន់ និងប្តីរបស់គាត់ឈ្មោះ សុខ គីមឃួន ហើយកូនស្រីរបស់គាត់ពីរនាក់ទៀតឈ្មោះ សុខ ស៊ីណា និង សុខ ស៊ីណាត។ បងស្រីរបស់ខ្ញុំបានបាត់ខ្លួនមួយគ្រួសារ ទាំងអស់ ទាំងឪពុកម្តាយ និងកូនៗ។ សូមបងប្អូនទាំងអស់គ្នាជួយរកបងរបស់ខ្ញុំផង ក្រែងបានឃើញគាត់ខ្ញុំពិតជាត្រេកអរណាស់។

# សូមប្រកាសរកយាយដែលបាត់ខ្លួន



*លោកយាយ ឡាំ គីម។*

ខ្ញុំឈ្មោះ ត្យូវ៉ានី ម៉ារេស៊ី សព្វថ្ងៃរស់នៅប្រទេសអ៊ីតាលី សូមប្រកាសរកយាយរបស់ខ្ញុំឈ្មោះ ឡាំ គីម មានដើមកំណើតជាជនជាតិចិន។ នៅឆ្នាំ១៩៧៥ គាត់មានអាយុ៦៥ឆ្នាំ។ គាត់រស់នៅម្តុំឃុំគន្ធរ ក្នុងទីក្រុងភ្នំពេញយ៉ាងហោចណាស់រហូតដល់ដើមខែមេសា ឆ្នាំ១៩៧៥។ សាច់ញាតិរបស់ខ្ញុំមួយចំនួនដែលរស់នៅប្រទេសកម្ពុជា ក៏បានបាត់ខ្លួនប្រហែលឆ្នាំ១៩៧៥ ដែរ ហើយប្រហែលអ្នកខ្លះបានរត់គេចខ្លួនទៅប្រទេសវៀតណាម ឬប្រទេសថៃ។ ប្រសិនបើបងប្អូនស្គាល់យាយរបស់ខ្ញុំ សូមទាក់ទងមកខ្ញុំតាមរយៈអ៊ីម៉ែល៖

giovanni.maressi@gmail.com

សូមអរគុណ!

# «ទួលពិឃាដ» (ត)

## ទិដ្ឋភាពយន់ឃ្នង អាសូរស្ត្រីជនជាតិអ៊ីស្លាម និងទារក (ត)

### *សម្លាប់ក្រោមចំពុះទុង, គល់ស្វាយ (ត)*

មកជិតដល់រោងយាមប្រហែលជប់ទៅម៉្តម៉ែត្រ ឃើញកងឈ្លបពីរនាក់នោះ កំពុងតែប្រឡែងគ្នា គាត់ក៏បន្តដំណើរៗ មកជិតដល់ស្រាប់តែកងឈ្លបស្ទុះចេញមកឃាត់ តែខំទប់អារម្មណ៍ធ្វើធម្មតា ហើយគាត់ងក់ក្បាលលើកដៃដោយមិនបញ្ចេញសម្តីតបតទេៗ បន្ទាប់មកមិនដឹងយ៉ាងម៉េចស្រាប់តែកងឈ្លបនោះលើកដៃដែរ ហើយលើកដើមឫស្សីនោះចេញៗ គាត់ខំធាក់កង់ប្រឹងយ៉ាងលឿនឆ្លងកាត់ពួកគេៗ មកបានបន្តិចមើលលែងឃើញគ្នា គាត់ចុះរត់បណ្តើរកង់នោះបន្តទៅទៀតៗ

គាត់គិតអស់សំណើចក្នុងពិភពស្លាប់ ដោយគិតថា ប្រហែលជាកងឈ្លបទាំងនោះ ស្មានថាគាត់ជាកម្មាភិបាលថ្នាក់លើហើយ ព្រោះមានកង់ជិះៗ មិនយូរប៉ុន្មាន គាត់បានឆ្លងកាត់ភូមិជ្រៃរួចមកដល់ភូមិក្រាំងទាំងយប់ងងឹតៗ គាត់ទម្លាក់កង់ចោលនៅក្រោមផ្ទះ រួចឡើងទៅលើផ្ទះលបៗ គោះទ្វារហៅម្តាយគាត់ៗ អ៊ំតែមបើកទ្វារមកឃើញកូនណាត មានការភ្ញាក់ផ្អើល ស្ទុះឱបកូនក្នុងក្តីរំភើប ព្រោះមានក្តីនឹករលឹកយ៉ាងខ្លាំង និងទឹកភ្នែករលីងរលោងស្ទុះឱបកូន ហើយពោលថា "កូន ណាតមិនទាន់ស្លាប់មែនទេ តើកូនគេចខ្លួនដោយរបៀបណា? ពិតជាអាយុវែងមែន"ៗ

អ៊ំតែម គាត់ដឹងថាកងចល័តទាំងអស់ដែលទៅធ្វើការនៅសមរភូមិមុខទួលស្វាយខ្ពប ឃុំកញ្ចុំ ត្រូវខ្មែរក្រហមសម្លាប់ចោលអស់ហើយ ក្នុងនោះមានបងវុឌ្ឍ បងហេង និងបងហោដែលជាបងជីដូនមួយខ្ញុំ នៅក្នុងវត្តកញ្ចុំៗ បងណាត ស្រក់ទឹកភ្នែកតាមម្តាយ រួចបាននិយាយរឿងរ៉ាវទាំងប៉ុន្មានប្រាប់ដល់គាត់ ហើយក៏ចូលទៅសម្រាន្តទាំងអស់គ្នាទៅៗ

ស្អែកព្រឹកឡើងគាត់ភ្ញាក់ពីដំណេក បើកភ្នែកមិនរួច ហើយឈឺរការយ៉ាងខ្លាំង គាត់ក៏ប្រាប់ទៅអ៊ំតែម ម្តាយគាត់ថា ខ្ញុំត្រឡប់ទៅមន្ទីរពេទ្យស្រុកវិញ ហើយក្រែងលោបានធូរស្រាលខ្លះម៉្យាងទៀតភ្នែកក្រហមខ្លាំងណាស់ ខ្លាចខ្វាក់ៗ អ៊ំតែម មិនមានមាត់កអ្វីទេ ដោយឆ្លើយថា អីទៅចុះ កូនប្រយ័ត្នប្រយែងផងៗ បងណាត ធាក់កង់ចេញទៅរួច នឹកគិតក្នុងចិត្តថា បើសិនគេសម្លាប់ក៏សម្លាប់ចុះ ព្រោះឈឺភ្នែកទ្រាំលែងបានហើយៗ ធ្វើដំណើរតាមផ្លូវមិនឃើញមានកងឈ្លបណាមករារាំងជាឧបសគ្គទេៗ

គាត់បានមកដល់មន្ទីរពេទ្យស្រុក ពេលនោះគាត់ជួបកម្មាភិបាលគេឲ្យគាត់ទៅសម្រាកលើគ្រែមួយៗ គាត់ក្រឡេកមើលជុំវិញខ្លួនសុទ្ធតែអ្នកជំងឺស្លេកស្លាំងស្គមស្គាំង អ្នកខ្លះទៀតមិនកំរើក ហាក់ដូចជាស្លាប់ទៅហើយ ដែលគួរឲ្យពិបាកមើលណាស់ៗ រំពេចនោះដែរ ស្រាប់តែឃើញកុមារម្នាក់អាយុប្រហែល១២ឆ្នាំ ហុចថ្នាំឲ្យគាត់ពីរគ្រាប់ហើយនិយាយថា "មិត្តឯងលេបថ្នាំនេះទៅ" គាត់ទទួលថ្នាំពីកុមារនោះ រួចដើរទៅពាងទឹកក្បែរអណ្តូង ដើម្បីរកទឹកមកលេបថ្នាំៗ កំពុងតែដាក់ថ្នាំចូលក្នុងមាត់ ស្រាប់តែកម្មា-ភិបាលបីបួននាក់មកស្រែកប្រាប់គាត់ថា "សមមិត្តទាំងអស់ចូលក្នុងរោងមក" ពេលនោះគាត់ក៏ដើរចូលទៅក្នុងរោងក្បែរនោះៗ កម្មាភិបាលនោះនិយាយបន្តថា "អង្គការឲ្យមកធ្វើជំរឿនប្រជាជន១៧ មេសា ដើម្បីឲ្យទៅរស់នៅភ្នំពេញវិញៗ រំពេចនោះ ពួកគេចាប់ផ្តើមកត់ឈ្មោះគាត់និងអ្នកជំងឺដទៃទៀតៗ ឆ្លៀតពេលនោះគាត់លួចដើរចេញមកក្រៅ ហើយដើរសសៀរយ៉ាងលឿនសំដៅទៅទួលស្វាយខ្ពបវិញ ព្រោះគាត់ហាក់ដូចជាដឹងមុនថា គេធ្វើជំរឿនដើម្បីយកទៅសម្លាប់ៗ

ការធ្វើដំណើរចេញពីមន្ទីរពេទ្យស្រុកពារាំងមានការភ័យខ្លាចយ៉ាងខ្លាំង ខ្លាចពួកវាជិះម៉ូតូមកតាម ព្រោះម៉ូតូនោះកម្មាភិបាលជិះមកធ្វើជំរឿនដូចគ្នា កាលពីគាត់ឃើញសម្លាប់ជនជាតិចាមពីថ្ងៃមុនៗ គិតដល់ត្រង់នេះគាត់ដើរផងរត់ផង រហូតមកដល់ទន្លេជ្រៃៗ ទឹកហូរគួចខ្លាំងណាស់តែដោយសារអំណាចខ្លាចពួកគេមកទាន់ផង គាត់ប្រថុយហែលឆ្លងទន្លេជ្រៃ ហើយបន្តមកដល់ទួលស្វាយខ្ពបៗ

ភ្នែកគាត់ស្រវាំង រកាំមើលមិនបានឆ្ងាយទេ ខំសម្លឹងមើលយ៉ាងយូរ គាត់ឆ្ងល់នៅលើទួលម៉េចបានជាមិនឃើញកងចល័តអ៊ីចឹង? គាត់ដើរទៅ

មុខប្អូនដប់ដំហ៊ានពុះសំឡេងស្រែកថា តោះពួកយើងគេឲ្យទៅផ្ទះវិញហើយ។ មិនយូរប៉ុន្មាន គាត់ឃើញអ្នកភូមិក្រាំងប្អូនដប់នាក់ មានពូឡេង ផង។ ក្នុងអារម្មណ៍ធូរទ្រូងបន្តិច គាត់បាននិយាយប្រាប់ពូឡេងថា ឡេងអើយ ភ្នែកខ្ញុំមិនដឹងយ៉ាងម៉េចទេ មើលទៅប្រហែលខ្វាក់ហើយ ព្រោះចាប់ផ្តើមមើលព្រិលទៅៗ។ ពូឡេង ចាប់ទាញត្របកភ្នែកមើលទៅឃើញក្រហមប្រាលៗ។ ពូឡេងបានបន្តថា "ណាតអើយ ប្រញាប់យកទឹកនោមមកលប់មុខមក ក្រែងគ្រាន់បើ។ មួយសន្ទុះក្រោយមក បងណាត បាននោមដាក់កំប៉ង់ដៃយកមកលុបមុខធ្វើតាមពូឡេង។ ពួកគាត់ប៉ុន្មាននាក់បានចាកចេញពីទួលស្វាយ ខ្ចួចមកភូមិក្រាំងវិញ។ បងណាតបន្តទៀតថា តាមគាត់ដឹង កងចល័តនៅលើទួលជាអ្នក ១៧ មេសា ក្នុងឃុំព្រៃស្រឡិតប្រហែល ៥៧ នាក់ បើសរុបមួយស្រុកពារាំង មានច្រើនរាប់រយនាក់ដែលត្រូវសម្លាប់នៅវត្តកញ្ចាំ។

អំឡុងពេលនោះគាត់បានសុំគណៈរោងបាយ ធ្វើចុងភៅនៅសហករណ៍កណ្តាលភូមិ ដោយមិនត្រឡប់ទៅសមរភូមិកងចល័តវិញទេរហូតដល់ថ្ងៃរៀបការគាត់ និងបងស្រីខ្ញុំ តាមបណ្តាំម្តាយខ្ញុំដែលផ្តាំដល់អ៊ំតែមឲ្យផ្សំផ្គុំកូនយើងទៅ បើអង្គការធ្វើពិធីប្រមូលផ្តុំរៀបការជាក្រុម។

នេះជាសំណាងម៉្យាងដែរ ប្រសិនបើមិនឈឺភ្នែកទេ ប្រាកដជាត្រូវគេសម្លាប់ចោលនៅទីនោះជាមួយកងចល័តទាំងអស់ជាមួយបងប្រុសខ្ញុំដែរនៅក្នុងវត្តកញ្ចាំ។

---

# សម្តី ពូឡេង កងចល័តទួលស្វាយខ្ចួច

ពូឡេង ជាអ្នកមូលដ្ឋានរស់នៅភូមិក្រាំង ទៅធ្វើកងចល័តនៅទួលស្វាយខ្ចួចជាមួយបងណាតដែរ។ បន្ទាប់ពីបងណាតចេញទៅមន្ទីរពេទ្យស្រុកពារាំង កងចល័តនៅលើទួលស្វាយខ្ចួចទាំងអស់ត្រូវមេកងចល័តមកប្រាប់ថា មិត្តណានៅស្រុកណាគេឲ្យត្រឡប់ទៅកន្លែងដើមវិញ។ កងចល័តទាំងអស់ភាគច្រើនជាអ្នក១៧ មេសា ដែលគេប្រមូលមកពីឃុំព្រៃស្រឡិត មានការត្រេកអរយ៉ាងខ្លាំងថាបានទៅរស់នៅទីក្រុងភ្នំពេញវិញ ព្រោះកន្លងមកធ្វើការកងចល័តនៅទីនេះលំបាកខ្លាំងណាស់ ធ្វើការគ្មានពេលយប់ថ្ងៃ ហូបតែបបរជាមួយសម្លប្រហើរ ស្លឹកអង្កាដីស្ទើររាល់ថ្ងៃ។

មេកងចល័តបានណែនាំថា បងប្អូនទាំងអស់មុននឹងចាកចេញទៅរស់នៅកន្លែងដើមវិញ ត្រូវចុះឈ្មោះនៅវត្តកញ្ចាំសិន។ កងចល័តរាប់រយនាក់ជាអ្នក ១៧ មេសា បានដើរតម្រង់ផ្លូវគ្នាទៅវត្តកញ្ចាំនៅរសៀលថ្ងៃនោះ នៅសល់តែ ពូឡេង និងអ្នកមូលដ្ឋានប្រហែលប្រមាណ១០នាក់នៅលើទួលស្វាយខ្ចួច តែគាត់លួចប្រាប់គ្នាគាត់ថា ដូចជាមិនជឿមេកងសោះ។

ស្អែកឡើងមិនឃើញមេកងត្រឡប់មកវិញ គ្នាគាត់ប៉ុន្មាននាក់គ្មានមេគ្មានកើយ មិនដឹងធ្វើអ្វី ស្រាប់តែម្នាក់ឈ្មោះលាងជាចុងភៅស្រែកឡើងថា តោះ! ពួកយើងគេឲ្យទៅភូមិវិញហើយ ព្រោះទឹកឡើងជិតលិចទួលហើយ។ គ្នាគាត់ប៉ុន្មាននាក់បានចាកចេញពីទួលយ៉ាងលឿនសំដៅទៅភូមិក្រាំង ពេលនោះ ពូឡេង បានចាប់ក្របីមួយនឹមឲ្យហែល ទឹកចម្លងគាត់ឆ្លងទន្លេជ្រៃដែលមានទឹកហូរយ៉ាងខ្លាំងស្ទើរក្របីហែលមិនរួច។

ថ្ងៃនោះពួកគាត់បានធ្វើដំណើរមកដល់ភូមិក្រាំងរួចបានដឹងថា អ្នក ១៧ មេសា ត្រូវគេសម្លាប់អស់ហើយ។ រួចគាត់នឹកក្នុងចិត្តថា កងចល័តអ្នក ១៧ មេសានៅទួលស្វាយខ្ចួចប្រហែលជាគេសម្លាប់អស់ដែរ ហើយនៅក្នុងភូមិកញ្ចាំរួមទាំងបងវុទ្ធ បងហោ និងហេង ជាបងជីដូនមួយ។ ថ្ងៃក្រោយមកទៀតពូថា អ្នកធ្លាប់ទៅធ្វើកងចល័តជាមួយគ្នានៅភូមិផ្សេងបានដំណាលថា កងចល័តអ្នក១៧ មេសា ទាំងអស់ក្រោយពីមេកងប្រាប់ថា ឲ្យទៅចុះឈ្មោះនៅវត្តកញ្ចាំ យប់ឡើងពួកកងឈ្លបឲ្យបែកជាក្រុមមានគ្នា៩-១០នាក់ៗ បន្ទាប់មកកងឈ្លបបានហៅក្រុមទាំងនោះឲ្យចេញមកក្រៅ ដោយប្រាប់ថា ទៅចុះឈ្មោះ ហើយកងឈ្លបទាំងនោះចាប់ផ្តើមចងមុខចងស្លាបសេកបណ្តើរយកទៅ សម្លាប់ទម្លាក់រណ្តៅនៅវត្តកញ្ចាំរហូតទាល់តែអស់កងចល័ត ១៧ មេសារាប់រយនាក់។

អត្ថបទខាងលើជាការរៀបរាប់របស់ពូឡេង។

**(តទៅលេខក្រោយ)** **ឡុង ឧទ្យសមិទ្ធ**

រូបក្របមុខ៖
កងទ័ពបដិវត្តន៍និងកម្មាភិបាលខ្មែរក្រហមនៅតាមសហករណ៍កំពុងប្រមូលផលស្រូវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
កងចល័តកំពុងស្ទូងស្រូវនៅវាលស្រែក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 271, July 2022 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.